# សង្ហតការណ៍ ១៨

## ជំណើរកាត់ទោសមេដឹកនាំខ្មែរក្រហម

ខែធ្នូ ឆ្នាំ២០១២





# រចនាសម្ព័ន្ធយោធាក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និង ការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំដំណាក់កាលទី១ និងទី២

## មាតិកា


ការសួរដេញដោលសាក្សី មាស ហឿន ២
ការអានបណ្តាកថាខណ្ឌ...... ១១
សវនាការដាក់ឯកសារ...... ១២
សក្ខីកម្ម ឃឹម សុវណ្ណ និង ជុំ សុខា ២១
សក្ខីកម្ម សុខ ឈិន ២៨
សក្ខីកម្ម ឡាយ បូនី ៣២
សក្ខីកម្ម គង់ គឹម ៣៩
សក្ខីកម្ម ស៊ុំ ជា ៤៣
សក្ខីកម្ម មុំ សំអឿន ៥០
សក្ខីកម្ម ប៉ើជុយ ជីពសែ ៥៣


សញ្ញាជាតិ កម្ពុជាប្រជាធិបតេយ្យ
(ប្រភព ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)


ក្រុមសង្កេតការណ៍ ៖
ឆាយ ឈុនលី, លឹម ជ័យទត្ត,
ឌី សុជាតា, និង ចាន ប្រាថ្នា



មេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យកំពុងអមដំណើរប្រមុខរដ្ឋនៃប្រទេសភូមា នេ វីន នៅក្នុងដំណើរទស្សនកិច្ច
មកប្រទេសកម្ពុជានៅក្នុងខែវិច្ឆិកា ឆ្នាំ១៩៧៧ (ប្រភព ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)

# សវនាការលើសំណុំរឿង០០២ រចនាសម្ព័ន្ធយោធាក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និងការផ្លាស់ទីលំនៅ ប្រជាជនដោយបង្ខំដំណាក់កាលទី១ និងទី២

## ថ្ងៃទី៣ ខែតុលា ដល់ថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១២

ឌី សុជាតា, ឆាយ ឈុនលី, ចាន ប្រាថ្នា និង លីម ជ័យទ័ត្ត

ចាប់ពីថ្ងៃទី៣ ខែតុលា ដល់ថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១២ អង្គជំនុំជម្រះសាលាដំបូង នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានបើកសវនាការស្តាប់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សីចំនួន៩រូបជាបន្តបន្ទាប់ រួមមាន មាស រឿន, យឹម សុវណ្ណ, ជុំ សុខា, សុខ ឈិន, ឡាយ បូនី គង់ គឹម, ស៊ុំ ជា, មុំ សំអឿន និង ប៉េជុយ ជីពសែ ។ សក្ខីកម្មរបស់បុគ្គលទាំង៩រូបនេះ គឺភាគច្រើនពាក់ព័ន្ធនឹងរចនាសម្ព័ន្ធយោធានៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និងការជម្លៀសប្រជាជននៅក្នុងដំណាក់កាលទី១ និងដំណាក់កាលទី២ បន្ទាប់ពីខ្មែរក្រហមចូលកាន់កាប់ទីក្រុងភ្នំពេញនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ។ ក្នុងចន្លោះពេលនោះ អង្គជំនុំជម្រះសាលាដំបូងក៏បានបើកសវនាការពីរដាច់ដោយឡែកផ្សេងទៀតគឺ ទី១) សវនាការស្តីពីការអានដីកាដំណោះស្រាយនូវបណ្តឹងឧទ្ធរណ៍មួយចំនួន ដែលបានចោទប្រកាន់ទាក់ទងនឹងការសម្លាប់អតីតទាហាន និងមន្ត្រីរដ្ឋការនៃរបប លន់ នល់ នៅទួលពោធិ៍ជ្រៃ ហើយចុងបញ្ចប់អង្គជំនុំជម្រះអនុញ្ញាតឲ្យជនជាប់ចោទទាំងអស់ធ្វើការឆ្លើយតបដោយសង្ខេប ។ ទី២) សវនាការស្តីអំពីការដាក់បង្ហាញឯកសារទាក់ទងនឹងរចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋបាលនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ សវនាការនេះអនុញ្ញាតឲ្យភាគីទាំងអស់ រួមទាំងអង្គជំនុំជម្រះផង ដាក់បង្ហាញឯកសារ និងអានដោយសង្ខេបនូវខ្លឹមសារទាំងឡាយដែលពាក់ព័ន្ធនឹងរចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋបាលនៃរបបកម្ពុជាប្រជាធិបតេយ្យ ហើយភាគីទាំងអស់ត្រូវបានផ្តល់ឱកាសឲ្យធ្វើការជំទាស់ចំពោះឯកសារទាំងនោះ ។

ដូចធ្លាប់បានអនុវត្តកន្លងមកហើយ ក្នុងការសួរដេញដោលដើមបណ្តឹងរដ្ឋប្បវេណី គឺត្រូវបានប្រព្រឹត្តទៅតាមលំដាប់ ដោយចាប់ពីក្រុមមេធាវីដើមបណ្តឹងរដ្ឋប្បវេណី តំណាងសហព្រះរាជអាជ្ញា និងក្រុមមេធាវីការពារក្តីជនជាប់ចោទទាំងបីក្រុម ។ ចំណែកការសួរដេញដោលសាក្សីវិញ គឺចាប់ផ្តើមពីតំណាងសហព្រះរាជអាជ្ញា មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងក្រុមមេធាវីការពារក្តីជនជាប់ចោទ ។ សម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សីទាំង៧រូបដូច បានរៀបខាងលើ ភាគច្រើនពុំត្រូវបានក្រុមមេធាវីការពារក្តីចោទសំណួរឡើយ ។ សវនាការទាំងនេះបានប្រព្រឹត្តទៅដោយរលូន ដោយមានការចូលរួមតាមដានដោយផ្ទាល់ពីសំណាក់ប្រជាជនកម្ពុជាប្រមាណ៣៧៨០នាក់មកពីបណ្តាខេត្តនានា ដូចជា ខេត្តកំពង់ចាម ខេត្តកំពង់ធំ ខេត្តកណ្តាល ខេត្តតាកែវ ខេត្តកំពង់ស្ពឺ ខេត្តព្រៃវែង តាមការស្នើអញ្ជើញរបស់មន្ត្រីនៃអង្គភាពផ្នែកកិច្ចការសាធារណៈរបស់សាលាក្តី កាត់ទោសមេដឹកនាំខ្មែរក្រហម ។



ទីក្រុងភ្នំពេញក្រោយថ្ងៃជម្លៀស (ប្រភព ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)

# សវនាការស្ដីពីការស្ដាប់សក្ខីកម្មរបស់សាក្សី មាស វឿន

## ថ្ងៃទី៣ ដល់ថ្ងៃទី៩ ខែតុលា ឆ្នាំ២០១២

នៅក្នុងកិច្ចបន្តដំណើរការនីតិវិធីជំនុំជម្រះ ជនជាប់ចោទទាំងបីរូប នួន ជា, ខៀវ សំផន និង អៀង សារី អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានពិភាក្សាលើកិច្ចដំណើរការវគ្គទីបីនៃសំណុំរឿង០០២/០១ ។ ប្រធានអង្គជំនុំជម្រះបានចាត់ក្រឡាបញ្ជីដើម្បីអានបណ្ដាកថាខ័ណ្ឌមួយចំនួននៃដីកាដំណោះស្រាយទាក់ទងនឹងរចនាសម្ព័ន្ធយោធានៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យរួមមាន ៖ ការបង្កើតកងទ័ពបដិវត្តកម្ពុជា តួនាទីរបស់កងទ័ពបដិវត្តកម្ពុជា ស្ថាប័នកងទ័ពរបស់មជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា សមាសភាពកងទ័ពបដិវត្តកម្ពុជា តួនាទីនៅក្នុងផ្នែកសន្តិសុខបក្សកុម្មុយនីស្តកម្ពុជា ទំនាក់ទំនងជាមួយមេដឹកនាំជាន់ខ្ពស់ផ្សេងទៀតនៃរបបកម្ពុជាប្រជាធិបតេយ្យ និងការចូលរួមក្នុងផែនការរួមនៃការផ្លាស់ទីលំនៅប្រជាជនជាដើម ។



សាក្សី មាស វឿន (ប្រភព ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)

អង្គជំនុំជម្រះសាលាដំបូងបានកោះហៅសាក្សី មាស វឿន ដែលជាបុគ្គលទីមួយមកផ្ដល់សក្ខីកម្មទាក់ទងនឹងរចនាសម្ព័ន្ធយោធានៃរបបកម្ពុជាប្រជាធិបតេយ្យ បន្ទាប់ពីការអានកថាខ័ណ្ឌមួយចំនួននៅក្នុងដីកាដំណោះស្រាយដោយក្រឡាបញ្ជី ។ ក្នុងអំឡុងពេលនៃការផ្ដល់សក្ខីកម្មចាប់ពីថ្ងៃទី៣ ដល់ថ្ងៃទី៩ ខែតុលា ឆ្នាំ២០១២ សាក្សី មាស វឿន បានផ្ដោតជាសំខាន់លើការចូលរួមក្នុងបដិវត្ត ការការពារ ខៀវ សំផន នៅក្នុងព្រៃ ការចូលបម្រើកងទ័ពក្នុងឋានៈជាអនុប្រធានកងពល ការបញ្ជូនសារទូរលេខ និងការទំនាក់ទំនងជាមួយមេដឹកនាំផ្សេងៗនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ក្នុងអំឡុងពេលសវនាការស្ដាប់សក្ខីកម្ម សាក្សី មាស វឿន អង្គជំនុំជម្រះបានផ្ដល់មេធាវីប្រឹក្សាមួយរូបដែលមានឈ្មោះ សេង រិទ្ធី ជូន សាក្សីដើម្បីជៀសវាងពីការផ្ដល់សក្ខីកម្មប្រឆាំងនឹងខ្លួនឯង ។

### ១) ប្រវត្តិសាវតាររបស់សាក្សី មាស វឿន

នៅមុនពេលប្រគល់វេទិកាជូនភាគីដើម្បីសាកសួរដេញដោលដោយប្រធានអង្គជំនុំជម្រះ ។ ចៅក្រម និល ណុន បានសួរអំពីប្រវត្តិសាវតាររបស់សាក្សី ។ ឆ្លើយតបនឹងសំណួរនេះសាក្សីបានរៀបរាប់ថា ខ្លួនមានឈ្មោះ មាស វឿន ហៅ ស៊ុាយ វឿន មានអាយុ៦៨ឆ្នាំ មានទីលំនៅក្នុងខេត្តបន្ទាយមានជ័យ និងមានមុខរបរជាកសិករ ។ ឪពុកឈ្មោះ ស៊ុាយ មាស ម្ដាយឈ្មោះ ប៉ែន អឹម និងប្រពន្ធឈ្មោះ អឹម យឹន និងមានកូន៨នាក់ ។

### ២) ការសួរដេញដោលដោយសហព្រះរាជអាជ្ញា

តំណាងសហព្រះរាជអាជ្ញាជាតិ វ៉េង ហ៊ត់ បានចាប់ផ្ដើមសួរសាក្សីទាក់ទងនឹងការចូលបដិវត្តនៅឆ្នាំ១៩៦៨ ។ ឆ្លើយតបនឹងសំណួរនេះ មាស វឿន បានបញ្ជាក់ថា ដំបូងខ្លួនចូលជាយុវជនតំណាងតាមភូមិ តាមរយៈកម្មាភិបាលដឹកនាំម្នាក់ ។ នៅឆ្នាំ១៩៧០ ខ្លួនគឺជាយុវជនស្ម័គ្រចិត្តក្នុងកងកម្មាភិបាលការពារដែលមានភារកិច្ចការពារកម្មាភិបាលដែលមកពីភ្នំពេញចូលព្រៃរួមមាន វន វេត, នង សួន និង ខៀវ សំផន។ សាក្សីធ្លាប់បានចូលរួមរៀន វគ្គបំប៉នយោធា និងនយោបាយនៅក្នុងអំឡុងពេលនៃរបបអាណានិគមនិយមបារាំង ។ ឆ្លើយតបនឹងសំណួរពាក់ព័ន្ធនឹងរចនាសម្ព័ន្ធយោធា សាក្សី មាស វឿន បានអះអាងថា ប្រធានយោធាភូមិភាគជាបុគ្គលដែលមានឋានៈធំជាងប្រធានកងពល ។

ចំណែកឯរូបសាក្សីផ្ទាល់ក្លាយជាប្រធានកងវរៈសេនាធំនៅឆ្នាំ ១៩៧៥ ដែលតែងតាំងដោយឈ្មោះ សឿង ហើយគ្រប់គ្រងទាហានប្រហែល៦០០នាក់ ប៉ុន្តែការអនុវត្តជាក់ស្តែង គឺទទួលបញ្ជាពីប្រធានកងពលលេខ១ ។ អ្នកមានសិទ្ធបង្កើតកងវរៈសេនាធំរហូតដល់តូច គឺប្រធានភូមិភាគ រហូតដល់ប្រធានកងពល ហើយអ្នកទាំងពីរនោះគឺមានឋានៈប្រហាក់ប្រហែលគ្នា និងអាចពិគ្រោះគ្នាបាននៅ ពេលខ្លះ ។

## ២.ក) ស្ថានភាពប្រជាជននៅទីក្រុងភ្នំពេញ

សាក្សី មាស វឿន បានបញ្ជាក់ថា មុនពេលកងទ័ពខ្មែរក្រហមវាយចូលដល់ទីក្រុងភ្នំពេញ ខ្លួនធ្លាប់ បានចូលរួមប្រយុទ្ធនៅលើផ្លូវជាតិលេខ៥ ត្រង់ម្តុំក្រគរ រហូតដល់ភ្នំពេញ ដែលមានអ្នកបញ្ជាផ្ទាល់គឺ តាម៉ុក ។ នៅពេលនោះ មានការទម្លាក់គ្រាប់ពីលើអាកាសផង និងការប្រយុទ្ធនៅលើដីផង ដែលធ្វើឲ្យប្រជាជនត្រូវបង្ខំចិត្តចាកចោលលំនៅដ្ឋានរបស់ខ្លួន ។ ពាក់ព័ន្ធនឹងការជម្លៀសប្រជាជន មាស វឿន បានបញ្ជាក់ថា នៅក្នុងការប្រជុំកងទ័ពដើម្បីរៀបចំវាយយកទីក្រុងភ្នំពេញ ខ្លួនមិនបានឮអំពីផែនការជម្លៀសប្រជាជនចេញពីទីក្រុងទេ ។ សាក្សីបានបន្តថា ខ្លួនបានទទួលបញ្ជាឲ្យវាយតាមវរៈសេនាធំ ដោយដឹកនាំទ័ពចូលតាមពោធិ៍ចិនតុង រហូតដល់ស្ទឹងមានជ័យ ដោយស្ថានភាពនៅពេលនោះសាក្សីបានឃើញផ្ទះប្រជាជនមានព្យួរទង់សគ្រប់ៗផ្ទះ ។ ទាហាន លន់ នល់ ដែលត្រូវបានចាប់ខ្លួន គឺត្រូវបញ្ជូនទៅប្រធានកងពល ប៉ុន្តែក្រុមរបស់ខ្លួនពុំបានចាប់ទាហាន លន់ នល់ ឡើយ ។ ពាក់ព័ន្ធនឹងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ សាក្សីបានអះអាងថា ខ្លួនមិនដឹងពីគម្រោងជម្លៀសប្រជាជនទេ ប៉ុន្តែនៅក្រោយពេលប្រជាជនចេញមកដល់ក្រៅក្រុងហើយ ទើបខ្លួនបានដឹងថាមានការជម្លៀសប្រជាជន ហើយកងទ័ពរបស់ខ្លួនក៏បើកផ្លូវឲ្យប្រជាជនធ្វើដំណើរចេញតាមសម្រួល ។ បន្ទាប់មក សាក្សីបានទទួលបញ្ជាពីប្រធានកងពលឲ្យដកទ័ពចេញខណៈដែលប្រជាជនមិនទាន់ចេញអស់ពីភ្នំពេញនៅឡើយ ។ មាស វឿន បញ្ជាក់បន្ថែមថា បន្ទាប់ពីរំដោះបានទីក្រុងភ្នំពេញ ភូមិភាគនិរតី និងភូមិភាគបស្ចិម គឺនៅមិនទាន់បែងចែកភ្លាមទេ ។ លុះមួយរយៈក្រោយមក ទើបមានការបែងចែក កងទ័ពនៃភូមិភាគទាំងពីរនេះ ដែលនៅក្នុងនោះសាក្សីត្រូវបានផ្ទេរទៅភូមិភាគបស្ចិម គឺខេត្តកោះកុងជាមួយកងទ័ពមួយកងពលកន្លះដើម្បីការពារព្រំដែនសមុទ្រ ដែលកំពុងមានការប្រយុទ្ធគ្នាជាមួយកងទ័ពថៃដែលចង់ឈ្លានពានទឹកដីខ្មែរ ។ នៅពេលនោះ ប្រទេសថៃបានប្រើយន្តហោះទម្លាក់គ្រាប់មកលើទឹកដីប្រទេសកម្ពុជា ហើយភាគីកម្ពុជាបានបាញ់កាំភ្លើងធំវិញ ប៉ុន្តែមិនអាចចាប់បានទាហានថៃទេ ។

## ២.ខ) ការការពារកម្មាភិបាលនៅក្នុងព្រៃ

តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ថារីក អាប់ឌុលហាក់ បានបន្តសួរសំណួរទាក់ទងនឹងភារកិច្ចរបស់សាក្សីក្នុងជួរបដិវត្ត ។ សាក្សីបានរៀបរាប់ថា ក្នុងអំឡុងពេលនៃការរត់ចូលព្រៃរបស់មេដឹកនាំបក្សកុម្មុយនីស្ត កម្ពុជានៅចុងឆ្នាំ១៩៦៧ និងដើមឆ្នាំ ១៩៦៨ ខ្លួនបានចូលរួមការពារសុវត្ថិភាពដូនកម្មាភិបាលទាំងនោះ ក្នុងឋានៈជាយុវជនកងការពារកម្មាភិបាលនៅភ្នំស្រួច និងនៅស្រុកកំពង់ស្ពឺ ។ ប៉ុន្តែការការពារនេះធ្វើឡើងតែនៅពេលដែលមេដឹកនាំទាំងនោះធ្វើដំណើរតាមផ្លូវប៉ុណ្ណោះ ពីព្រោះពេលខ្លះមេដឹកនាំទាំងខ្មែរក្រហមត្រូវនៅក្នុងព្រៃខេត្តកំពង់ស្ពឺ ឬខេត្តកំពង់ឆ្នាំងជាដើម ដោយសារតែខ្លាចខ្មាំងរកឃើញ ខៀវ សំផន។ សាក្សីអះអាងថា ការធ្វើបែបនេះ គឺជាយុទ្ធសាស្ត្ររបស់ តាម៉ុក ដែលជាអ្នកទទួលភារកិច្ចចាត់ចែងលើកិច្ចការទាំងនេះ ។ មាស វឿន បន្ថែមថា សមាជិកការពារកម្មាភិបាលបានចាប់ផ្តើមការងារដំបូងនៅឆ្នាំ១៩៦៨ ដោយមានសមាជិកត្រឹមតែ២០នាក់ប៉ុណ្ណោះ រហូតដល់ឆ្នាំ១៩៧០ទើបចំនួននេះកើនដល់ប្រហែល ១៥០នាក់ ។ ឆ្លើយតបនឹងសំណួររបស់តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ថារីក ទាក់ទងនឹង ខៀវ សំផន សាក្សីបញ្ជាក់ថាដំបូងខ្លួនមិនបានដឹងថា ខៀវ សំផន មានតួនាទីជាអ្វីនោះទេ គឺគ្រាន់តែដឹងថាជាបុគ្គលស្នេហាជាតិតែប៉ុណ្ណោះ ។ នៅពេលប្រជុំសមាជជាមួយសម្តេចព្រះ នរោត្តម សីហនុ ម្តងៗ ខៀវ សំផន មានតួនាទីជាកុងសីសេដ្ឋកិច្ច ។ សាក្សីបានបញ្ជាក់ថា នៅមុនពេលរដ្ឋប្រហារ ថ្វីត្បិតតែខ្លួនរស់នៅក្នុងព្រៃជាមួយ ខៀវ សំផន ប៉ុន្តែខ្លួនមិនបានដឹងថា ខៀវ សំផន មានមុខនាទីជាអ្វីនោះទេ គឺទើបតែដឹងតាមរយៈការស្តាប់តាមប៉ុស្តិ៍វិទ្យុ ដែលផ្សាយថា ខៀវ សំផន ថាជាប្រធានរណសិរ្សរួបរួមជាតិកម្ពុជា ។ មាស វឿន សង្កត់ធ្ងន់

ថា ខ្លួនបានធ្វើជាកងការពាររបស់ ខៀវ សំផន ចាប់តាំងពីឆ្នាំ ១៩៦៨ រហូតដល់ឆ្នាំ១៩៦៩ ។

## ២.ក) ការវាយចូលឧត្ដុង្គដើមឆ្នាំ១៩៧៣ និងចុងឆ្នាំ១៩៧៤

ពាក់ព័ន្ធនឹងការវាយចូលឧត្ដុង្គ មាស វឿន បានជម្រាបជូនអង្គជំនុំជម្រះថា នៅពេលកងទ័ពរបស់ខ្លួនវាយចូលឧត្ដុង្គ សាក្សីបានឃើញប្រជាជនទាំងអស់ចេញពីឧត្ដុង្គមកតំបន់រំដោះប្រហែល ៨គីឡូម៉ែត្រពីឧត្ដុង្គ ។ សាក្សីបានរំឭកថា ខណៈដែលវាយខ្ទាំងនៅតាមផ្លូវជាតិលេខ៥ ខ្លួនបានចូលរួមក្នុងសមរភូមិនៅក្រគរ និងសមរភូមិនៅមុំឧត្ដុង្គ ដែលកាលនោះអ្នកបញ្ជារួមគឺ តាម៉ុក និងតាសឿង ។ ការវាយនោះគឺមានខ្លះឈ្នះ ខ្លះចាញ់ និងបានវាយជាបន្តបន្ទាប់តាមបណ្ដោយផ្លូវជាតិលេខ៥ ដោយគ្មានការសម្រាករហូតមកដល់ឧត្ដុង្គ ។


យុទ្ធជនខ្មែរក្រហមនៅមុំកប់ស្រូវជាយទីក្រុងភ្នំពេញ (ប្រភព ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅក្នុងសមរភូមិតាមផ្លូវលេខជាតិលេខ៥នេះ ប្រជាជនបានរត់ទៅតំបន់រំដោះ ដូច្នេះតំបន់នោះ គឺមានតែកងទ័ពខ្មែរក្រហម និងទាហាន លន់ នល់ ប្រយុទ្ធគ្នាតែប៉ុណ្ណោះ ។ នៅពេលកងទ័ពរបស់ខ្លួនបានវាយចូលមកដល់ផ្នែកខាងលិចនៃទីក្រុងភ្នំពេញ គឺពុំមានការចាប់ខ្លួនទាហាននៃរដ្ឋការរបប លន់ នល់ នោះទេ ប៉ុន្ដែខ្លួនមិនដឹងថាតើផ្នែកខាងកើតនៃទីក្រុងមានការចាប់ខ្លួនទាហាន លន់ នល់ ដែរឬយ៉ាងណានោះទេ ។

បន្ទាប់មក តំណាងសហព្រះរាជអាជ្ញាអន្ដរជាតិ ថារីក អាប់ឌុលហាក់ បានអានឯកសារដើម្បីសួរបញ្ជាក់សាក្សីទាក់ទងនឹងការថ្លែងសុន្ទរកថារបស់ ខៀវ សំផន ដែលធ្វើឡើងនៅថ្ងៃទី៥ ខែមេសា ឆ្នាំ១៩៧៤ ទាក់ទងនឹងការចាប់ខ្លួនជនក្បត់ ។ ឯកសារនេះបានលើកឡើងថា «នៅក្នុងប្រទេសកងកម្លាំងរំដោះប្រជាជនកម្ពុជា គឺបានវាយកងកម្លាំងផ្សេងៗ ហើយនៅពេលនោះ គឺបានវាយចូលទៅដល់ជិតប្រែកចូលរួចទៅហើយ ។ ភ្នំពេញជាកន្លែងដែលជនក្បត់លាក់ខ្លួន ហើយជាសមរភូមិមួយយ៉ាងក្ដៅគគុក និងមានការតស៊ូមួយយ៉ាងខ្លាំង ពីកងរំដោះប្រជាជនកម្ពុជារបស់យើង ។ នៅថ្ងៃទី១៨ ខែមីនា កងកម្លាំងរួបរួមជាតិរបស់យើងបានរំដោះឧត្ដុង្គ ដោយធ្វើការកម្ទេចទាហានសាធារណរដ្ឋនៅទីនោះ ។ បានន័យថាគឺខ្ទាំងជាង៥០០០ នាក់ត្រូវបានបំផ្លិចបំផ្លាញ ហើយយើងចាប់បាន១៥០០នាក់» ។ ឆ្លើយតបនឹងការលើកឡើងនេះ មាស វឿន បានបញ្ជាក់ថា ខ្លួនពិតជាបានឃើញសាកសពទាហានស្លាប់ និងមានការចាប់ខ្លួនទាហានប្រាកដមែន ប៉ុន្ដែខ្លួនមិនបានដឹងអំពីចំនួនទាហានជាក់លាក់ឡើយ ។ តំណាងសហព្រះរាជអាជ្ញាអន្ដរជាតិ បានបន្ដរំឭកពីរបាយការណ៍ដែលថាប្រជាជនស៊ីវិលប្រមាណជិត៣ម៉ឺននាក់ ត្រូវបានទាហានខ្មែរក្រហមបណ្ដើរចេញទៅតំបន់រំដោះផ្សេងៗ នៅពេលដែលកម្លាំងកងទ័ពខ្មែរក្រហមវាយដណ្ដើមយកបានក្រុងឧត្ដុង្គ ។ សាក្សីបានរៀបរាប់ថា ខ្លួនបានឃើញប្រជាជនចាកចេញពីឧត្ដុង្គពិតប្រាកដមែន ប៉ុន្ដែពុំដឹងថាមានចំនួនប៉ុន្មាននោះទេ គ្រាន់តែដឹងថាការចាកចេញរបស់ប្រជាជនទាំងនោះពុំមែនកើតឡើងដោយការស្ម័គ្រចិត្តនោះទេ ដោយសារមានការប្រយុទ្ធគ្នាយ៉ាងខ្លាំងរវាងកម្លាំងរបស់ខ្មែរក្រហម និងកម្លាំងរបស់ លន់ នល់ ។

## ២.ឃ) ការវាយចូលទីក្រុងភ្នំពេញនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥

ឆ្លើយតបនឹងសំណួររបស់តំណាងសហព្រះរាជអាជ្ញា មាស រឿន បានជម្រាបជូនអង្គជំនុំជម្រះថា ក្នុងការវាយចូលភ្នំពេញ ខ្លួនបានដឹងថា មានកងពលមកពីភូមិភាគនិរតី ភូមិភាគបូព៌ា និង ភូមិភាគឧត្តរ ដែលកងពលទាំងនោះទទួលបញ្ជាពី សុន សេន និង តាម៉ុក ។ កងវរៈសេនាធំរបស់ខ្លួន គឺមានមុខសញ្ញាទទួលខុសត្រូវ ពីពោធិ៍ចិនតុងទៅអូបែកក្អម និងទៅស្ទឹងមានជ័យ ដែលមាន សមាជិក ៦០០នាក់ ហើយបានចូលមកដល់ទីក្រុងភ្នំពេញនៅថ្ងៃ ទី១៧ ខែមេសា ឆ្នាំ១៩៧៥ នៅម៉ោងប្រហែល៩ ឬ១០ព្រឹក ។ ចំណែកឯកងទ័ពរបស់កងពលភូមិភាគឧត្តរ និងបូព៌ា បានសំដៅ ទៅអគ្គសេនាធិការយោធារបស់ លន់ នល់ តែម្ដង ក្រោយពេល ចូលមកដល់ទីក្រុងភ្នំពេញ ។ រីឯកងទ័ពរបស់ខ្លួនបានចូលដល់ ត្រឹមតែបុរីកីឡាតែប៉ុណ្ណោះ ក្នុងរយៈពេលប្រហែលមួយយប់ មួយថ្ងៃ ។ សាក្សីបានឃើញប្រជាជនចេញពីទីក្រុងភ្នំពេញទៅ តាមផ្លូវជាតិ លេខ៣ និងលេខ៤ ហើយអ្នកទាំងនោះបានប្រាប់ សាក្សីថា កងទ័ពឲ្យប្រជាជនចាកចេញពីទីក្រុង ។ សាក្សីអះអាងថា ខ្លួនមិនបានដឹងពីផែនការដែលគេឲ្យប្រជាជនចេញមកពីទីក្រុងទេ លោកបានដឹងតាមរយៈមេបញ្ជាការកងពលខ្លះថា ប្រជាជនត្រូវ ចេញពីទីក្រុងមួយសប្ដាហ៍ ទើបអនុញ្ញាតឲ្យត្រឡប់មកវិញ ។ ក្រោយពីរំដោះបានទីក្រុងភ្នំពេញ សាក្សីត្រូវបាន តាម៉ុក ចាត់ ឲ្យមកធ្វើស្រែនៅកំបូល និងក្រោយមកត្រូវបានបញ្ជូនទៅស្រុក កំពង់ត្រាច ខេត្តកំពត ប្រហែល១៣ខែ ។ នៅចុងឆ្នាំ១៩៧៦ ប្រធានកងពល និងប្រធានភូមិភាគបស្ចិមគឺ សឿន និង ជូ ជេត ហៅ ស៊ី បានបញ្ជូនខ្លួនទៅខេត្តកោះកុងចំនួន៣ឆ្នាំ ដើម្បីដឹកនាំកងទ័ព ២៧០០នាក់ ។ ក្រោយពេលទៅដល់កោះកុងប្រហែល១ខែ កងទ័ពរបស់ខ្លួនបានឆ្លងជំងឺគ្រុនចាញ់ ហើយបានត្រឡប់មក វិញស្ទើរតែទាំងអស់ ពោលគឺនៅសល់ប្រហែល៧០០នាក់តែ ប៉ុណ្ណោះ ។ នៅខេត្តកោះកុង មាស រឿន និងកងទ័ពទទួលបន្ទុក ការពារព្រំដែនសមុទ្រ និងព្រំដែនគោក ដោយមានកប៉ាល់ចល័ត ទាំងយប់ទាំងថ្ងៃ និងកម្លាំងថ្មើរជើងដាក់តាមកោះ និងតាម ដីគោក ។ សាក្សីក៏បានទទួលភារកិច្ចការពារកោះស្ដេច កោះរ៉ុង និងកោះយ៉ ជាប់ព្រំដែនថៃដែរ ។ ចំណែកឯដែនដីពីកោះស្ដេច ទៅកោះភូឡូវ៉ៃ គឺទទួលបន្ទុកដោយកងពលលេខ៣របស់តាម៉ុក ។ ពេលទៅដល់ខេត្តខេមរភូមិន្ទ (ខេត្តកោះកុងបច្ចុប្បន្ន) ប្រជាជន ទាំងអស់ត្រូវបានជម្លៀសចេញអស់ពីទីនោះហើយ គឺនៅសល់តែ កងទ័ពតែប៉ុណ្ណោះ ។

## ២.ង) ការបញ្ជូនសារទូរលេខ

សាក្សីបានបំភ្លឺជូនអង្គជំនុំជម្រះថា នៅខេត្តកោះកុង ពុំមាន មន្ទីរ ឬការិយាល័យទេ គឺមានតែជំរុំតូចៗ ធ្វើនៅតាមកោះ តែប៉ុណ្ណោះ ។ ចំពោះការបញ្ជូនសារនៅកន្លែងរបស់ខ្លួន គឺធ្វើតាម រយៈម៉ាស៊ីនបញ្ជូនសារទូរលេខ និងមានលេខសម្គាល់០៧ ចំណែក ៦០៨ និង០៩នោះ គឺជារបស់មន្ទីរផ្សេង ។

ព្រះរាជអាជ្ញា ជារីក បានបន្តការដាក់បង្ហាញឯកសារសារ ទូរលេខដែលសរសេរដោយ សឿង ប្រធានកងពល ។ ឯកសារ នេះមានចំណាររបស់ ខៀវ ប៉ុន្តែសាក្សីបញ្ជាក់ថា នៅកោះកុង គឺ ពុំមានឈ្មោះ ខៀវ នោះទេ ប៉ុន្តែបើនៅអគ្គសេនាធិការ ខៀវ គឺ សុន សេន ។

សាក្សីបានបញ្ជាក់ថា ប៉ុល ពត បាននិយាយពីសភាពការណ៍ យួនវាយតាមព្រំដែនខាងកើតចាប់ពីខេត្តព្រៃវែង ស្វាយរៀង កំពង់ចាម រតនគិរី និងមណ្ឌលគិរី ។ នៅក្នុងជំនួបនោះ សាក្សីបាន ទទួលការណែនាំ ពាក់ព័ន្ធនឹងការផ្ទេរខ្លួនទៅព្រះវិហារ ដើម្បីបញ្ជាក់ អំពីសភាពការណ៍ប្រជាជននៅខេត្តព្រះវិហារថា តើមានការចាប់ ចងប្រជាជនបង្អត់អាហារ និងការចាប់ប្រជាជននៅខេត្តសៀមរាប ដាក់គុកដែរឬយ៉ាងណា ។

## ២.ច) តួនាទីរបស់មេដឹកនាំសំខាន់ៗ

ទាក់ទងនឹងតួនាទីសំខាន់ៗរបស់មេដឹកនាំបក្សកុម្មុយនីស្ត កម្ពុជា តំណាងសហព្រះរាជអាជ្ញាបានលើកយកសេចក្ដីប្រកាស របស់ ខៀវ សំផន ដែលថា “ចំពោះសមរភូមិផ្លូវជាតិ៥ គឺកងទ័ព រំដោះជាតិកម្ពុជា បន្តកម្ទេចពីខាងត្បូងកំពង់ឆ្នាំង រហូតទៅដល់ សាលាលេខ៥.... យោងតាមស្ថិតិ គឺយើងបានធ្វើការកម្ទេច និង ធ្វើឲ្យមានរបួសឈ្លើយសឹក១០៥០ នៅសមរភូមិបន្ទាយមាស កំពង់ឆ្នាំង និងព្រៃខ្មែរតាមផ្លូវជាតិលេខ៥ ។ បន្ថែមពីនោះ ក្រុម ទាហានរបស់យើងនៅសមរភូមិតាមផ្លូវជាតិលេខ៥ បានចូលរួម

វាយប្រយុទ្ធខ្លាំងប្រហែល ៩០នាក់បន្ថែមទៀត» ។ សាក្សីបាន ពន្យល់ថា ឯកសារដែលសហព្រះរាជអាជ្ញាបានលើកឡើង គឺ ពិតជាត្រឹមត្រូវ ប៉ុន្តែស្ថានភាពដែលលើកឡើងស្ថិតក្នុងអំឡុង ខែមករា ឆ្នាំ១៩៧៣ គឺខ្លួនមិនបានដឹងថា ខៀវ សំផន កាន់ តួនាទីអ្វីនោះទេ ។

សាក្សីបានទទួលស្គាល់ថាខ្លួនធ្លាប់បានរាយការណ៍ជូន ខៀវ សំផន អំពីសកម្មភាពរបស់ខ្លួននៅខេត្ត ព្រះវិហារ ឬសៀមរាប តាមរយៈសារទូរលេខ ។ ក្នុងនោះសាក្សីបានសរសេរជាក្រដាស និងមានដាក់ឈ្មោះរបស់ខ្លួន និងតំបន់១០៣ដើម្បីផ្ញើទៅ ខៀវ សំផន ហើយនៅពេលសភាពការណ៍មមាញឹក គឺត្រូវរាយការណ៍ ដែលជាប្រធាននារីតំបន់ឲ្យចេញពីគុកនៅក្នុងខេត្តសៀមរាប ។ សាក្សីបានបញ្ជាក់បន្ថែមថា នៅក្នុងចំណោមអ្នកទោសទាំងចំនួន ៧០០ នាក់ដែលត្រូវបានឃុំខ្លួន គឺមានតែបងថ្លៃស្រីរបស់ ខៀវ សំផន ម្នាក់ប៉ុណ្ណោះដែលខ្លួនបានដោះលែង ។

ទាក់ទងនឹងការប្រជុំផ្នែកភូមិភាគ សាក្សីបានរៀបរាប់ថា ធ្លាប់មានការប្រជុំភូមិភាគនៅក្នុងជួរយោធា គឺប្រជុំសន្និបាត ភូមិភាគមានរយៈពេល១សប្ដាហ៍ ដោយមានការពិភាក្សាអំពីវគ្គ សិក្សារៀនសូត្រ ។ អ្នកចូលរួមក្នុងកិច្ចប្រជុំនោះរួមមាន ប៉ុល ពត តាម៉ុល និង តាស៊ី ដែលអ្នកទាំងបីនេះ ជាអ្នកពិភាក្សាអំពីការ បោសសម្អាតខ្មាំងស៊ីរូងផ្ទៃក្នុង ។ ភ្លាមៗបន្ទាប់ពីសាក្សីឆ្លើយ


ខៀវ សំផន និង សុន សេន នៅទីក្រុងបាងកក ក្នុងខែវិច្ឆិកា ឆ្នាំ១៩៩១ (ប្រភព ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)

រយៈពេលមួយសប្ដាហ៍ម្ដង ឬមួយខែម្ដង ។ មូលហេតុដែលខ្លួន រាយការណ៍នេះ ដោយសារមានសារទូរលេខពី ខៀវ សំផន ថា ពេលមានស្ថានភាពអ្វីត្រូវរាយការណ៍ឲ្យគាត់ ។ សាក្សីបានបន្ថែម ថា នៅពេលក្រោយមក ខ្លួនបានដឹងតាមរយៈប្រជាជន និងប្រធាន មន្ទីរពេទ្យថា ខៀវ សំផន និង នួន ជា ទទួលបន្ទុកនៅតំបន់ស្វយ័ត ១០៣ ។ ដោយសារ ខៀវ សំផន មានតួនាទីនេះ សាក្សីបានទទួល បញ្ជាឲ្យដោះលែងបងថ្លៃស្រីរបស់ ខៀវ សំផន ឈ្មោះ យៀត សំណួរនេះ តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ បានព្យាយាម លើកយកអត្ថបទសម្រង់របស់សាក្សី ដែលបានផ្ដល់សក្ខីកម្មជូន សហចៅក្រមស៊ើបអង្កេតថា "ខ្ញុំបានចូលរួមសន្និបាតចំនួនពីរលើក ដែលមាន តា នួន ជា ឬតា ប៉ុល ពត ចូលរួមនៅខេត្តកំពង់ស្ពឺ និងនៅ បន្ទាយលង្វែកខេត្តកំពង់ឆ្នាំង" ។ សាក្សីបញ្ជាក់បន្ថែមថា ការ ដែលខ្លួនលើកឡើងដូច្នេះ គឺដោយសារខ្លួនបានឃើញវត្តមានរបស់ នួន ជា នៅក្នុងការប្រជុំនោះពិតប្រាកដមែន ។

### ៣) ការសួរដេញដោលដោយមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី

ពេជ អង្គ មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានចាប់ផ្តើមសំណួរទាក់ទងនឹងការចូលបដិវត្តរបស់ មាស រឿន និងការបង្កើតកងទ័ពខ្មែរក្រហម ។ សាក្សីបានបញ្ជាក់ថា កងទ័ពខ្មែរក្រហមបានបង្កើតឡើងមុនថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដែលមានទាំងកងទ័ពជើងគោក ជើងទឹក និងជើងអាកាស ។ ពោលគឺមានតាំងពីឆ្នាំ១៩៦៧ ដល់ឆ្នាំ១៩៦៩ ដែលមានការតស៊ូតាំងពីជំនាន់ឥស្សរៈនៅភូមិបាយដំរាំ និងនៅភូមិវាយចាបមកម្ល៉េះ ។ ឆ្លើយតបនឹងសំណួរទាក់ទងនឹងពាក្យថា "កងទ័ព" មាស រឿន បានពន្យល់ថា ខ្លួនធ្លាប់បានឮបក្សប្រើពាក្យ"កងទ័ព"ថា គឺជាឧបករណ៍ផ្តាច់ការរបស់បដិវត្តន៍ដែលមានន័យថា កងទ័ពខិតខំបម្រើបក្សធ្វើការដោយគ្មានកម្រៃ ឬក៏លះបង់ជីវិតដើម្បីជាតិមាតុភូមិ ពាក្យនេះត្រូវបានប្រើនៅអំឡុងឆ្នាំ១៩៧០ រហូតដល់ឆ្នាំ១៩៧២ ។ ចំណែកពាក្យ"កងការពារសម្ងាត់" សាក្សីបានផ្តល់និយមន័យថា គឺជាកងការពារកម្មាភិបាលដោយសម្ងាត់ ដើម្បីតស៊ូនឹងអំណាចនាយទុន ឃោសនាអប់រំប្រជាជនដោយសម្ងាត់ អប់រំអំពីប្រទេសជាតិ សេដ្ឋកិច្ច នយោបាយ និងការជិះជាន់ពីរបបនាយទុនសក្តិភូមិ ដើម្បីដៀសវាងរដ្ឋអំណាច លន់ នល់ អាចស៊ើបព័ត៌មានបាន ។ សាក្សីបន្តថាការទាក់ទងគ្នានៅពេលនោះ គឺមានការលំបាកដោយសារត្រូវដើរបញ្ជុះបញ្ចូលប្រជាជនត្រូវកាត់ព្រៃ និងចំណាយពេលជាច្រើនខែ ។

សាក្សីបន្ថែមថា តួនាទី និងភារកិច្ចរបស់យោធាចាប់ពីឆ្នាំ១៩៧៥ គឺត្រូវតែគោរពមាគ៌ាមួយដែលថា "ដៃម្ខាងវាយខ្មាំង ដៃម្ខាងបង្កបង្កើនផល" ។ ចំពោះគោលការណ៍ផលិតស្រូវឲ្យបានបីតោនក្នុងមួយហិចតា គឺជាផែនការរបស់មជ្ឈិមបក្សរួមមាន ប៉ុល ពត, នួន ជា និងតាម៉ុក ជាដើម ដើម្បីដាក់ឲ្យគណៈភូមិភាគ និងតំបន់អនុវត្តតាម ។

ទាក់ទងនឹងរចនាសម្ព័ន្ធយោធានៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យសាក្សីបានពន្យល់ថា មានការបែងចែកចេញជាបី គឺយោធាភូមិភាគ យោធាតំបន់ និងយោធាស្រុក ។ យោធាភូមិភាគបែងចែកជាក្រុមវរៈសេនាតូច វរៈសេនាធំ និងកងពល ។ ចំណែកឯកងទ័ពបែងចែកជាបីប្រភេទ គឺកងទ័ពភូមិភាគ កងទ័ពស្រួច និងកងទ័ពឈ្លប ។ នៅក្នុងកងទ័ពភូមិភាគ ដែលមាននាទីការពារព្រំដែនខាងក្រៅ គឺបែងចែកជាកងទ័ពតំបន់ និងកងទ័ពស្រុក ហើយមាននាទីការពារ តាមតំបន់ និងស្រុករៀងខ្លួន ។

ពាក់ព័ន្ធនឹងការរៀនសូត្រសាក្សី មាស រឿន បានបញ្ជាក់ថា ខ្លួនទទួលការបណ្តុះបណ្តាលពី តាម៉ុក ទៅតាមដំណាក់ៗនៃសភាពការណ៍ ។ ដំណាក់កាលទីមួយ គឺនៅពេលខ្លួនរស់នៅក្នុងព្រៃជាមួយគ្នា ។ តាម៉ុក បានបង្រៀនទាក់ទងនឹងសភាពការណ៍របស់ប្រទេសជាតិដែលមិនទាន់បានឯករាជ្យ ជាពិសេសសេដ្ឋកិច្ចស្ថិតនៅក្រោមការត្រួតត្រារបស់អាណានិគមបារាំង ។ ទីពីរ នៅពេលទៅសមរភូមិដើម្បីវាយខ្មាំងជាមួយគ្នា តាម៉ុក បានបង្រៀនពីការយុទ្ធសាស្ត្រវាយខ្មាំង ដែលមានដូចជា ការវាយតាមភូមិ វាយទីតាំងវាយនៅតាមផ្លូវជាតិ ការផ្តាច់ស្ពាន និងផ្តាច់ផ្លូវ ដែលជាសរសៃឈាមក្នុងការទាក់ទងគ្នារបស់ខ្មាំង ។ ទីបី ក្រោយពេលទទួលបានជ័យជម្នះ តាម៉ុក បានបង្រៀនអំពីការការពារ និងការកសាងប្រទេសជាតិគឺ "ដៃម្ខាងវាយខ្មាំង ដៃម្ខាងការពារជាតិ" ។

ពាក់ព័ន្ធនឹងស្ថានភាពទីក្រុងភ្នំពេញនៅពេលដែលទាហានខ្មែរក្រហមវាយចូល សាក្សីបញ្ជាក់ថា ប្រជាជននៅក្នុងទីក្រុងបានចងទង់សនៅតាមផ្ទះ ហើយមានប្រជាជនខ្លះបានចេញពីផ្ទះ និងបានមកប្រាប់ទាហានរបស់ខ្លួនថា ប្រជាជនអត់បាយ និងអត់ថ្នាំពេទ្យ ។ សាក្សីបានឃើញប្រជាជនវាយចូលក្នុងមន្ទីរពេទ្យ ព្រមទាំងបានវាយកញ្ចក់ដើម្បីយកថ្នាំ ដោយមានអ្នកខ្លះមុតចេញឈាមទៀតផង ។

សាក្សីបានបញ្ជាក់ថា មុនឆ្នាំ១៩៧៣ ខ្លួនគោរពស្រលាញ់ ហ៊ូ យន់ និង ហ៊ូ នឹម ដូចជាឪពុករបស់ខ្លួនបង្កើត ។ ប៉ុន្តែឆ្នាំ១៩៧៥ ខ្លួនលែងបានជួបអ្នកទាំងពីរនេះរហូតដល់ពេលនៃការដួលរលំរបស់របបកម្ពុជាប្រជាធិបតេយ្យនៅឆ្នាំ១៩៧៩ ។ សាក្សីបានឮតាមមិត្តភក្តិរបស់ខ្លួនថា ហ៊ូ យន់ ត្រូវបានចាប់ខ្លួនដោយសារបានប្រឆាំង ឬទំនាស់ចំពោះការចាយលុយនៅក្នុងអគ្គភាពរបស់ខ្លួន ។

### ៤) ការសួរសាក្សីដោយចៅក្រម ហ្សង់ម៉ាក ឡាវើញ

ចៅក្រមអន្តរជាតិ ហ្សង់ម៉ាក ឡាវើញ បានបង្ហាញផែនទី

ពណ៌ធម្មជាតិជូន មាស វឿន ដើម្បីពិនិត្យ និងបានសួរសំណួរមួយចំនួនពាក់ព័ន្ធនឹងរចនាសម្ព័ន្ធយោធា ។ សាក្សីបញ្ជាក់ថា ស្ថានភាពនៅមុនឆ្នាំ១៩៧៥ កងពលភូមិភាគ១ នៅក្រោមលេខាភូមិភាគនិរតី គឺតាម៉ុក ក្រោយមកជំនួសដោយ តាស៊ី ។ នៅពេលដែលចៅក្រមលើកឡើងពីឈ្មោះ សំ ប៊ិត និង មាស មុត សាក្សីបញ្ជាក់ថា ខ្លួនធ្លាប់តែឮឈ្មោះបុគ្គលទាំងពីរនេះ ប៉ុន្តែពុំដឹងពីតួនាទីឡើយ ហើយក៏ពុំដឹងថា ការរាយការណ៍របស់ មាស មុត ដែលជាប្រធានកងពល ១៦៤ ជូនទៅអ្នកណានោះដែរ ។

បន្ទាប់មក ចៅក្រម ឡាវ៉ើញ បានលើកយកអត្ថបទសម្រង់មួយចុះខែកក្កដា ឆ្នាំ១៩៧៨ ដើម្បីសួរបញ្ជាក់សាក្សីត្រង់ចំណុចខ្លះ ដែលទាក់ទងនឹងការបោសសម្អាតលើជនជាតិវៀតណាម ភ្នាក់ងារសេ.អ៊ី.អា និងសមាសភាពមិនល្អ ។ ផ្នែកនោះបានសរសេរថា ៖

*ទី១. យើងបានកម្ទេចវៀតណាម១០០នាក់ ទាំងធំទាំងតូចទាំងចាស់ទាំងក្មេង ។ ទី២ យើងបានសម្លាប់មនុស្ស៦០នាក់ ដែលជាអ្នកមានឋានៈ ហើយនិងជាភ្នាក់ងារសេ.អ៊ី.អា ពួកចក្រពត្តិអាមេរិក ដែលបង្កប់ខ្លួននៅក្នុងអង្គភាព និងក្នុងសហករណ៍ ។ ទី៣ ក្នុងកងទ័ពតំបន់យើងបានបោសសម្អាតពួកយុទ្ធជនចិន ដែលនៅក្នុងជួរកងទ័ព ។ យោធាចិន ៤០នាក់ត្រូវបានរក្សាទុកឲ្យធ្វើការបង្កបង្កើនផល ។ ទី៤ វិធានការពាក់ព័ន្ធនឹងយោធាវៀតណាម ។ ទី៥ មនុស្ស១០នាក់នៅក្នុងកងអនុសេនាតូច អនុសេនាធំ និងសហករណ៍មួយចំនួនត្រូវបានបោសសម្អាតចោល ។ អ្នកខ្លះគឺជាមនុស្សខ្ជិលច្រអូស អ្នកខ្លះជាអ្នកជិតាស់ ហើយអ្នកខ្លះជេរចំពោះប្រជាជន ។ អ្នកខ្លះទៀត ត្រូវបានប្រកាសដោយខ្មាំង ហើយអ្នកខ្លះមិនចង់ធ្វើការ ។ វិធានការយើងចំពោះប្រតិបត្តិការរបស់ខ្មាំងដែលបានលើកឡើងខាងលើនេះ ៖ បន្តតាមដាន និងស្វែងរកខ្សែខ្មាំងគ្រប់ទាំងអស់ ដែលបានបង្កប់ស៊ីរូងផ្ទៃក្នុង ហើយនៅពេលដែលយើងចាប់បានហើយ យើងបន្តធ្វើការបោសសម្អាតនៅតាមមូលដ្ឋាន អង្គភាព មន្ទីរ និងក្រសួងនានា ដើម្បីកម្ទេចឲ្យស្អាតបរិសុទ្ធ» ។*

សាក្សី ឆ្លើយតបថា ខ្លួនបានដឹងពីផែនការខាងលើនេះខ្លះ គឺផែនការកម្ទេចយួន និងសម្អាតក្រែងមានខ្មាំងយួនបង្កប់នៅក្នុងជួរអង្គភាពស៊ីរូងផ្ទៃក្នុង ។

ពាក់ព័ន្ធនឹងការរៀបអាពាហ៍ពិពាហ៍ សាក្សីបញ្ជាក់ថា បុរសគឺចាប់ពីអាយុ២០ឆ្នាំ ហើយនារីចាប់ពីអាយុ១៨ឆ្នាំ អាចរៀបការបានដោយមិនបាច់បង្ខំឡើយ ។ ទាក់ទងនឹងមេដឹកនាំមួយចំនួន សាក្សីបានបដិសេធថា ខ្លួនមិនដឹង កុយ ធួន ត្រូវបានខ្លួនបញ្ជូនមកមន្ទីរស-២១ទេ ។ ចំណែកឯ កែ ពក វិញ ក្រោយពេលវៀត-ណាមវាយចូលប្រទេសកម្ពុជា រួចហើយទើបខ្លួនដឹងថា កែ ពក នៅខេត្តកំពង់ធំ ។ សាក្សីបានបន្តថា មេដឹកនាំមិនដែលពិភាក្សាជាមួយខ្លួនអំពី កែ ពក ទេ ។

## ៥) ការសួរដេញដោលសាក្សីដោយមេធាវីការពារក្តីទាំងបីក្រុម

### ៥.ក) ក្រុមមេធាវីការពារក្តី នួន ជា

សុន អរុណ មេធាវីជាតិការពារក្តីជនជាប់ចោទ នួន ជា បានចាប់ផ្តើមសំណួររបស់ខ្លួនទាក់ទងនឹងរចនាសម្ព័ន្ធយោធា ដែល មាស វឿន បានសិក្សា ។ មាស វឿន បានបំភ្លឺថា ដំបូងបក្សបានរៀបចំមនុស្សជាពីរក្រុម ដែលមានសមាជិក១២នាក់ ។ នៅក្នុងរចនាសម្ព័ន្ធយោធាគឺមានចាប់ពីក្រុមវរៈសេនាតូច វរៈសេនាធំ អនុសេនាតូច អនុសេនាធំ និងកងពល ។ ការបូកបញ្ចូលគ្នារវាងបីក្រុមស្មើនឹងមួយកងអនុសេនាតូច បីអនុសេនាតូចស្មើនឹងមួយកងអនុសេនាធំ ចំនួនបីអនុសេនាធំស្មើនឹងមួយវរៈសេនាធំ ចំនួនបីវរៈសេនាធំស្មើនឹងមួយកងពលតូច ដែលនៅក្នុងនោះមានកងពិសេសវរៈសេនាតូចសម្រាប់កងពលតូចប្រើប្រាស់ និងចុងក្រោយ គឺចំនួនបីកងពលតូចរៀបចំបានមួយកងពលធំ ។ សាក្សីបានបញ្ជាក់ថា មានពេលខ្លះការរៀបចំនោះ គឺមិនបានចំនួនជាក់លាក់ទេ ដោយសារតែពេលខ្លះ យោធាទាំងនោះទៅប្រយុទ្ធជាមួយខ្មាំងហើយបានបាត់បង់ជីវិតអស់ខ្លះ ដែលក្នុងមួយកងវរសេនាធំមិនលើសពី៦០០នាក់ និងក្នុងមួយកងពលមិនលើសពីចំនួន៣០០០នាក់នោះឡើយ ។ មាស វឿន ធ្លាប់បម្រើការងារនៅក្នុងកងវរៈសេនាតូច១៣៦ ក្រោយមកឡើងមកកាន់នៅវរៈសេនាធំលេខ១១៦ និងនៅកងពលលេខ១ ។

នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ មាស វឿន ធ្លាប់ឮថា វៀតណាមបានបើកកប៉ាល់ធំ មកចូលវាយយកកោះវៃ ដែលកោះនោះស្ថិតនៅក្រោម ការគ្រប់គ្រងរបស់ មាស មុត ។ សាក្សី

បានដឹងអំពីបញ្ហានេះតាមរយៈកងពលលេខ៣ ដែលបាននិយាយប្រាប់អំពីការប្រយុទ្ធគ្នាជាមួយវៀតណាមនៅកោះវៃ និងកោះតាង ។ វៀតណាមបានវាយឈ្នះកម្ពុជា ហើយបានកាន់កាប់កោះនោះ ។ ប៉ុន្តែក្រោយមកវៀតណាមដកទៅវិញ ឬយ៉ាងណានោះលោកពុំបានដឹងទេ ។

ទាក់ទងនឹងជនជាប់ចោទ នួន ជា សាក្សីបញ្ជាក់ថា កម្មាភិបាលថ្នាក់ក្រោមកម្របានជួបមុខ នួន ជា ណាស់ លើកលែងតែមានការប្រជុំធំៗ ដែលបក្សអនុញ្ញាតឲ្យថ្នាក់ក្រោមចូលរួម ។ ចំពោះការចូលរួមនៅក្នុងវគ្គប្រជុំនៃរបបកម្ពុជាប្រជាធិបតេយ្យ ខ្លួនបានចូលរួមប្រជុំចំនួនពីរលើក នៅស្រុកលង្វែក និងខេត្តកំពង់ស្ពឺ ។ កិច្ចប្រជុំនៅខេត្តកំពង់ស្ពឺ មានរយៈពេល១០ថ្ងៃ ដោយមានមេដឹកនាំចូលរួមដូចជា ប៉ុល ពត, តាសុី និង តាប៉ាល់ ប៉ុន្តែមិនឃើញ នួន ជា ឡើយ ។

បន្ទាប់ពីមេធាវីជាតិបញ្ចប់សំណួររបស់ខ្លួន មេធាវីអន្តរជាតិ អេនខ្វេ អ៊ីទូហ៊្សី បានបន្តសំណួរទាក់ទងនឹងតួនាទី និងកាតព្វកិច្ចសាក្សី ។ សាក្សីបញ្ជាក់ថា នៅឆ្នាំ១៩៧១ ខ្លួនធ្វើជាយោធាសាមញ្ញ បន្ទាប់មកក្លាយជាប្រធានក្រុមនៅឆ្នាំ១៩៧២ ។ នៅឆ្នាំ១៩៧៣ ខ្លួនក្លាយជាប្រធានវរៈសេនាតូច រហូតដល់ឆ្នាំ១៩៧៥ បានក្លាយជាប្រធានវរៈសេនាធំ ហើយបានបំពេញតួនាទីសំខាន់ក្នុងការរំដោះយកភ្នំពេញ ។ នៅឆ្នាំ១៩៧៦ សាក្សីបានទទួលមុខងារជាប្រធានកងពលតូច និងអនុប្រធានកងពល៧៦ ។ សាក្សីបានផ្ដល់ហេតុផលថា មូលហេតុដែលខ្លួនឡើងឋានៈនេះ មិនមែនជារឿងងាយនោះទេ ។ ខ្លួនបានរងរបួសជាច្រើនកន្លែង ទើបអាចក្លាយអនុបញ្ជាការកងពលនៅឆ្នាំ១៩៧៥-១៩៧៦ ដោយទទួលខុសត្រូវនៅខេត្តកោះកុង ។ មេធាវីបានសួររំឭកពីអត្តសញ្ញាណ មាស មុត និង ស៊ូ ម៉េត ។ សាក្សីបញ្ជាក់ថា បើប្រៀបធៀបទៅនឹងឋានៈរបស់ មាស មុត ខ្លួនមានឋានៈទាបជាងឆ្ងាយណាស់ ព្រោះ មាស មុត គ្រប់គ្រងខាងកងពល ហើយទទួលខុសត្រូវទាំងកប៉ាល់ និងរបស់របរជាច្រើនទៀត ។ ចំពោះ តាម៉ុក សាក្សីបានស្គាល់តាំងពីនៅក្នុងព្រៃ ហើយ តាម៉ុក បានជ្រើសរើសខ្លួនឲ្យធ្វើកងការពារ ។

បន្ទាប់មក មេធាវីបានស្នើឲ្យ មាស វឿន បញ្ចេញយោបល់ ឬការយល់ដឹងផ្ទាល់ខ្លួនចំពោះទំនាក់ទំនងរបស់គណៈមជ្ឈិមជាមួយ មាស មុត និង តាម៉ុក ពាក់ព័ន្ធនឹងការសម្លាប់កម្មាភិបាលរបស់ខ្លួន ។ ភ្លាមៗ នោះអង្គជំនុំជម្រះមិនបានអនុញ្ញាតឲ្យសាក្សីឆ្លើយតបនឹងសំណួរឡើយ ដោយសំអាងលើហេតុផលថា គ្មានឯកសារមូលដ្ឋានក្នុងការសាកសួរ ។ បន្ទាប់មក មេធាវី អ៊ីទូហ៊្សី បានផ្លាស់ប្ដូរប្រធានបទ ដោយចោទសួរអំពីសាក្សីម្នាក់ឈ្មោះ រចឹម គុន ហៅ



យុទ្ធជនខ្មែរក្រហមនៅសមរភូមិ
(ប្រភព ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)

ជាម ដែលធ្លាប់មកផ្ដល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ ។ សាក្សីមិនច្បាស់ថា ជាម ជាបុគ្គលណាមួយនោះទេ ដោយសារមនុស្សដែលខ្លួនស្គាល់ គឺមានឈ្មោះ ជាម ជាច្រើននាក់ ។

### ៩.២) ក្រុមមេធាវីការពារក្តី អៀង សារី

ម៉ៃឃើល កាណាវ៉ាស មេធាវីអន្តរជាតិការពារក្តី អៀង សារី បានចាប់ផ្តើមសំណួរទាក់ទងនឹងផ្នែកនីតិវិធីដែលសហចៅក្រមស៊ើបអង្កេតបានអនុវត្តលើការសម្ភាសន៍សាក្សី មាស វឿន ។ មេធាវីបានសួរទាក់ទងនឹងរយៈពេលចុះទៅសម្ភាសសាក្សីដោយសហចៅក្រមស៊ើបអង្កេត ដែលថាក្នុងជំនួបរវាងចៅក្រមស៊ើបសួរ និងសាក្សីប្រហែល៧ម៉ោង ប៉ុន្តែរយៈពេលថតសម្លេងមានប្រហែលពីរម៉ោងតែប៉ុណ្ណោះ ។ មេធាវីបានសួរអំពីរយៈពេលផ្សេងទៀត ដែលហេតុអ្វីបានជាពុំមានការថតសម្លេង? សំណួរ

នេះត្រូវបានជំទាស់ពីភាគីសហព្រះរាជអាជ្ញា ហើយអង្គជំនុំជម្រះ មិនអនុញ្ញាតឲ្យសាក្សីឆ្លើយតបនឹងសំណួរនេះឡើយ ។ បន្ទាប់មក លោកមេធាវីព្យាយាមសួរសំណួរម្តងហើយម្តងទៀត ទាក់ទងនឹង កិច្ចស៊ើបសួររបស់សហចៅក្រមស៊ើបអង្កេត ប៉ុន្តែសំណួរទាំង នោះនៅតែត្រូវបានជំទាស់ពីសហព្រះរាជអាជ្ញា ។ អង្គជំនុំជម្រះ បានរំឭកដល់មេធាវីថា ការសួរដេញដោលក្នុងបំណងសំដៅ មោឃៈកិច្ចដំណើរការនីតិវិធី ដែលធ្វើឡើងដោយសហចៅក្រម ស៊ើបអង្កេត គឺមិនស្របតាមវិធានផ្ទៃក្នុងក៏ដូចជាច្បាប់ស្តីពីនីតិវិធី ព្រហ្មទណ្ឌកម្ពុជានោះទេ ។

### ៤.ក) ក្រុមមេធាវីការពារក្តី ខៀវ សំផន

មេធាវីជាតិការពារក្តីជនជាប់ចោទ ខៀវ សំផនគឺមេធាវី គង់ សំអុន បានចាប់ផ្តើមសំណួរដំបូងទាក់ទងនឹងមូលហេតុដែលនាំ ឲ្យសាក្សីចូលរួមក្នុងចលនាតស៊ូ ។ សាក្សីបានបញ្ជាក់ថានៅឆ្នាំ ១៩៦៨ មានកម្មាភិបាលមកអប់រំពីស្ថានភាពប្រទេសជាតិ ដែល មិនទាន់ឯករាជ្យ ហើយការអប់រំណែនាំនេះធ្វើឡើងដោយស្ងាត់ ស្ងៀម និងមានពេលខ្លះធ្វើនៅពេលយប់ផង ។ នៅពេលយល់ដឹង ពីបញ្ហាទាំងនោះរួចហើយ សាក្សីមានភារកិច្ចណែនាំបុគ្គលផ្សេង ទៀត ដោយលាក់ការសម្ងាត់ ។ មេធាវីបានសួរនាំសាក្សីពាក់ព័ន្ធ នឹងទំនាក់ទំនងរវាងជនជាប់ចោទ ខៀវ សំផន និងសាក្សីនៅក្នុង ពេលដែលសាក្សីចូលរួមក្នុងចលនាតស៊ូ ដែលពេលនោះសាក្សី គឺជាកងការពារ ខៀវ សំផន ។ សាក្សីបញ្ជាក់ថា ខ្លួនបានជួប ខៀវ សំផន នៅពេលដែលខៀវ សំផន រត់ចូលព្រៃខណៈដែលសម្តេច នរោត្តម សីហនុ ប្រកាសឲ្យចាប់ខ្លួន ហ៊ូ នឹម, ហ៊ូ យន់ និង ខៀវ សំផន ព្រមទាំងប្រកាសផ្តល់ប្រាក់លើកទឹកចិត្តប្រហែល៧លាន ប្រសិនបើនរណាអាចចាប់បាន ។ សាក្សីបាននាំ ខៀវ សំផន ទៅលាក់ខ្លួននៅក្នុងព្រៃ ដើម្បីកុំឲ្យខ្មាំងរកឃើញ ដោយគោរពតាម បញ្ជារបស់តាម៉ុក និងតាមឿន ។ មេធាវីបានសួររកមូលហេតុ ដែលសាក្សីមិនជម្រាបពីវត្តមានរបស់ ខៀវ សំផន នៅក្នុងព្រៃ ។ សាក្សីបានលើកឡើងថា នៅពេលនោះស្ថានភាពមានការតឹងតែង ណាស់ និងមានការស៊ើបអង្កេត បើកាលណាខ្លួនជូនដំណឹងនោះ នឹងមានការចោទប្រកាន់ពីហេតុផលនយោបាយ ដូច្នេះខ្លួនមិន ហ៊ានប្រាប់ពីរឿងនេះទេ ។ សាក្សីបានបន្ថែមទៀតថា ខ្លួនបានឮ ខៀវ សំផន និយាយនៅពេលចូលដល់ក្នុងព្រៃថា “ការណ៍សម្តេច រករឿង ហើយទាមទារតម្លៃខ្លួនគាត់ ឬក្បាលគាត់ហ្នឹង ហើយគាត់ ប្រាប់ថា មិនអីទេអ្ហា! មកដល់ព្រៃហើយ” ។ ចំពោះរយៈពេល ក្រោយរដ្ឋប្រហារ សាក្សីមិនបានជួប ខៀវ សំផន ទៀតទេ ដោយសារខ្លួនចូលបម្រើកងទ័ព ។ សាក្សីដឹងថា ខៀវ សំផន ជាប្រធានរណសិរ្សរួបរួមជាតិកម្ពុជា ដែលជាស្ថាប័នប្រមូល កម្លាំងទាំងអស់ដើម្បីសង្គ្រោះជាតិ ។ នៅឆ្នាំ១៩៧០ អ្នកចូលរួម ជាមួយខ្មែរនោះគឺវៀតណាម ។

មេធាវីអន្តរជាតិ អង់តា ហ្គីសសេ បានសួរបន្តទាក់ទង នឹងរយៈពេលក្រោយរដ្ឋប្រហារ ឆ្នាំ១៩៧០ ដែលប្រជាជន បានរត់ចូលព្រៃម៉ាគី ។ សាក្សីបានឆ្លើយថា ដើម្បីឲ្យសម្តេចព្រះ នរោត្តម សីហនុ អាចចូលស្រុកបានព្រះអង្គបានអំពាវនាវឲ្យ ប្រជាជនរត់ចូលព្រៃ ។ មេធាវីបានសួរនូវសំណួរមួយចំនួន ដើម្បី ឲ្យសាក្សីឆ្លើយបំភ្លឺឡើងវិញនូវចំណុចដែលព្រះរាជអាជ្ញា និង ចៅក្រម ហ្សង់ម៉ាក ឡាវីញ បានសួរកន្លងមក ។ មានចំណុច មួយចំនួនតូចដែលសាក្សីបានឆ្លើយកែប្រែនូវចម្លើយដែលខ្លួនបាន ផ្តល់ជូនអង្គជំនុំជម្រះកាលពីពេលមុន ។ ចំណុចដែលសាក្សីធ្វើការ កែប្រែនោះទាក់ទងនឹងពេលវេលាដែលខ្លួនបានជួបតាសឿង ។ សាក្សីបានកែប្រែថា មិនដូចចម្លើយដែលខ្លួនឆ្លើយនៅពេលមុន នោះទេ ការពិតខ្លួនបានជួន តាសឿង ចំនួន បីដងរួចមកហើយ មិនមែនពីរដងនោះទេ វាអាចមកពីខ្លួនមានការភ័ន្តច្រឡំនូវចំណុច ខ្លះ ។ ជាថ្មីម្តងទៀត ឆ្លើយតបនឹងសំណួររបស់មេធាវីអន្តរជាតិ ការពារក្តី ខៀវ សំផន សាក្សីបានជម្រាបពីការបង្ហាញដែនទីរបស់ ប៉ុល ពត និងសភាពការណ៍ខ្មាំងដែល ប៉ុល ពត បានប្រាប់ឲ្យខ្លួន ទៅខេត្តព្រះវិហារ ដើម្បីពិនិត្យមើលថាតើមានមនុស្សបាត់ខ្លួន និងអត់ឃ្លាន ឬយ៉ាងណា ។ តាមបញ្ជារបស់ ប៉ុល ពត សាក្សីបាន ទទួលបន្ទុកការស៊ើបអង្កេតនៅព្រះវិហារ ។ សាក្សី ត្រូវបាន តាសឿង ប្រាប់ឲ្យទៅទទួលខុសត្រូវនៅតំបន់១០៣ នៅខែសីហា ឆ្នាំ១៩៧៨ ដោយពុំមានប្រាប់ពីមុខងាររបស់ខ្លួនឲ្យបានច្បាស់ លាស់នោះឡើយ ។ ដូច្នេះនៅពេលទៅធ្វើការនៅទីនោះ លោក មិនបានប្រកាសប្រាប់ពីសមាសភាពខ្លួនជានរណានោះទេ រហូត ដល់វៀតណាមវាយចូលទឹកដីខ្មែរ ។

# សវនាការលើការអានបណ្តាកថាខ័ណ្ឌដែលពាក់ព័ន្ធនឹងអង្គហេតុនៃការសម្លាប់អតីតទាហាន និងមន្ត្រីរដ្ឋការរបប លន់ នល់ នៅទួលពោធិ៍ជ្រៃ

*ថ្ងៃទី៩ ខែតុលា ឆ្នាំ២០១២*

ក្លាម១បន្ទាប់ពីបញ្ចប់សវនការសួរដេញដោលសាក្សី មាស វឿន នៅរសៀលថ្ងៃទី៩ ខែតុលា ឆ្នាំ ២០១២ អង្គជំនុំជម្រះបានបន្តសវនាការមួយទៀត ស្តីពីការអាននូវបណ្តាកថាខ័ណ្ឌដែលពាក់ព័ន្ធនឹងអង្គហេតុនៃការសម្លាប់អតីតទាហាន និងមន្ត្រីរដ្ឋការនៃរបប លន់ នល់ នៅទួលពោធិ៍ជ្រៃ និងកថាខ័ណ្ឌមួយចំនួនទៀតដែលពាក់ព័ន្ធ ដែលមាននៅក្នុងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេត ។ បណ្តាអង្គហេតុទាំងនោះ គឺត្រូវបានអានដោយក្រឡាបញ្ជី សែ កុលវុឌ្ឍី ចាប់ពីកថាខ័ណ្ឌ២០៥ ដល់ ២០៩ *(វិធានផ្សេងៗដែលបានធ្វើឡើងប្រឆាំងនឹងក្រុមជាក់លាក់នានា និងការបរិច្ចេទ និងការចូលរួម)* កថាខ័ណ្ឌ៦៩៨ ដល់៧១១ *(កន្លែងសម្លាប់មនុស្សនៅទួលពោធិ៍ជ្រៃ រួមមានទីតាំង និងការបង្កើត ដំណើរការប្រព្រឹត្តទៅរួមមាន រចនាសម្ព័ន្ធគ្រប់គ្រង និងបុគ្គលិក ការចាប់ ការបញ្ជូនខ្លួន និងការសម្លាប់នៅទួលពោធិ៍ជ្រៃ អតីតមន្ត្រី និងអ្នករដ្ឋការនៃរបប លន់ នល់)* កថាខ័ណ្ឌ៩៧៥ ដល់៩៧៧ *(ក្រុមមនុស្សជាក់លាក់ផ្សេងៗ ការប្រព្រឹត្តលើអតីតមន្ត្រីរដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ)* កថាខ័ណ្ឌ១១០៥ ដល់ ១១១៣ *(ក្រុមមនុស្សជាក់លាក់ ការប្រព្រឹត្តលើអតីតមន្ត្រីរដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ)* និងពីកថាខ័ណ្ឌ១១៩១ ដល់ ១១៩៣ *(ក្រុមមនុស្សជាក់លាក់ផ្សេងៗ និងការប្រព្រឹត្តលើអតីតអ្នករដ្ឋការរបបសាធារណរដ្ឋខ្មែរ)* ។

ប្រធានអង្គជំនុំជម្រះ លោកចៅក្រម និល ណុន បានជម្រាបភាគី និងសាធារណជនដែលបានចូលរួមនៅក្នុងសវនាការនេះថា បណ្តាអង្គហេតុដែលបង្ហាញនៅក្នុងបណ្តាកថាខ័ណ្ឌពាក់ព័ន្ធនឹងការសម្លាប់អតីតទាហាន និងមន្ត្រីរដ្ឋការនៃរបប លន់ នល់ នៅទួលពោធិ៍ជ្រៃ និងកថាខ័ណ្ឌពាក់ព័ន្ធខាងលើអង្គជំនុំជម្រះនឹងសម្រេចដាក់បញ្ចូលក្នុងផ្នែកមួយនៃអង្គហេតុដែលអង្គជំនុំជម្រះលើកយកមកធ្វើសវនាការវគ្គទី៣ នៃសំណុំរឿង០០២/០១ ។ លោកចៅក្រមបានបញ្ជាក់ថា ការធ្វើដូច្នេះ គឺដើម្បីសម្រួលដល់ការរៀបចំនូវកាលវិភាគសម្រាប់រក្សាកិច្ចដំណើរការនាពេលអនាគត ។

**បញ្ជាក់ ៖** មុនពេលប្រកាសផ្អាកនីតិវិធីសវនាការ ចៅក្រម និល ណុល តំណាងឲ្យអង្គជំនុំជម្រះទាំងមូលបានចេញសេចក្តីសម្រេចមួយទាក់ទងនឹងអាកប្បកិរិយារបស់មេធាវីអន្តរជាតិការពារក្តីជនជាប់ចោទ នួន ជា គឺមេធាវី អេនឌ្រូ អ៊ីណូហ៊្វ ។ នៅក្នុងការសេចក្តីសម្រេចនោះ អង្គជំនុំជម្រះបានកត់សម្គាល់ឃើញថា អាកប្បកិរិយា និងការកត់សម្គាល់របស់មេធាវី អ៊ីណូហ៊្វ ដែលបានបង្ហាញនៅមុនពេលការឈប់សម្រាកនៃសវនការក្នុងពេលថ្ងៃត្រង់គឺជាការដកស្រង់ចេញពីបទភ្លេងរបស់ រ៉ូជ្ជឺ និង ហែមមឺស្តែន ដែលជាកាយវិការមួយប្រមាថដល់អង្គជំនុំជម្រះ និងជាការមិនគោរពក្រមសីលធម៌វិជ្ជាជីវៈដែលមេធាវីត្រូវគោរព ។ ចៅក្រម និល ណុន បានបន្តទៀតថា អង្គជំនុំជម្រះនឹងបញ្ជូនពាក្យបណ្តឹងនេះទៅគណៈមេធាវីដែល មេធាវី អ៊ីណូហ៊្វ ជាសមាជិក និងស្នើឲ្យគណៈមេធាវីពិចារណាលើពាក្យបណ្តឹងនេះ រួមជាមួយនឹងការប្តឹងដែលបានចេញពីពេលមុនដែលអង្គជំនុំជម្រះបានសម្រេចចំពោះមេធាវីរូបនេះ ។

បន្ទាប់មក លោកប្រធានអង្គជំនុំជម្រះបានជូនដំណឹងដល់ភាគីទាំងអស់ថា អង្គជំនុំជម្រះនឹងចាប់ផ្តើមសវនាការស្តីពីការដាក់ឯកសាររបស់អង្គជំនុំជម្រះ ឬរបស់ភាគី ដែលជាការបញ្ចប់សវនាការវគ្គ២នៃសំណុំ រឿង០០២/០១ នៅថ្ងៃទី១០ ខែតុលា ឆ្នាំ២០១២ ។ ហើយនៅមុនពេលចាប់ផ្តើមនៃសវនាការនេះ អង្គជំនុំជម្រះនឹងផ្តល់ឱកាសជូនជនជាប់ចោទ នួន ជា ដើម្បីធ្វើការកត់សម្គាល់ ឬធ្វើសេចក្តីថ្លែងតបទៅនឹងបណ្តាកថាខ័ណ្ឌនៃអង្គហេតុចោទប្រកាន់ដែលមាននៅក្នុងដីកាដំណោះស្រាយ ។

# សវនាការលើការដាក់ឯកសារពាក់ព័ន្ធនឹងអង្គហេតុរចនាសម្ព័ន្ធរដ្ឋបាល នៃរបបកម្ពុជាប្រជាធិបតេយ្យ

## ថ្ងៃទី១០ និង១៨-១៩ ខែតុលា ឆ្នាំ២០១២

នៅថ្ងៃទី១០ ខែតុលា ឆ្នាំ២០១២ ដូចកាលវិភាគដែលបានគ្រោងទុក អង្គជំនុំជម្រះសាលាដំបូង បានបន្តកិច្ចដំណើរការនីតិវិធីសវនាការ ដោយផ្តល់វេទិកាជូនជនជាប់ចោទ នួន ជា ដើម្បីមានឱកាសធ្វើការកត់សម្គាល់ ឬធ្វើសេចក្តីថ្លែងការណ៍តបនឹងបណ្តាលក្ខខណ្ឌទាំងឡាយនៃដីកាដំណោះស្រាយ ដែលអង្គជំនុំជម្រះបានសម្រេចលើកយកមកធ្វើសវនាការវគ្គ៣ នៃសំណុំរឿង០០២/០១ ។ បន្ទាប់មក អង្គជំនុំជម្រះចាប់ផ្តើមសវនាការស្តីពីការដាក់ឯកសារដោយចៅក្រមជំនុំជម្រះ ឬភាគីដែលខ្លួនយល់ថាជាឯកសារពាក់ព័ន្ធបំផុតនឹងអង្គហេតុរចនាសម្ព័ន្ធរដ្ឋបាលនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ សវនាការនេះធ្វើឡើងក្នុងគោលបំណងដើម្បីអនុញ្ញាតឲ្យអង្គជំនុំជម្រះបានដឹងអំពីទំហំនៃឯកសារដាក់លាក់ ឯកសារដាក់បន្ទុក ឯកសារដោះបន្ទុក ដែលភាគីបានដាក់ ហើយពាក់ព័ន្ធនឹងរចនាសម្ព័ន្ធនៃរបបកម្ពុជាប្រជាធិបតេយ្យដែលត្រូវបានបញ្ចប់ ។

អង្គជំនុំជម្រះបានផ្តល់វេទិកាជូនសហព្រះរាជអាជ្ញាដើម្បីដាក់ និងបង្ហាញឯកសាររបស់ខ្លួននូវរយៈពេល១ថ្ងៃកន្លះ ហើយសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីមានពេលវេលាចំនួនកន្លះថ្ងៃ និងក្រុមមេធាវីការពារក្តីមានពេលវេលាចំនួន២ថ្ងៃ ។ ប៉ុន្តែដោយសារកិច្ចដំណើរការនីតិវិធីប្រព្រឹត្តទៅលឿនជាងការគ្រោងទុក សវនាការនេះបានបញ្ចប់ដោយចំណាយពេលត្រឹមតែ៣ថ្ងៃប៉ុណ្ណោះ គឺនៅថ្ងៃទី១០ ថ្ងៃទី១៨ និងថ្ងៃទី១៩ខែតុលា ឆ្នាំ២០១២ ។ នៅចន្លោះថ្ងៃទី១០ និង១៨ ខែតុលា ឆ្នាំ២០១២ អង្គជំនុំជម្រះបានផ្អាកមិនធ្វើសវនាការ ដោយសារមូលហេតុបុគ្គលិកខាងភាគីជាតិនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាត្រូវទៅពិនិត្យបញ្ជីឈ្មោះបោះឆ្នោត និងចំពេលនៃការឈប់សម្រាកក្នុងពិធីបុណ្យភ្ជុំបិណ្ឌ ។

ក្នុងអំឡុងពេលនៃសវនាការដាក់ឯកសារ សហព្រះរាជអាជ្ញាបានបង្ហាញនូវឯកសារជាច្រើនដែលពាក់ព័ន្ធនឹងរចនាសម្ព័ន្ធរដ្ឋបាល និងប្រព័ន្ធទំនាក់ទំនងនៃរបបកម្ពុជាប្រជាធិបតេយ្យរាប់ចាប់តាំងពីរចនា សម្ព័ន្ធថ្នាក់មជ្ឈិម ភូមិភាគ តំបន់ រហូតដល់ថ្នាក់ស្រុក ។ រីឯសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានបង្ហាញនូវខ្សែវីដេអូជាច្រើនទាក់ទងនឹងកិច្ចសម្ភាសន៍ជាមួយនឹងមេដឹកនាំខ្មែរក្រហម រួមមាន កិច្ច សម្ភាសន៍ជាមួយនឹង នួន ជា និង ខៀវ សំផន ជាដើម ។ ក្នុងចំណោមមេធាវីការពារក្តីជនជាប់ចោទទាំងបីក្រុម គឺមានតែក្រុមមេធាវីការពារក្តី នួន ជា ប៉ុណ្ណោះ ដែលបានបង្ហាញនូវឯកសាររបស់ខ្លួន ។ ក្រុមមេធាវីការពារក្តី អៀង សារី និង ខៀវ សំផន មិនបានដាក់ ឬបង្ហាញឯកសារនានា ដើម្បីដោះបន្ទុកក្តីរបស់ខ្លួនទាក់ទងនឹងរចនាសម្ព័ន្ធរដ្ឋបាលនៃរបបកម្ពុជាប្រជាធិបតេយ្យឡើយ ។



ជនជាប់ចោទ នួន ជា កំពុងអានសេចក្តីថ្លែងការណ៍លើកៅអីរាងរង្វង់ក្រចកសេះនៅក្នុងបន្ទប់សវនាការ
(ប្រភព : មជ្ឈមណ្ឌលឯកសារកម្ពុជា)

## ១) សេចក្តីថ្លែងការណ៍របស់ នួន ជា ឆ្លើយតបនឹងការចោទប្រកាន់នានានៃដីកាដំណោះស្រាយ

មុនពេលចាប់ផ្តើមនីតិវិធីសវនាការស្តីពីការដាក់ឯកសារពាក់ព័ន្ធនឹងរចនាសម្ព័ន្ធរដ្ឋបាលនៃរបបកម្ពុជាប្រជាធិបតេយ្យ អង្គជំនុំជម្រះសាលាដំបូងបានអនុញ្ញាតឲ្យជនជាប់ចោទ នួន ជា ឡើងថ្លែងដើម្បីឆ្លើយតបនឹងការចោទប្រកាន់ទាំងឡាយចំពោះខ្លួន ដែលក្រឡាបញ្ជីបានអានចេញពីដីកាដំណោះស្រាយកាលពីថ្ងៃទី៩ ខែតុលា ឆ្នាំ២០១២ ។

សេចក្តីថ្លែងការណ៍នេះ នួន ជា បានចំណាយពេលប្រមាណ ៣នាទី ដើម្បីអាននៅចំពោះមុខអង្គជំនុំជម្រះ ភាគី និងសាធារណជនដែលបានចូលរួមនៅក្នុងសាលសវនាការ ។

សេចក្តីថ្លែងការណ៍នេះមានអត្ថន័យដូចតទៅ ៖

*«គោរពលោកប្រធាន! ដោយសុខភាពខ្ញុំមិនស្រួល ខ្ញុំសូមប្រើសិទ្ធិនៅស្ងៀមមិនឆ្លើយ ។*

*គោរពលោកប្រធាន! បន្ទាប់ពីបានស្តាប់ការអានដីកាដំណោះស្រាយដែលចោទប្រកាន់មកលើរូបខ្ញុំ ។ ខ្ញុំសូមបំភ្លឺនូវចំណុចមួយចំនួនអំពីតួនាទីរបស់ខ្ញុំ ជាពិសេសនៅក្នុងកថាខ័ណ្ឌ ១២១, ១២២, ១២៣, ៨៧៣ ដល់៨៨១ និងកថាខ័ណ្ឌទាំងឡាយណាដែលចោទប្រកាន់ពីតួនាទីរបស់ខ្ញុំក្នុងគណៈកម្មាធិការយោធា និងមន្ទីរស-២១ និងបណ្តាបញ្ហាសន្តិសុខ ។*

*ខ្ញុំសូមបដិសេធថា ខ្ញុំមិនដែលជាសមាជិកក្នុងគណៈកម្មាធិការនេះទេ ។ ដូចគ្នានេះដែរ ខ្ញុំក៏ពុំមានតួនាទីអ្វីគ្រប់គ្រងលើមន្ទីរស-២១ នោះទេ ។ សូមគោរពលោកប្រធាន ។ ចប់ ។»*

## ២) ការដាក់បង្ហាញឯកសារចំពោះមុខអង្គជំនុំជម្រះដោយសហព្រះរាជអាជ្ញា

តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ខេល លីសាក់ បានចាប់ផ្តើមដោយបញ្ជាក់លម្អិតអំពីឯកសារ ដែលការិយាល័យសហព្រះរាជអាជ្ញានឹងដាក់បង្ហាញឯកសារដែលពាក់ព័ន្ធនឹងការចោទប្រកាន់សំខាន់ៗដែលមាននៅក្នុងដីកាដំណោះស្រាយ ទាក់ទងនឹងរចនាសម្ព័ន្ធរដ្ឋបាល និងប្រព័ន្ធទំនាក់ទំនងការងារនៃរបបកម្ពុជាប្រជាធិបតេយ្យដោយធ្វើការបែងចែកជា៣ផ្នែក ។

ផ្នែកទី១ គឺផ្តោតលើតួនាទីរបស់គណៈមជ្ឈិម និងគណៈអចិន្ត្រៃយ៍នៃបក្សកុម្មុយនីស្តកម្ពុជា រួមទាំងសិទ្ធិអំណាចក្នុងការធ្វើសេចក្តីសម្រេច និងការទំនាក់ទំនងនៅក្នុងជួរបក្ស ក៏ដូចជាទំនាក់ទំនងផ្សេងៗក្នុងចំណោមអង្គការដទៃទៀតក្នុងទម្រង់របស់បក្សកុម្មុយនីស្តកម្ពុជា ។

ផ្នែកទី២ គឺផ្តោតជាសំខាន់លើឯកសារពាក់ព័ន្ធនឹងរចនាសម្ព័ន្ធរបស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ រួមទាំងមុខងារ និងប្រតិបត្តិការរបស់ក្រសួងចំនួន៤ រួមមានក្រសួងការបរទេស ក្រសួងពាណិជ្ជកម្ម ក្រសួងឃោសនាការ និងក្រសួងសង្គមកិច្ច ។ និងបង្ហាញថា តើក្រសួងទាំងបួននេះរាយការណ៍ជូនទៅដល់ថ្នាក់ដឹកនាំបក្ស ក៏ដូចជាការអនុវត្តគោលនយោបាយបក្សដោយរបៀបណា ។

ផ្នែកទី៣ គឺផ្តោតលើឯកសារទាក់ទងនឹងប្រព័ន្ធទំនាក់ទំនងដែលនឹងបង្ហាញអំពីចំណុចលម្អិតនៃសារទូរលេខ របាយការណ៍ដែលផ្ញើចេញពីថ្នាក់ភូមិភាគ ថ្នាក់តំបន់ ទៅថ្នាក់លើ និងរបាយការណ៍របស់រដ្ឋាភិបាលនៃរបបកម្ពុជាប្រជាធិបតេយ្យ ដើម្បីស្វែងយល់អំពីគណៈកម្មាធិការមជ្ឈិមមួយនេះ ។ បន្ថែមពីលើនេះ សហព្រះរាជអាជ្ញានឹងលើកបង្ហាញឧទាហរណ៍មួយចំនួនអំពីរបាយការណ៍ដែលផ្ញើចេញពីថ្នាក់ឃុំ ថ្នាក់ស្រុក ទៅថ្នាក់តំបន់ ដើម្បីបង្ហាញថា តើរបាយការណ៍ទាំងនោះត្រូវបានផ្ញើជូនទៅថ្នាក់លើ និងថ្នាក់ខ្ពស់បំផុតនៅភ្នំពេញដោយរបៀបណា និងថា តើគោលនយោបាយត្រូវបានផ្សព្វផ្សាយពីមជ្ឈិមទៅមូលដ្ឋានដើម្បីអនុវត្តដោយរបៀបណា ។

បន្ទាប់មកតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ខេល លីសាក់ បានផ្ទេរវេទិកាជូនសហភាគីរបស់ខ្លួន គឺតំណាងសហព្រះរាជអាជ្ញាជាតិ សេង ប៊ុនឃាង ដើម្បីបង្ហាញឯកសារលម្អិត ។

តំណាងសហព្រះរាជអាជ្ញាជាតិ សេង ប៊ុនឃាង បានចាប់ផ្តើមការបង្ហាញផ្នែកទី១ ស្តីអំពីឯកសារទាក់ទងនឹងតួនាទីរបស់គណៈមជ្ឈិម និងគណៈអចិន្ត្រៃយ៍នៃបក្សកុម្មុយនីស្តកម្ពុជា ។ នៅក្នុងការដាក់បង្ហាញឯកសារនេះ លោកតំណាងសហព្រះរាជអាជ្ញាបានលើកយកមាត្រាមួយចំនួននៃឯកសារស្តីពី *«លក្ខន្តិកបក្ស កុម្មុយនីស្តកម្ពុជា»* ដើម្បីបង្ហាញអំពីតួនាទី ភារកិច្ច និងសិទ្ធិអំណាចរបស់គណៈកម្មាធិការមជ្ឈិមនៃបក្សកុម្មុយនីស្តកម្ពុជា ។

បន្ទាប់មកតំណាងសហព្រះរាជអាជ្ញា ប៊ុនឃាង បានលើកយកអំពីកំណត់ហេតុនៃការសួរចម្លើយជនជាប់ចោទ ខៀវ សំផន ដោយសហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០៧ ដែលមានលេខឯកសារ E3/27 ។ នៅក្នុងកំណត់ហេតុសួរចម្លើយនោះ លោកតំណាងសហព្រះរាជអាជ្ញាបានអះអាងថា ខៀវ សំផន បានឆ្លើយទាក់ទងនឹងគណៈកម្មាធិការមជ្ឈិម និងគណៈកម្មាធិការអចិន្ត្រៃយ៍របស់បក្សកុម្មុយ នីស្តកម្ពុជាថា ៖

«កម្ពុជាប្រជាធិបតេយ្យ គឺជារបបកុម្មុយនីស្តដែលមានបក្សជាអ្នកដឹកនាំរដ្ឋ ។ ជាគោលការណ៍ អង្គការដែលសំខាន់ជាងគេ គឺគណៈកម្មាធិការមជ្ឈិម ។ ប៉ុន្តែជាក់ស្តែង គឺគណៈកម្មាធិការអចិន្ត្រៃយ៍ ហើយថា ទាំងមាគ៌ានយោបាយ និងការដាក់ចេញ សេចក្តីសម្រេចត្រូវបានធ្វើឡើងដោយគណៈកម្មាធិការអចិន្ត្រៃយ៍» ។

ខៀវ សំផន បានលើកឡើងបន្តទៀតថា «គណៈកម្មាធិការមជ្ឈិម គឺជួបប្រជុំជារៀងរាល់៦ខែម្តង ចាប់ពី ឆ្នាំ១៩៧០មក ។ គណៈកម្មាធិការអចិន្ត្រៃយ៍ជួបប្រជុំជាទៀងទាត់ប្រហែល៧ ទៅ ១០ថ្ងៃម្តង ឬញឹកញាប់ជាងនេះក្នុងករណីបន្ទាន់ ។ គណៈកម្មាធិការអចិន្ត្រៃយ៍មានសមាជិក៧រូប គឺ ប៉ុល ពត, នួន ជា, វន វេត, សោ ភឹម, តាម៉ុក, សុន សេន និង អៀង សារី ។ ខ្ញុំសូមបញ្ជាក់ថា គណៈកម្មាធិការនេះមិនចាំបាច់ មានសមាជិកចូលរួមប្រជុំគ្រប់គ្នានោះទេ ។ ចំណែកឯគណៈកម្មាធិការមជ្ឈិមមានសមាជិកប្រមាណ ៣០នាក់ ប៉ុន្តែខ្ញុំមិនចាំឈ្មោះអស់នោះទេ ។ ខ្ញុំចាំដូចជា មាស មុត កូនប្រសាររបស់ តាម៉ុក ដែលជាលេខានៃកងពលមួយដែលឈរជើងនៅកំពត ហើយក្រោយឆ្នាំ១៩៧៥ បានបញ្ជូនទៅជាត្រូវបានប្តូរទៅជាកង ទ័ពជើងទឹក និង សឿ វ៉ាស៊ី ហៅ ឌឿន ជាប្រធានមន្ទីរ៨៧០ ឬដងដែរ ។ កុយ ធួន, កែ ពក ។

ខ្ញុំខ្លួនឯងក៏ជាសមាជិកនៃគណៈកម្មាធិការមជ្ឈិម ។ ជាដំបូងសមាជិកត្រៀមនៅឆ្នាំ១៩៧១ និងក្លាយជាសមាជិកពេញសិទ្ធិនៅឆ្នាំ១៩៧៦ ។»

តំណាងសហព្រះរាជអាជ្ញា សេង ប៊ុនឃាង បានបន្តលើកយកឯកសារជាច្រើនទៀតមកដាក់បង្ហាញជូនអង្គជំនុំជម្រះ ដូចជា ឯកសារកំណត់ហេតុនៃការសួរចម្លើយជនជាប់ចោទ ខៀវ សំផន ដោយសហចៅក្រមស៊ើបអង្កេតចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៧ ដែលរៀបរាប់អំពីមន្ទីរក-១ និងមន្ទីរក-៣ ដែល ជាកន្លែងធ្វើការ និងកន្លែងស្នាក់នៅរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ ។ ឯកសារស្តីពីបទសម្ភាសន៍ជាមួយ អៀង សារី កាលពីថ្ងៃទី១៧ ខែធ្នូ ឆ្នាំ ១៩៩៦ ដែលបញ្ជាក់អំពីសមាសភាពរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ និងវត្តមានរបស់ ខៀវ សំផន នៅក្នុងកិច្ចប្រជុំទាំងនោះ ។ ឯកសារកំណត់ហេតុនៃការសួរចម្លើយរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត ដែលបានធ្វើជាមួយនឹង ខៀវ សំផន នៅថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ ២០០៧ ។ នៅក្នុងកំណត់ហេតុសួរចម្លើយនោះ ខៀវ សំផន បានទទួលស្គាល់ថា «វាជាការពិត ដែលថា ខ្ញុំបានចូលរួមក្នុងកិច្ចប្រជុំដែលមានការពង្រីកនៃគណៈកម្មា-ធិការអចិន្ត្រៃយ៍ ដែលនៅក្នុងនោះគេពិភាក្សាតែបញ្ហាទូទៅប៉ុណ្ណោះ ដូចជា ការការពារជាតិ ការកសាងជាតិ វៀតណាម ឬការលាលែងរបស់ នរោត្តម សីហនុ» ។ ឯកសារ «សេចក្តីសម្រេចគណៈមជ្ឈិមអំពីបញ្ហាផ្សេងៗមួយចំនួន» ចុះថ្ងៃទី៣០ ខែមិនា ឆ្នាំ១៩៧៦ ដែលមាននិយាយអំពីសិទ្ធិសម្រេចកម្ទេចក្នុងជួរ និងក្រៅជួរ ។ លោកតំណាងសហព្រះរាជអាជ្ញា ក៏បានបង្ហាញអំពីឯកសារស្តីពីកំណត់ហេតុកិច្ចប្រជុំរបស់គណៈអចិន្ត្រៃយ៍ និងគណៈមជ្ឈិមជាច្រើនផ្សេងទៀតដែរ ។ បន្ទាប់មកតំណាងសហ ព្រះរាជអាជ្ញាជាតិ សេង ប៊ុនឃាង បញ្ចប់ការដាក់បង្ហាញឯកសាររបស់ខ្លួន និងបានប្រគល់វេទិកាបន្តជូនសហភាគីរបស់ខ្លួន គឺតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ឌេល លីសាក់ ដើម្បីបន្តដាក់បង្ហាញឯកសារទាក់ទងនឹងផ្នែកទីមួយដដែល ។

តំណាសហព្រះរាជអាជ្ញា ឌេល លីសាក់ បានលើកឡើងថា មធ្យោបាយដែលគណៈអចិន្ត្រៃយ៍ និងគណៈមជ្ឈិមផ្សព្វផ្សាយមាគ៌ាបក្ស និងការណែនាំរបស់ខ្លួនទៅអង្គការតំបន់ គឺធ្វើឡើងតាមរយៈសុន្ទរកថា ឬសន្និបាតនៅតាមភូមិភាគ ។ ក្រោយមកទៀត គឺតាមរយៈទស្សនាវដ្តីទង់បដិវត្តដែលបោះពុម្ពផ្សាយ ដោយរបបកម្ពុជាប្រជាធិបតេយ្យ ។ លោកតំណាងសហព្រះរាជអាជាបានបន្តដាក់បង្ហាញឯកសារស្តីពីទស្សនាវដ្តីទង់បដិវត្តជាច្រើនច្បាប់ ដែលចុះផ្សាយក្នុងរយៈកាលផ្សេងៗគ្នា រួមមានទស្សនាវដ្តី

ដែលចុះផ្សាយ នៅខែមិថុនា ឆ្នាំ១៩៧៦, ខែសីហា ឆ្នាំ ១៩៧៧, ទស្សនាវដ្តីលេខពិសេសចុះផ្សាយថ្ងៃទី២៥ ខែកក្កដា ឆ្នាំ១៩៧៧ ។ល ។ ទាក់ទងនឹងការផ្សព្វផ្សាយពីគោលនយោបាយរបស់បក្សដល់កម្មាភិបាលថ្នាក់ក្រោម តំណាងសហព្រះរាជអាជ្ញា ទាក់ទងនឹងខ្លាំងរបស់របបកម្ពុជាប្រជាធិបតេយ្យ ។

បន្ទាប់មក លោកតំណាងសហព្រះរាជអាជ្ញាបានបន្តធ្វើការបង្ហាញអំពីឯកសារដែលបក្សកុម្មុយនីស្តកម្ពុជាបានបញ្ជូនផ្សព្វផ្សាយអំពីការណែនាំសារចរ និងមាគ៌ារបស់ខ្លួន ។ ឯកសារ



ផែនទីកម្ពុជាប្រជាធិបតេយ្យ បោះពុម្ពដោយក្រសួងសិក្សាធិការក្នុងឆ្នាំ១៩៧៦ ប្រភព ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)

លីសាក់ បានលើកយកឯកសារសុន្ទរកថារបស់ ប៉ុល ពត ដែលជាលេខាបក្សកុម្មុយនីស្តកម្ពុជាយកមកធ្វើការបង្ហាញ ។ ក្នុងសុន្ទរកថាទាំងអស់នោះ ប៉ុល ពត បានថ្លែងប្រាប់កម្មាភិបាលរបស់ខ្លួនអំពីគោលដៅនយោបាយ និងគោលដៅរបស់បក្ស សារាចរនោះត្រូវបានផ្សព្វផ្សាយនៅក្នុងខែធ្នូ ឆ្នាំ១៩៧៥ មានចំណងជើងថា "ការពិនិត្យទៅលើការគ្រប់គ្រង និងការអនុវត្តមាគ៌ានយោបាយ ស្តារសេដ្ឋកិច្ច និងរៀបចំប្រទេសគ្រប់ផ្នែក" ។ ឯកសារដែលជាសេចក្តីណែនាំរបស់គណៈមជ្ឈិមពាក់ព័ន្ធនឹងការ

ប្រើពាក្យ "អគ្គការ" និង "បក្ស" ឯកសារដែលចេញដោយគណៈ ៨៧០ នៅខែមីនា ឆ្នាំ១៩៧៨ និងឯកសារទាក់ទងនឹងសេចក្តីណែនាំរបស់គណៈមជ្ឈិមជាច្រើនទៀត ។

ក្រៅពីឯកសារទាក់ទងនឹងសារាចរ និងសេចក្តីណែនាំរបស់បក្សកុម្មុយនីស្តកម្ពុជា តំណាងសហព្រះរាជអាជ្ញា ឌេល លីសាក់ បានបន្តបង្ហាញឯកសារទាក់ទងនឹងសារទូរលេខដែលផ្ញើចេញពីមន្ទីរ៨៧០ និងរបាយការណ៍ដែលផ្ញើចេញពីតំបន់២២ ទៅភូមិភាគបូព៌ា ដែលរៀបរាប់អំពីសភាពការណ៍ខ្លាំងនៅក្នុងស្រុកមុខកំពូល រួមជាមួយនឹងសារទូរលេខទាក់ទងដទៃផ្សេងទៀត ។

តំណាងសហព្រះរាជអាជ្ញាអន្តរជាតិមួយរូបទៀត វាំងសង់ ដែលសរសេរថា ៖

"រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជាហ្រ្វុង ស្ថិតនៅក្រោមការគាំទ្ររបស់រណសិរ្សរួបរួមជាតិកម្ពុជា ដែលបានបង្កើតឡើងនៅថ្ងៃទី៥ ខែឧសភា ឆ្នាំ១៩៧០ ។ រដ្ឋាភិបាលនេះ គឺជារដ្ឋាភិបាលស្របច្បាប់តែមួយគត់របស់ប្រទេសកម្ពុជា ។ សមាសភាពរបស់រដ្ឋាភិបាលនេះ គឺមានដូចតទៅ ៖

ទី១) ប៉ែន នុត នាយករដ្ឋមន្ត្រី ទី២) ខៀវ សំផន ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងការពារជាតិ ទី៣) សារិន ឆាក រដ្ឋមន្ត្រីក្រសួងការបរទេស ទី៤) ហ៊ូ នឹម រដ្ឋមន្ត្រីក្រសួងឃោសនាការ និងព័ត៌មាន ។"



មេដឹកនាំខ្មែរក្រហមពេលធ្វើដំណើរតាមរទេះភ្លើង (ប្រភព ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)

ដឺវ៉ាល់ ដេស្មាឯល បានបន្តដាក់បង្ហាញឯកសារបន្ថែមទាក់ទងនឹងរចនាសម្ព័ន្ធ និងប្រព័ន្ធទំនាក់ទំនងការងារនៅក្នុងរដ្ឋាភិបាលនៃរបបកម្ពុជាប្រជាធិបតេយ្យ ដែលមានប្រមូលផ្តុំទៅដោយក្រសួងជាច្រើន ។ សហព្រះរាជអាជ្ញា បានបញ្ជាក់អំពីឯកសារ ដែលត្រូវលើកយកមកបង្ហាញ ដែលនៅក្នុងនោះរួមមាន ឯកសារទាក់ទងនឹងរដ្ឋាភិបាលរួបរួមជាតិកម្ពុជា បន្ទាប់មកគឺឯកសារទាក់ទងនឹងរបបកម្ពុជាប្រជាធិបតេយ្យ ។ តំណាងសហព្រះរាជអាជ្ញាបានចាប់ផ្តើម បង្ហាញនូវឯកសារដែលមានចំណងជើងថា "អាសនៈកម្ពុជានៅអគ្គការសហប្រជាជាតិ" ដោយដកស្រង់នូវ ឃ្លាមួយ

តំណាងសហព្រះរាជអាជ្ញា វាំងសង់ បានបន្តរៀបរាប់ឈ្មោះសមាជិកនៃរដ្ឋាភិបាលរួបរួមជាតិមួយចំនួនទៀតដូចជា ៖

"ចាន់ យូរ៉ាន់, ឧត្តមសេនីយ ដួង សំអុល, ហួត សម្បត្តិ, ជា សាន, ជួន ប្រាសិទ្ធ, គាត ឈន់, វ៉ាន់ ពីនី, ទីវ អុល, អៀង ធីរិទ្ធ អនុរដ្ឋមន្ត្រីក្រសួងអប់រំ ប្រជាជននិងយុវជន, ជូ ជេត អនុរដ្ឋមន្ត្រីក្រសួងសុខាភិបាលសាធារណៈ ក្រសួងកិច្ចការសាសនានិងសង្គមកិច្ច និង កុយ ធួន អនុរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

លោកតំណាងសហព្រះរាជអាជ្ញាបានដាក់បង្ហាញឯកសារ "ខុទ្ទការល័យរបស់រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា សេចក្តីថ្លែង

ការណ៍របស់សម្តេចសីហនុ» ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ១៩៧៤ រួមជាមួយនឹងឯកសារមួយចំនួនផ្សេងទៀត ដូចជា «សេចក្តីសម្រេចរបស់គណៈមជ្ឈិមលើបញ្ហាមួយចំនួន» ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ ឯកសារ «សេចក្តីប្រកាសរបស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យចំពោះសេចក្តីថ្លែងការណ៍របស់សម្តេចសីហនុ សុំចូលនិវត្តន៍» និងឯកសារ «ការតែងតាំងរដ្ឋាភិបាលថ្មីនៃកម្ពុជាប្រជាធិបតេយ្យ» ។

តំណាងសហព្រះរាជអាជ្ញា បានដកស្រង់ផ្នែកទាក់ទងនឹងសមាសភាពនៃរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យដូចតទៅ ៖

១) សមមិត្ត ប៉ុល ពត នាយករដ្ឋមន្ត្រី
២) សមមិត្ត អៀង សារី ឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការបរទេស
៣) សមមិត្ត វន វ៉េត ឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកសេដ្ឋកិច្ច
៤) សមមិត្ត សុន សេន ឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការការពារជាតិ
៥) សមមិត្ត ហ៊ូ នឹម រដ្ឋមន្ត្រីក្រសួងឃោសនាការនិងព័ត៌មាន
៦) សមមិត្ត ជួន ជឿន រដ្ឋមន្ត្រីក្រសួងសុខាភិបាល
៧) សមមិត្ត អៀង ធីរិទ្ធ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច
៨) សមមិត្ត តូច ភឿន រដ្ឋមន្ត្រីក្រសួងសាធារណការ
៩) សមមិត្ត យុន យ៉ាត រដ្ឋមន្ត្រីក្រសួងវប្បធម៌ អប់រំ និងសិក្សាធិការ

សូមបញ្ជាក់ថា ដោយសារតែតំណាងសហព្រះរាជអាជ្ញា មិនទាន់បញ្ចប់ការដាក់បង្ហាញឯកសាររបស់ខ្លួនចប់សព្វគ្រប់ អង្គជំនុំជម្រះអនុញ្ញាតឲ្យភាគីសហព្រះរាជអាជ្ញាបន្តការដាក់បង្ហាញឯកសាររបស់ខ្លួនបន្ថែម ទៀតនៅថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១២ ។

មុនពេលចាប់ផ្តើមកិច្ចដំណើរការនីតិវិធីសវនាការនៅថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១២ ក្រុមមេធាវីការពារក្តី នួន ជា បានស្នើសុំអង្គជំនុំជម្រះដើម្បីឡើងសម្តែងនូវសេចក្តីមរណទុក្ខចំពោះការយាងចូលទិវង្គត់របស់សម្តេចព្រះនរោត្តម សីហនុ នៅថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១២ នៅទីក្រុងប៉េកាំង កន្លងទៅ ។ ប៉ុន្តែបន្ទាប់ពីបានពិភាក្សាក្នុងចំណោមចៅក្រមទាំងអស់ អង្គជំនុំជម្រះបានសម្រេចបដិសេធសំណើសុំរបស់ក្រុមមេធាវីការពារក្តី នួន ជា ដោយអះអាងថា មិនមែនជាពេលវេលាសមស្របដែលត្រូវអនុញ្ញាតឲ្យភាគីណាមួយត្រូវធ្វើដូច្នេះនៅក្នុងនីតិវិធីសវនាការទេ ។

បន្ទាប់មកអង្គជំនុំជម្រះប្រគល់វេទិកាជូនតំណាងសហព្រះរាជអាជ្ញា វ៉ាំងសង់ ដើម្បីបន្តការដាក់បង្ហាញឯកសាររបស់ការិយាល័យសហព្រះរាជអាជ្ញាបន្តទៀត ។ តំណាងសហព្រះរាជអាជ្ញាបានបន្តដាក់ ឯកសារទាក់ទងនឹងជនជាប់ចោទ ខៀវ សំផន ក្នុងឋានៈជាអ្នកទទួលបន្ទុកខាងផ្នែកពាណិជ្ជកម្ម ។ ឯកសារភាគច្រើន បង្ហាញអំពីការសរសេរលិខិតរបស់កម្មាភិបាលថ្នាក់ក្រោមដើម្បីសុំការណែនាំពី បងហែម (ខៀវ សំផន) ទាក់ទងនឹងការនាំចូល និងនាំចេញស្បៀងពីប្រទេសកម្ពុជា និងឯកសារស្តីពីមហាសន្និបាតនៅក្រសួងពាណិជ្ជកម្ម ។ បន្ទាប់មកតំណាងសហព្រះរាជអាជ្ញាអន្តរជាតិរូបនេះ បានបន្តបង្ហាញឯកសារផ្សេងៗទៀតទាក់ទងនឹងបញ្ជីឈ្មោះកម្មាភិបាលក្រសួងពាណិជ្ជកម្មដែលត្រូវបានចាប់ខ្លួនបញ្ជូនទៅមន្ទីរស-២១ ឬគុកទួលស្លែង ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ ឌុច ។

តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ វ៉ាំងសង់ ដឺវ៉ាល់ដេស្នាឯល បានបញ្ចប់ការដាក់បង្ហាញឯកសារចំពោះផ្នែកស្តីពីរដ្ឋាភិបាលរួបរួមជាតិរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ និងក្រសួងផ្សេងៗ រួមទាំងគោលនយោបាយដែលត្រូវបានអនុវត្តនៅក្នុងរយៈកាលនៃរបបកម្ពុជាប្រជាធិបតេយ្យ ។

បន្ទាប់មកតំណាងសហព្រះរាជអាជ្ញាជាតិ សុង ឆវ័ន្ត បានបន្តបង្ហាញឯកសារស្តីអំពីរចនាសម្ព័ន្ធរដ្ឋបាល និងប្រព័ន្ធទំនាក់ទំនងរវាងគណៈមជ្ឈិម និងថ្នាក់ភូមិភាគតាមរយៈបទបញ្ជា សេចក្តីសម្រេច និងសារទូរលេខដែលប្រធានភូមិភាគនានាបានរាយការណ៍អំពីអ្វីដែលបានកើតឡើងនៅតាមភូមិភាគរបស់ខ្លួន ។ តំណាងសហព្រះរាជអាជ្ញា ឆវ័ន្ត ក៏បានបង្ហាញអំពីប្រព័ន្ធទំនាក់ទំនងរដ្ឋបាលរវាងថ្នាក់តំបន់ និងថ្នាក់ស្រុកតាមរយៈសារទូរលេខ និងរបាយការណ៍ដែរ ។ បន្តពីតំណាងសហព្រះរាជអាជ្ញាជាតិ តំណាងសហព្រះរាជអាជ្ញា អន្តរជាតិ ឃីត រេននីរ បានបន្តដាក់បង្ហាញឯកសារស្តីពីប្រព័ន្ធទំនាក់ទំនងរវាងភូមិភាគឦសាន និងមជ្ឈិមបក្ស ដើម្បីបង្ហាញអំពីប្រព័ន្ធទាំងនាក់ទំនងរបស់ថ្នាក់លើ ថ្នាក់ភូមិភាគទៅថ្នាក់តំបន់ និងពីថ្នាក់តំបន់ទៅថ្នាក់ស្រុក និងពីថ្នាក់

ស្រុកទៅថ្នាក់ឃុំ ។

### ៣) ការដាក់បង្ហាញឯកសារចំពោះមុខអង្គជំនុំជម្រះដោយសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី

មេធាវីជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណី ពេជ អង្គ បានដាក់បង្ហាញឯកសារទាក់ទងនឹងរចនាសម្ព័ន្ធរដ្ឋបាល និងប្រព័ន្ធទំនាក់ទំនងនៃរបបកម្ពុជាប្រជាធិបតេយ្យ ដោយចាប់ផ្តើមជាមួយនឹងឯកសារ ខ្សែវីដេអូដែលមានចំណងជើងថា "សត្រូវរបស់ប្រជាជន" (ដែលជាខ្សែវីដេអូស្តីពីបទសម្ភាសន៍រវាង នួន ជា និង ថេត សម្បត្តិ) ។ មេធាវី ពេជ អង្គ បានបង្ហាញខ្សែវីដេអូនេះជាវគ្គខ្លីៗចំពោះចំណុចដែលខ្លួនយល់ថា មានភាពជាប់ទាក់ទងនឹងរចនាសម្ព័ន្ធនៃរបបកម្ពុជាប្រជាធិបតេយ្យ និងបានធ្វើការសន្និដ្ឋានចំពោះវគ្គនីមួយៗ នៃខ្សែវីដេអូដែលខ្លួនបានដាក់បង្ហាញនោះ ។ ឧទាហរណ៍ លោកមេធាវីបញ្ជាក់ថា នៅក្នុងខ្សែវីដេអូនេះ នួន ជា បាននិយាយថា ប៉ុល ពត និង នួន ជា ខ្លួនឯងបានរួមគ្នាធ្វើការសម្រាប់បក្សកុម្មុយនីស្ត ដោយមានការរួម និងផ្លាស់ប្តូរមតិគ្នា ។ ការធ្វើសេចក្តីសន្និដ្ឋានបន្ថែមបែបនេះ ត្រូវបានក្រុមមេធាវីការពារក្តី នួន ជា ជំទាស់ ដោយអះអាងថា មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីមិនអាចធ្វើការសន្និដ្ឋានណាមួយ នៅក្នុងសវនាការនេះបានទេ ។ មេធាវី ពេជ អង្គ បានបញ្ជាក់ថា ខ្លួននឹងជៀសវាងចំពោះការធ្វើអត្ថាធិប្បាយដែលមានលក្ខណៈជាការសន្និដ្ឋាន ។

បន្ទាប់មក លោកមេធាវីបានបន្តបង្ហាញឯកសារខ្សែវីដេអូទាក់ទងនឹងជាប់ចោទ ខៀវ សំផន ដែលបានផ្តល់បទសម្ភាសន៍ជាមួយនឹងអ្នកកាសែត ។ អាកទួរ វែកគែន ក្រោយពីបញ្ចាំងវីដេអូនេះភ្លាម មេធាវីការពារក្តី ខៀវ សំផន បានធ្វើការជំទាស់ ដោយស្នើឲ្យអង្គជំនុំជម្រះច្រានចោលការចាក់បញ្ចាំងខ្សែវីដេអូនោះ ដោយអះអាងថា ខ្សែវីដេអូដែលមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីយកមកដាក់បង្ហាញ ពុំមានភាពជាប់ពាក់ព័ន្ធនឹងវិសាលភាពនៃសវនាការ ។ ប៉ុន្តែសេចក្តីជំទាស់នេះត្រូវបានអង្គជំនុំជម្រះបានបដិសេធ និងអនុញ្ញាតឲ្យមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបន្តដាក់បង្ហាញឯកសាររបស់ខ្លួនបន្តទៀត ។ មេធាវី ពេជ អង្គ បានបង្ហាញខ្សែវីដេអូមួយទៀតទាក់ទងនឹងការជម្លៀស និងការធ្វើការនៅក្នុងសហករណ៍ និងការដ្ឋាន ។ ជាថ្មីម្តងទៀត មេធាវីការពារក្តី ខៀវ សំផន បានព្យាយាមជំទាស់សារជាថ្មីចំពោះការបង្ហាញខ្សែវីដេអូនោះ ។ ប៉ុន្តែ អង្គជំនុំជម្រះច្រានចោលការជំទាស់នេះ ។ មេធាវី ពេជ អង្គ ក៏បានបង្ហាញ និងអាននិក្ខេបបទរបស់ ខៀវ សំផន ដើម្បីបង្ហាញភាគី និងអង្គជំនុំជម្រះចំពោះផ្នែកដែលទាក់ទងនឹងសហករណ៍ ។ បន្ទាប់មកលោកមេធាវីបានភ្ជាប់អត្ថន័យដែលមាននៅក្នុងនិក្ខេបបទនោះ ជាមួយនឹងខ្សែវីដេអូដែលបង្ហាញអំពីស្ថានភាពជាក់ស្តែងរបស់ជនរងគ្រោះនៅតាមសហករណ៍ ។

នៅក្នុងសវនាការថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១២ មេធាវី ពេជ អង្គ បានបន្តដាក់បង្ហាញឯកសារទាក់ទងនឹងលក្ខន្តិកបក្សកុម្មុយនីស្តកម្ពុជា ។ លោកមេធាវីបានអានមាត្រា មួយចំនួននៃលក្ខន្តិកៈនេះជូនអង្គជំនុំជម្រះ និងភាគីទាក់ទងនឹងផ្នែកស្តីពីរចនាសម្ព័ន្ធរបស់បក្សកុម្មុយនីស្តកម្ពុជា ចាប់ពីថ្នាក់មជ្ឈិមរហូតដល់ថ្នាក់មូលដ្ឋាន ។ មេធាវី ពេជ អង្គ បានចំណាយពេលប្រមាណ ២០នាទីដើម្បីអានទាំងស្រុងនូវមាត្រាដែលទាក់ទង ។ មាត្រាទាំងនោះរួមមាន៖

មាត្រា៧ អំពីខ្សែចាត់តាំងរបស់បក្ស, មាត្រា៩ អំពីសាខា, មាត្រា១០ អំពីភារកិច្ចរបស់ខាសា, មាត្រា១២ អំពីគណៈកម្មាធិការស្រុក, មាត្រា១៣ អំពីភារកិច្ចរបស់គណៈកម្មាធិការស្រុក, មាត្រា១៤ អំពីការប្រជុំរបស់គណៈកម្មាធិការស្រុក, មាត្រា១៥ អំពីគណៈកម្មាធិការ តំបន់ ក្រុង, មាត្រា១៦ អំពីភារកិច្ចរបស់គណៈកម្មាធិការ តំបន់ ក្រុង, មាត្រា១៧ អំពីការប្រជុំរបស់គណៈកម្មាធិការ តំបន់ ក្រុង, មាត្រា១៨ អំពីគណៈកម្មាធិការភូមិភាគ, មាត្រា១៩ អំពីភារកិច្ចរបស់គណៈកម្មាធិការភូមិភាគ, មាត្រា២០ អំពីការប្រជុំរបស់គណៈកម្មាធិការភូមិភាគ, មាត្រា២១ អំពីគណៈកម្មាធិការមជ្ឈិម, មាត្រា២២ អំពីមហាសន្និបាត, មាត្រា២៣ អំពីភារកិច្ចរបស់គណៈកម្មាធិការមជ្ឈិម ។

បន្ទាប់មក មេធាវី ពេជ អង្គ បានបង្ហាញឯកសារមួយទៀតទាក់ទងនឹងសៀវភៅរបស់ ខៀវ សំផន ដែលមានចំណងជើងថា "ប្រវត្តិសាស្ត្រកម្ពុជាថ្មីៗនេះ និងគោលជំហររបស់ខ្ញុំជាបន្តបន្ទាប់" ដែលនិយាយទាក់ទងនឹងគណៈមជ្ឈិមបក្សនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ លោកមេធាវីបានដកស្រង់ឃ្លាមួយដែលជា

សំណេររបស់ ខៀវ សំផន ដើម្បីបង្ហាញជូនអង្គជំនុំជម្រះ និង ភាគី ។ ឃ្លានោះបានសរសេរថា ៖

"ប៉ុន្តែបើគេស៊ើបអង្កេតឲ្យបានហ្មត់ចត់បន្តិច គេអាចឃើញយ៉ាងងាយថា គណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា មិនអាចប្រៀបបានទៅនឹងគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្តដទៃទៀតដែលគេធ្លាប់ស្គាល់នៅក្នុងសកលលោកនោះទេ ។ ដូចដែលខ្ញុំបានសរសេរនៅក្នុងសំបុត្រចំហរបស់ខ្ញុំចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០០១ ហើយ ។ អង្គការនេះ មានន័យថា ជាអង្គការមជ្ឈិមបក្សគណៈកម្មាធិការមជ្ឈិមបក្សនេះ មិនមែនជាអង្គការដឹកនាំរបស់បក្សនោះទេ វាគ្រាន់តែជាមជ្ឈមណ្ឌលមួយសម្រាប់អប់រំកម្មាភិបាលខាងមនោគមវិជ្ជា និងខាងនយោបាយតែប៉ុណ្ណោះ ពិសេសសម្រាប់អប់រំលេខា និងគណៈកម្មាធិការបក្ស ដែលទទួលខុសត្រូវគ្រប់គ្រងភូមិភាគ តំបន់ និងកងទ័ព សំដៅឲ្យគេជ្រួតជ្រាបការសម្រេចខាងនយោបាយជាទូទៅរបស់គណៈកម្មាធិការអចិន្ត្រៃយ៍តែប៉ុណ្ណោះ" ។

បន្ទាប់ពីបញ្ចប់ការបង្ហាញការដកស្រង់នេះ មេធាវី ពេជ អង្គ មេធាវី ស៊ីម៉ូណូហ្គូត បានបន្តធ្វើការបង្ហាញឯកសារចំនួន១១ ទាក់ទងនឹងរចនាសម្ព័ន្ធរបស់គណៈមជ្ឈិម និងលើកឡើងពីសម្តីរបស់ ខៀវ សំផន និង នួន ជា ដែលនិយាយអំពីតួនាទីរបស់ខ្លួននៅក្នុងគណៈទាំងនោះ ។ លោកស្រីមេធាវីបានបង្ហាញអំពីបង្ហាញបទសម្ភាសន៍មួយដែលធ្វើឡើងរវាង អៀ ម៉េងទ្រី និង លឿង សូភ័ក្ត្រ ជាមួយ ខៀវ សំផន និង នួន ជា នៅថ្ងៃទី៩-១០ ខែមិថុនា ឆ្នាំ២០០៦ ។ នៅក្នុងបទសម្ភាសន៍នោះ ខៀវ សំផន បានបញ្ជាក់ថា "អ្នកទាំងអស់គ្នាបានប្រព្រឹត្តកំហុសជាច្រើន ។ មិនដែលមាននរណាសុក្រឹតឥតខ្ចោះនោះទេ ។ យើងត្រូវតែរៀនសូត្រពីការខុសឆ្គងរបស់យើង រួចហើយធ្វើការកែប្រែ ។ ខ្ញុំក៏បានប្រព្រឹត្តខុសជាច្រើនដែរនៅក្នុងពេលដែលខ្ញុំកាន់អំណាច" ។ ឆ្លើយតបនឹងសំណួរដែលសួរថា តើនរណាខ្លះជាសមាជិករបស់គណៈកម្មាធិការអចិន្ត្រៃយ៍ ខៀវ សំផន បានបញ្ជាក់ថា ៖

"មានមនុស្សចំនួនប្រាំបីនាក់ ។ គណៈកម្មាធិការនេះរួមប្រជុំគ្នាដើម្បីសម្រេចលើបញ្ហាជាក់លាក់ រួចហើយបានជម្រាបជូនសមាជិកមជ្ឈិមបក្សដែលមកពីគ្រប់តំបន់ទាំងអស់នៅទូទាំងប្រទេស ។ ខ្ញុំជាសមាជិកមួយរូបរបស់គណៈអចិន្ត្រៃយ៍ ក៏ប៉ុន្តែខ្ញុំគ្មានតំបន់សម្រាប់ត្រួតត្រានោះទេ ។ ក្នុងគណៈអចិន្ត្រៃយ៍ រួមមាន ប៉ុល ពត ជាលេខា នួន ជា អនុលេខា អៀង សារី, សុន សេន, តាម៉ុក, វន វេត, និង សោ ភឹម" ។

ការបង្ហាញឯកសារនេះ ត្រូវបានមេធាវីអន្តរជាតិការពារក្តី ខៀវ សំផន មេធាវី វើកគែន បានក្រោកឡើងជំទាស់ដោយអះអាងថា ឯកសារនោះពុំមានខ្សែអាត់ថតសម្លេង គឺមានត្រឹមតែកំណត់ត្រាប៉ុណ្ណោះ ។ មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានឆ្លើយតបនឹងការជំទាស់នេះថា ឯកសារនេះត្រូវបានទទួលយកដោយអង្គជំនុំជម្រះម្តងហើយ ដូច្នេះខ្លួនអាចលើកយកឯកសារនេះមកបង្ហាញនៅក្នុងសវនការបាន ។ អង្គជំនុំជម្រះបានសម្រេចបដិសេធការជំទាស់របស់មេធាវីការពារក្តី ខៀវ សំផន ដោយអះអាងថា ឯកសារនេះអង្គជំនុំជម្រះបានទទួលស្គាល់នៅក្នុងសំណុំរឿងហើយ ចំពោះទម្ងន់នៃភស្តុតាងនេះនឹងត្រូវពិចារណានៅពេលដែលអង្គជំនុំជម្រះចេញសាលក្រម ។ ម្យ៉ាងវិញទៀត ភាគីមិនគួរជំទាស់ការបង្ហាញឯកសារនៅពេលនេះទេ មេធាវីការពារក្តីអាចធ្វើការជំទាស់នៅពេលដែលខ្លួនត្រូវបានផ្តល់វេទិកាដោយអង្គជំនុំជម្រះ ។

បន្ទាប់មកមេធាវី ស៊ីម៉ុនណូហ្គូត បានបង្ហាញឯកសារមួយទៀតស្តីពីបទសម្ភាសន៍រវាង អៀ ម៉េងទ្រី ជាមួយ នួន ជា ដែលនិយាយអំពីការអប់រំកម្មាភិបាល ។ លោកស្រីមេធាវីបានដកស្រង់ចំណុចមួយចំនួននៃបទសម្ភាសន៍នោះមកធ្វើការបង្ហាញ ។ នួន ជា បានលើកឡើងនៅក្នុងបទសម្ភាសន៍នោះថា ៖

"ពេលដែលខ្ញុំកាន់អំណាចនយោបាយល្អ មន្ត្រីរបស់យើងគឺមិនល្អទេ យើងពុំមានស្ថានល្អសម្រាប់ នាំយកគោលនយោបាយល្អរបស់យើងទៅដល់ប្រជាជន ។ អាស្រ័យហេតុនេះហើយ បានជាយើងបរាជ័យ មិនអាចទៅដល់គោលដៅរបស់យើង ។ នៅទីបញ្ចប់ ផែនការរបស់ខ្ញុំត្រូវបានបំផ្លាញ ហើយធ្វើឲ្យរបបរបស់ខ្ញុំទន់ខ្សោយ ។ នៅចុងបញ្ចប់ខ្ញុំត្រូវបរាជ័យ" ។

ឯកសារកិច្ចសម្ភាសន៍មួយទៀតរវាង ខៀវ សំផន និងអ្នកកាសែតសម្លេងវិទ្យុសហរដ្ឋអាមេរិកក៏ត្រូវបានដាក់បង្ហាញ រួមជាមួយនឹងការសែតដែលបារាំងដែលបានសម្ភាសន៍ជាមួយ ចៅ

សេង និងសំបុត្រដែល ចៅ សេង បានផ្ញើជូនភរិយារបស់លោក ។ បន្ថែមពីលើនេះ លោកស្រីមេធាវីបានបង្ហាញឯកសារមួយចំនួនទៀត ទាក់ទងនឹងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ប្រពន្ធ អ៊ុក កេត និងបញ្ជីឈ្មោះអ្នកទោសដែលត្រូវបានសម្លាប់នៅខែធ្នូ ឆ្នាំ១៩៧៧ ។

### ៤) ការដាក់បង្ហាញឯកសារចំពោះមុខអង្គជំនុំជម្រះដោយក្រុមមេធាវីការពារក្តីជនជាប់ចោទ

ក្នុងចំណោមក្រុមមេធាវីការពារក្តីជនជាប់ចោទទាំងបីក្រុម ក្រុមមេធាវីការពារក្តី នួន ជា ត្រូវបានអង្គជំនុំជម្រះផ្តល់វេទិកាជូនមុនគេ ដើម្បីដាក់ឯកសារដែលខ្លួនមានបំណងចង់បង្ហាញជូនអង្គជំនុំជម្រះ និងភាគី ។ បន្ទាប់មក វេទិកាដាក់បង្ហាញឯកសារនឹងត្រូវបន្តជូនក្រុមមេធាវីការពារក្តី អៀង សារី និង ខៀវ សំផន ។ ប៉ុន្តែ ក្រុមមេធាវីការពារ អៀង សារី និងក្រុមមេធាវីការពារក្តី ខៀវ សំផន បានបញ្ជាក់ជូនអង្គជំនុំជម្រះថា ក្រុមរបស់ខ្លួនពុំមានឯកសារដើម្បីដាក់ជូនអង្គជំនុំជម្រះ និងភាគីទេ ។

#### ៤.ក) ក្រុមមេធាវីការពារក្តី នួន ជា

មេធាវីអន្តរជាតិការពារក្តី នួន ជា មេធាវី អេនឌ្រូ អ៊ីណូហ្វ៊ី បានបង្ហាញឯកសារស្តីពីបទសម្ភាសន៍រវាង ប៊ែន ឃៀរនិន ជាមួយសម្តេច ហេង សំរិន និងសម្តេច ជា ស៊ីម ដើម្បីដាក់ចូលនៅចំពោះមុខអង្គជំនុំជម្រះ ។ បទសម្ភាសន៍នេះ ត្រូវបានមេធាវីរូបនេះបញ្ជាក់ថា គឺផ្តោតសំខាន់លើការវាយចូលទីក្រុងភ្នំពេញនៅទីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដោយយោធាភូមិភាគបូព៌ា និងការប្រជុំដែលរៀបចំឡើង នៅទីក្រុងភ្នំពេញ នៅថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៧៥ ទាក់ទងនឹងអត្ថន័យនៃពាក្យថា កម្ទេចកម្ចាត់ និងបោសសម្អាត។ មេធាវី អ៊ីណូហ្វ៊ី បានអានឯកសារទាំងស្រុងជូនអង្គជំនុំជម្រះ និងភាគីបានដឹង ។

ឯកសារចំនួនពីររបស់ ហ្វីលីព ស្ងត និង ប៊ែន ឃៀរនិន ដែលក្រុមមេធាវីការពារក្តី នួន ជា មានបំណងចង់ដាក់បង្ហាញជូនអង្គជំនុំជម្រះ និងភាគី ត្រូវបានអង្គជំនុំជម្រះស្នើឲ្យបង្អង់ឯកសារទាំងពីរនោះទុកសិន ហើយអង្គជំនុំជម្រះនឹងផ្តល់ឱកាសជូនក្រុមមេធាវី នួន ជា ដើម្បីដាក់បង្ហាញឯកសារទាំងនេះនៅពេលក្រោយ ដោយពុំមានការបំពានលើសិទ្ធិរបស់មេធាវីការពារក្តីឡើយ ។

ការសម្រេចដូច្នេះ គឺដោយសារអង្គជំនុំជម្រះផ្អែកលើហេតុផលថា មិនមែនជាពេលវេលាសមស្របក្នុងការបង្ហាញឯកសារទាំងពីរនេះទេ ព្រោះអ្នកជំនាញទាំងពីររូបដែលបានសរសេរឯកសារទាំងពីរនេះ អង្គជំនុំជម្រះគ្រោងនឹងកោះហៅមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ ។ ប៉ុន្តែមេធាវីការពារក្តីមិនបានយល់ស្របចំពោះការសម្រេចបែបនេះឡើយ ដោយសារតែឯកសារដែលអង្គជំនុំជម្រះ ស្នើមិនឲ្យខ្លួនបង្ហាញនៅក្នុងសវនាការ គឺត្រូវបានដាក់ជូនអង្គជំនុំជម្រះដើម្បីពិនិត្យជាយូរមកហើយ ។ ម្យ៉ាងវិញទៀត អង្គជំនុំជម្រះទើបតែជូនដំណឹងមកក្រុមរបស់ខ្លួនអំពីការបង្អង់នេះនៅថ្ងៃសវនាការតែប៉ុណ្ណោះ ។ មេធាវី អ៊ីណូហ្វ៊ី បានលើកឡើងបន្តទៀតថា ការសម្រេចរបស់អង្គជំនុំជម្រះចំពោះចំណុចនេះ ហាក់បីដូចជាមានភាពលម្អៀងចំពោះក្រុមមេធាវីការពារក្តី ដោយសារតែអង្គជំនុំជម្រះអនុញ្ញាតឲ្យសហព្រះរាជអាជ្ញាអាចលើកឡើងពីឯកសារដែលរៀបចំដោយ ស្ទីវ ហេដឌ័រ និងឯកសាររបស់ ហ្វីលីព ស្ងត នៅអំឡុងពេលសវនាការ ថ្ងៃទី១០ ខែតុលា ឆ្នាំ២០១២ ។ ឆ្លើយតបនឹងការលើកឡើងរបស់មេធាវីការពារក្តី នួន ជា តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ គឺ ឃីត រេនន័រ បានបញ្ជាក់ថា ឯកសារដែលសហព្រះរាជអាជ្ញាបានដាក់បង្ហាញនៅថ្ងៃទី១០ ខែតុលា ឆ្នាំ២០១២ គឺគ្រាន់តែជាឯកសារទស្សនាវដ្តីទង់បដិវត្តដែលរៀបចំដោយ ស្ទីវ ហេដឌ័រ ឬ ហ្វីលីព ស្ងត ដែលសហព្រះរាជអាជ្ញាបានយោងទៅលើតែប៉ុណ្ណោះ ។

ទោះបីជាមានការលើកឡើងជាច្រើនដងពីសំណាក់ក្រុមមេធាវីការពារក្តី នួន ជា ក៏ដោយ អង្គជំនុំជម្រះបានសម្រេចមិនអនុញ្ញាតឲ្យមេធាវីការពារក្តី នួន ជា បង្ហាញឯកសារដែលទាក់ទងនឹង ស្ទីវ ហេដឌ័រ និង ហ្វីលីព ស្ងត នៅក្នុងសវនាការឡើយ ។ ប៉ុន្តែអង្គជំនុំជម្រះនឹងអនុញ្ញាតឲ្យបង្ហាញឯកសារនោះនៅពេលសមស្របខាងមុខ ។

សវនាការស្តីពីការដាក់បង្ហាញឯកសារទាក់ទងនឹងរចនាសម្ព័ន្ធរដ្ឋបាលនៃរបបកម្ពុជាប្រជាធិបតេយ្យបានបញ្ចប់នៅព្រឹកថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១២ ។

# សវនាការស្ដាប់សក្ខីកម្មដើមបណ្ដឹងរដ្ឋប្បវេណី យឹម សុវណ្ណ និង ជុំ សុខា

## ថ្ងៃទី១៩-២២ ខែតុលា ឆ្នាំ២០១២

នៅរសៀលថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១២ អង្គជំនុំជម្រះបានបន្តសាកសួរដេញដោលដើមបណ្ដឹងរដ្ឋប្បវេណី យឹម សុវណ្ណ ដែលជាជនរងគ្រោះដោយសារការជម្លៀសប្រជាជនរបស់យោធាខ្មែរក្រហម នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ។ ការសួរដេញដោលដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ ចំណាយពេលត្រឹមតែមួយរសៀលប៉ុណ្ណោះ ដោយហេតុថាមេធាវីការពារក្ដីឲ្យជនជាប់ចោទទាំងបីក្រុមពុំមានសំណួរ ដើម្បីចោទសួរដើមបណ្ដឹងរដ្ឋប្បវេណី ។ ដោយសារតែដើមបណ្ដឹងរដ្ឋប្បវេណីពុំទាន់បានថ្លែងអំពីទុក្ខសោករបស់ខ្លួនដែលរងគ្រោះដោយសាររបបខ្មែរក្រហម អង្គជំនុំជម្រះ បានផ្ដល់ឱកាសជូនអ្នកស្រីនៅព្រឹកថ្ងៃទី២២ ខែតុលា ឆ្នាំ២០១២ ដើម្បីឡើងថ្លែងអំពីទុក្ខសោកដោយសារការបាត់បង់សាច់ញាតិ និងអ្នកជាទីស្រឡាញ់ និងទ្រព្យសម្បត្តិនៅអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ បន្ទាប់មក នៅរសៀលថ្ងៃទី២២ ខែតុលា ឆ្នាំ២០១២ អង្គជំនុំជម្រះបានបន្តស្ដាប់សក្ខីកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណីមួយរូបផ្សេងទៀតដែលមានឈ្មោះ ជុំ សុខា ។ ការសួរដេញដោលដើមបណ្ដឹងរដ្ឋប្បវេណី ជុំសុខា គឺចំណាយពេលត្រឹមតែមួយរសៀលតែប៉ុណ្ណោះ ។

ការផ្ដល់សក្ខីកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណី យឹម សុវណ្ណ និង ជុំ សុខា បានផ្ដោតសំខាន់លើព្រឹត្តិការណ៍ជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ។ ដោយហេតុថា សវនាការនេះ ជាសវនាការសួរដេញដោលចំពោះដើមបណ្ដឹងរដ្ឋប្បវេណី ដូច្នេះនីតិវិធីតម្រូវឲ្យមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីជាអ្នកចាប់ផ្ដើមចោទសួរមុនភាគីផ្សេងទៀត ដែលខុសគ្នាពីការសួរដេញ ដោលចំពោះសាក្សី ដែលជាធម្មតាគឺសហព្រះរាជអាជ្ញាជាអ្នកចាប់ផ្ដើមមុន ។

ដោយសារសក្ខីកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណី យឹម សុវណ្ណ និង ជុំ សុខា ផ្ដោតជាសំខាន់លើការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញដូចគ្នា ហើយការទទួលរងគ្រោះមានលក្ខណៈប្រហាក់ប្រហែលគ្នា ដូច្នេះសក្ខីកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ជុំ សុខា នឹងត្រូវរៀបរាប់សង្ខេបៗ ។ ចំពោះសក្ខីកម្មដែលរៀបរាប់លម្អិតរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ជុំ សុខា អាចរកបាននៅក្នុងប្រតិចារិកសវនាការថ្ងៃទី២២ ខែតុលា ឆ្នាំ២០១២ នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

### ១) ប្រវត្តិសាវតាររបស់ដើមបណ្ដឹងរដ្ឋប្បវេណី យឹម សុវណ្ណ

ប្រធានអង្គជំនុំជម្រះ ចៅក្រម និល ណុន បានសាកសួរដេញដោលដើមបណ្ដឹងរដ្ឋប្បវេណី យឹម សុវណ្ណ ទាក់ទងនឹងប្រវត្តិសាវតាររបស់អ្នកស្រីមុនពេលប្រគល់វេទិកាសួរដេញដោលជូនមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ។ ឆ្លើយតបនឹងសំណួររបស់អង្គជំនុំជម្រះ យឹម សុវណ្ណ បានជម្រាបជូនប្រធានអង្គជំនុំជម្រះថា អ្នកស្រីកើតនៅថ្ងៃទី៥ ខែតុលា ឆ្នាំ១៩៦០ និងមានទីកន្លែងកំណើតនៅភូមិ ព្រែកត្រែង ឃុំសិត្បូ ស្រុកស្អាង ខេត្តកណ្ដាល ។



ដើមបណ្ដឹងរដ្ឋប្បវេណី យឹម សុវណ្ណ
(ប្រភព : មជ្ឈមណ្ឌលឯកសារកម្ពុជា)

បច្ចុប្បន្នកំពុងរស់នៅទីក្រុងភ្នំពេញ ។ យឹម សុវណ្ណ មានឪពុកឈ្មោះ តូច ស៊ុំ និងម្ដាយឈ្មោះ ទូច លី និង មានស្វាមីឈ្មោះ គឹម លាង មានកូនបីនាក់ ។ នៅចន្លោះឆ្នាំ១៩៧៥ ដល់ ឆ្នាំ១៩៧៩ ។

សុវណ្ណ គឺជាកសិករនៅឃុំពោធិ៍បាន ស្រុកកោះធំ ខេត្តកណ្តាល ហើយក្រោយមកត្រូវបានផ្លាស់ទៅសហករណ៍ក្បាលឈើពុក ស្រុកកណ្តៀង ខេត្តពោធិ៍សាត់ ។ បន្ទាប់ពីរបបខ្មែរក្រហមបានដួលរលំទៅ យឹម សុវណ្ណ បានត្រឡប់ចូលមករស់នៅទីក្រុងភ្នំពេញវិញ ។

បន្ទាប់ពីបញ្ចប់ការសួរដេញដោលប្រធានអង្គជំនុំជម្រះបានប្រគល់វេទិកាជូនមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីដើម្បីបន្តការសួរដេញដោល យឹម សុវណ្ណ ។

### ២) ការសួរដេញដោលដោយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី

មុនពេលចាប់ផ្តើមសាកសួរសំណួរដើមបណ្តឹងរដ្ឋប្បវេណី យឹម សុវណ្ណ មេធាវីនាំមុខអន្តរជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណី គឺ អេលីហ្សាប៊ែត ស៊ីម៉ូណូហ្គូ បានឡើងជម្រាបជូនអង្គជំនុំជម្រះថា សំ សុគង់ ដែលជាមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីនឹងចាប់ផ្តើមសាកសួរសំណួរដើមបណ្តឹងរដ្ឋប្បវេណី យឹម សុវណ្ណ ហើយអ្នកស្រីនឹងសាកសួរបន្តបន្ទាប់ពីលោកមេធាវីបញ្ចប់ការសួរសំណួរ ។

### ២.ក) ការសួរដេញដោលដោយមេធាវីជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណី

#### ២.ក.១) ស្ថានការណ៍មុនឆ្នាំ១៩៧៥

មេធាវី សំ សុគង់ បានចាប់ផ្តើមសំណួរដំបូងរបស់លោកទាក់ទងនឹងប្រវត្តិសាវតារ និងស្ថានភាពទីក្រុងភ្នំពេញនៅមុនពេលនៃការចូលមកដល់នៃទាហានខ្មែរក្រហម ដោយចោទសួរទាក់ទងនឹងទីកន្លែង ស្នាក់នៅរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅមុនឆ្នាំ១៩៧៥ ។ ឆ្លើយតបនឹងសំណួរនេះដើមបណ្តឹងរដ្ឋប្បវេណី យឹម សុវណ្ណ បានបញ្ជាក់ថា នៅមុនឆ្នាំ១៩៧៥ ខ្លួនរស់នៅស្រុកស្អាង ខេត្តកណ្តាល និងថាស្ថានការណ៍ នៅទីនោះមានការលំបាកខ្លាំងដោយសារការវាយប្រយុទ្ធគ្នារវាងយោធាខ្មែរក្រហម និងទាហាន លន់ នល់ ។ បន្ទាប់មកនៅក្នុងឆ្នាំ១៩៧២ ក្រុមគ្រួសាររបស់ខ្លួនបានចាកចេញមករស់នៅទីក្រុងភ្នំពេញ រហូតដល់ឆ្នាំ១៩៧៥ ។ ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះបានបន្តទៀតថា នៅអំឡុងពេលរស់នៅទីក្រុងភ្នំពេញ បានឃើញការបាញ់ផ្លោងរបស់យោធាខ្មែរក្រហមសំដៅផ្ទះរបស់សេនាប្រមុខ លន់ នល់ និងឃើញនៅតាមមន្ទីរពេទ្យមានអ្នករងរបួស និងសាកសពពាសពេញទាំងអស់ ។

#### ២.ក.២) ការជម្លៀសដោយបង្ខំ

មេធាវី សុគង់ បានបន្តសួរទាក់ទងនឹងស្ថានភាពនៅពេលដែលយោធាខ្មែរក្រហមចូលមកដល់ទីក្រុងភ្នំពេញ ថាតើនៅមានការប្រយុទ្ធគ្នារវាងទាហានខ្មែរក្រហម និងទាហានរបស់ លន់ នល់ ទៀត ដែរឬយ៉ាងណា? ដើមបណ្តឹងរដ្ឋប្បវេណីបានរៀបរាប់ថា នៅ ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ លែងមានការប្រយុទ្ធគ្នារវាងកងទ័ពខ្មែរក្រហម និងទាហាន លន់ នល់ ទៀតហើយ ដោយសារតែទាហាន លន់ នល់ បានចុះចាញ់ និងទម្លាក់អាវុធ ។ ប៉ុន្តែអ្នកស្រីបានឃើញកងទ័ពខ្មែរក្រហមរំលោភបំពានលើប្រជាជន និងកងទ័ព លន់ នល់ គួរឲ្យភ័យរន្ធត់និងគួរឲ្យព្រឺខ្លាច ។ មេធាវី សុគង់ បានបន្តចោទសួរអ្នកស្រីទៀតថា តើនៅថ្ងៃដដែលនោះ អ្នកស្រី និងក្រុមគ្រួសារ មានត្រូវបានប្រាប់ឲ្យចាកចេញពីលំនៅដ្ឋានដែរឬទេ? ឆ្លើយតបនឹងសំណួរនេះ យឹម សុវណ្ណ បានអះអាងថា នៅរសៀលម៉ោង៣នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ កងទ័ពខ្មែរក្រហមប្រដាប់ដោយអាវុធបានមកដល់ផ្ទះរបស់អ្នកស្រី ហើយបង្ខំឲ្យឪពុកអ្នកស្រីចាកចេញពីផ្ទះដោយអះអាងថា ទាហានអាមេរិកនឹងមកទម្លាក់គ្រាប់បែកនៅក្នុងពេលឆាប់ៗ ។ ឪពុក និងក្រុមគ្រួសាររបស់អ្នកស្រីបានចាកចេញពីផ្ទះដោយមានយកទៅជាមួយនូវអង្ករបន្តិចបន្តួចតែប៉ុណ្ណោះ ។ សុវណ្ណ បន្តថា ការចាកចេញនេះយោធាខ្មែរក្រហមបានទុកពេលឲ្យគ្រួសារអ្នកស្រីរៀបចំឥវ៉ាន់តែរយៈពេល១៥នាទីតែប៉ុណ្ណោះ ។ នៅអំឡុងពេលនៃការជម្លៀសនោះ អ្នកស្រីបានឃើញយោធាខ្មែរក្រហមប្រានទម្លាក់ទាហាន លន់ នល់ ដែលរងរបួសកំពុងសម្រាកព្យាបាលនៅមន្ទីរពេទ្យ នៅឯបុរីកីឡា និងបានឃើញយោធាខ្មែរក្រហមបាញ់សម្លាប់មនុស្សដែលមិនព្រមចាកចេញតាមបទបញ្ជាឲ្យចេញពីផ្ទះរបស់ខ្លួន ។ សុវណ្ណ បញ្ជាក់បន្ថែមថា គ្រួសាររបស់អ្នកស្រីបានចាកចេញពីភ្នំពេញតាមផ្លូវស្ទឹងមានជ័យ ដោយធ្វើដំណើរឆ្ពោះទៅផ្លូវជាតិលេខ៣ ។ នៅតាមផ្លូវមានប្រជាជនរាប់សិបម៉ឺននាក់ ធ្វើដំណើរចាកចេញដោយពុំមានគោលដៅ ហើយអ្នកស្រីបានឃើញកងទ័ពខ្មែរក្រហមបាញ់សម្លាប់ប្រជាជន ឃើញមាន

ការដាក់គ្នាស្លាប់តាមដងផ្លូវ និងឃើញអ្នកជំងឺត្រូវបង្ខំឲ្យធ្វើដំណើរក្នុងចំណោមប្រជាជនដែលត្រូវបានជម្លៀស ហើយមានអ្នកខ្លះត្រូវស្លាប់តាមផ្លូវ ។ ឆ្លើយតបនឹងសំណួររបស់មេធាវី សំ សុគង់ ដែលសួរថា តើមានការព្យាបាលចំពោះអ្នកជំងឺត្រឹមត្រូវដែរឬយ៉ាងណានៅអំឡុងពេលនៃការជម្លៀសនោះ? យឹម សុវណ្ណ បានបញ្ជាក់ថា អ្នកស្រីពុំឃើញមានការព្យាបាលត្រឹមត្រូវសម្រាប់អ្នកជំងឺទេ រីឯសាកសពដែលស្លាប់នៅតាមដងផ្លូវជិតព្រលានយន្តហោះពោធិ៍ចិនតុង ឃើញភាគច្រើនគឺស្លៀកពាក់ជាទាហាន ហើយសាកសពទាំងនោះនៅរាយប៉ាយនៅតាមដងផ្លូវដោយពុំមានការធ្វើបុណ្យ ។ យឹម សុវណ្ណ បានបន្តថា នៅអំឡុងពេលនៃជម្លៀសប្រជាជនចេញពីភ្នំពេញ ពុំមានសមាជិកក្រុមគ្រួសារណាម្នាក់របស់អ្នកស្រីស្លាប់បាត់បង់ជីវិតទេ ។ ប៉ុន្តែ អ្នកស្រីបានទទួលរងការប្រមាថមើលងាយពីសំណាក់យោធាខ្មែរក្រហមថា ជាប្រជាជន ១៧មេសា ។



យោធាខ្មែរក្រហមកំពុងទទួលមេបញ្ជាការរបស់ខ្លួន (ប្រភព ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)

### ២.១) ការសួរដេញដោលដោយមេធាវីនាំមុខអន្តរជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណី

អង្គជំនុំជម្រះផ្តល់វេទិកាសួរដេញដោលបន្តដល់មេធាវីនាំមុខអន្តរជាតិ អេលីហ្សាប៊ែត ស៊ីម៉ូណូហ្វ ដើម្បីសួរបញ្ជាក់ដើមបណ្តឹងរដ្ឋប្បវេណីឡើងវិញអំពីចម្លើយមុនៗដែលឆ្លើយតបនឹងសំណួររបស់មេធាវី សុគង់ និងស្នើឲ្យដើមបណ្តឹងរដ្ឋប្បវេណីរៀបរាប់អំពីទិដ្ឋភាពជាក់ស្តែងនៅក្នុងអំឡុងពេលនៃការជម្លៀស ។

ពាក់ព័ន្ធនឹងការជម្លៀសប្រជាជនដោយបង្ខំ លោកស្រីមេធាវីបានចោទសួរដើមបណ្តឹងរដ្ឋប្បវេណីថា តើយោធាខ្មែរក្រហមមានបានគំរាមកំហែងចំពោះក្រុមគ្រួសារអ្នកស្រីដែរឬទេ នៅពេលបដិសេធមិនព្រមចេញតាមការបញ្ជា? យឹម សុវណ្ណ បានបញ្ជាក់ថា នៅពេលឪពុករបស់អ្នកស្រីស្នើសុំយោធាខ្មែរក្រហមស្នាក់នៅដោយមិនព្រមចាកចេញ យោធាខ្មែរក្រហមបានឆ្លើយតបថា បើមិនព្រមចាកចេញគេនឹងបាញ់សម្លាប់ចោលតែម្តង ដោយសារអ្នកដែលមិនព្រមចាកចេញត្រូវបានចាត់ទុកថាជាខ្មាំង ។ បន្ទាប់មក មេធាវី អេលីហ្សាប៊ែត បានចោទសួរបន្តទាក់ទងនឹងរយៈពេលនៃការជម្លៀស ថាតើអ្នកស្រីត្រូវចំណាយពេលប៉ុន្មានថ្ងៃទើបទៅដល់គោលដៅ? ឆ្លើយតបនឹងសំណួរនេះ យឹម សុវណ្ណ បានអះអាងថា អ្នកស្រីត្រូវចំណាយពេលជិត១ខែទើបទៅដល់ភូមិពោធិ៍បាន ដែលជាកន្លែងខ្មែរក្រហមជម្លៀសទៅ ។

ពាក់ព័ន្ធនឹងពាក្យថា “ប្រជាជន១៧មេសា” យឹម សុវណ្ណ បានបញ្ជាក់ថា គឺជាប្រជាជនដែលត្រូវបានជម្លៀសចេញពីទីក្រុងភ្នំពេញ និងត្រូវបានចាត់ទុកថាជាខ្មាំងវណ្ណៈពួកនាយទុន និងសក្តិភូមិ ។ បន្ទាប់មក នៅចុងឆ្នាំ១៩៧៥ អ្នកស្រីត្រូវបានជម្លៀសជាលើកទី២ទៅខេត្តពោធិ៍សាត់ ហើយអ្នកស្រីបញ្ជាក់ថា ក្នុងចំណោមប្រជាជនដែលត្រូវបានជម្លៀសទាំងអស់នោះ គឺសុទ្ធសឹងតែជាប្រជាជន១៧មេសា ។ ខេត្តពោធិ៍សាត់នេះហើយដែលឪពុក និងប្អូនស្រីរបស់អ្នកស្រីត្រូវបានកម្មាភិបាលខ្មែរក្រហមយកទៅសម្លាប់ដោយចោទប្រកាន់ថាជាខ្មាំងស៊ីរូងផ្ទៃក្នុងនៅក្នុងឆ្នាំ១៩៧៨ ។

បន្ទាប់ពីបញ្ចប់ការសួរដេញដោល មេធាវី អេលីហ្សាប៊ែត ស៊ីម៉ូណូហ្វ បានស្នើសុំការអនុញ្ញាតពីអង្គជំនុំជម្រះដើម្បីសរសេរជាលាយលក្ខណ៍អក្សរនូវសេចក្តីថ្លែងអំពីទុក្ខសោកជូនដើមបណ្តឹងរដ្ឋប្បវេណីដើម្បីជួយសម្រួលក្នុងការរៀបចំពាក្យពេចន៍ ។ ប្រធានអង្គជំនុំជម្រះបានសម្រេចភ្លាមៗ ដោយអនុញ្ញាតឲ្យមេធាវីនាំមុខ

ដើមបណ្តឹងរដ្ឋប្បវេណីអាចធ្វើដូច្នេះបាន ។

គួរកត់សម្គាល់ថាជនរងគ្រោះដែលត្រូវបានទទួលស្គាល់ និងផ្តល់ឋានៈជាដើមបណ្តឹងរដ្ឋប្បវេណី ដោយអង្គជំនុំជម្រះ គឺមានសិទ្ធិថ្លែងអំពីទុក្ខសោករបស់ខ្លួននៅអំឡុងពេលផ្តល់សក្ខីកម្មនៅក្នុងសវនាការ ។ សិទ្ធិនេះក៏មានចែងនៅក្នុងវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧ របស់កម្ពុជាដែរ ។

បន្ទាប់មក អង្គជំនុំជម្រះបានប្រគល់វេទិកាសួរដេញដោលជូនតំណាងសហព្រះរាជអាជ្ញាដើម្បីចោទសួរដើមបណ្តឹងរដ្ឋប្បវេណី ។ តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ឃីត រេនន័រ បានចំណាយពេលត្រឹមតែ១៥នាទីប៉ុណ្ណោះ ក្នុងការសាកសួរ ឃឹម សុវណ្ណ ដោយសួររំឭកឡើងវិញអំពីព្រឹត្តិការណ៍ និងចម្លើយដែលអ្នកស្រីបានឆ្លើយតបនឹងសំណួររបស់មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ។

ដោយសារក្រុមមេធាវីការពារក្តីជនជាប់ចោទទាំងបីក្រុម ពុំមានសំណួរសួរ ឃឹម សុវណ្ណ អង្គជំនុំជម្រះបានបញ្ចប់កិច្ចដំណើរការនីតិវិធីសួរដេញដោលនៅរសៀលថ្ងៃទី១៩ ខែតុលា ឆ្នាំ ២០១២ ។ ប៉ុន្តែ អង្គជំនុំជម្រះបានឱកាសជូនដើមបណ្តឹងរដ្ឋប្បវេណីដើម្បីឡើងថ្លែងអំពីទុក្ខសោក និងការបាត់បង់របស់ខ្លួនដោយសាររបបកម្ពុជាប្រជាធិបតេយ្យនៅព្រឹកថ្ងៃទី២២ ខែតុលា ឆ្នាំ២០១២ ។

### ៣) ការថ្លែងអំពីទុក្ខសោករបស់ដើមបណ្តឹងរដ្ឋប្បវេណី

ដូចជាការជូនដំណឹងរបស់អង្គជំនុំជម្រះ នៅក្នុងសវនាការថ្ងៃទី២២ ខែតុលា ឆ្នាំ២០១២ ឃឹម សុវណ្ណ ត្រូវបានផ្តល់ឱកាសឲ្យឡើងថ្លែងអំពីទុក្ខសោក និងការបាត់បង់របស់ខ្លួននៅអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ នៅមុនពេលចាប់ឡើងថ្លែងអំពីទុក្ខសោក សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានស្នើសុំអង្គជំនុំជម្រះដើម្បីអនុញ្ញាតឲ្យដើមបណ្តឹងរដ្ឋប្បវេណីដែលចូលមកផ្តល់សក្ខីកម្មនៅក្នុងសវនាការ អាចនិយាយអំពីការទទួលរងគ្រោះរបស់ខ្លួនទាក់ទងនឹងសំណុំរឿង០០២ ទាំងមូលតែម្តង គឺមិនមែនត្រឹមតែការទទួលរងដែលមានកំណត់នៅក្នុងដំណាក់កាលនៃសំណុំរឿង០០២/០១នេះទេ ។ ការស្នើសុំដូច្នេះ ត្រូវបានមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីផ្តល់ហេតុផលថា ប្រសិនបើដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានផ្តល់ឱកាសឲ្យថ្លែងអំពីទុក្ខសោករបស់ខ្លួនមួយផ្នែក ហើយទុកមួយផ្នែក គឺពិតជាមានភាពលំបាកណាស់សម្រាប់ជនរងគ្រោះ ដែលមិនមែនជាអ្នកជំនាញ និងមានការយល់ដឹងអំពីនីតិវិធីច្បាប់នៅមានកម្រិត ។ ដូច្នេះនៅពេលខ្លះ ដើមបណ្តឹងរដ្ឋប្បវេណីមិនអាចកំហិតអំពីទុក្ខសោកដែលខ្លួននឹងត្រូវថ្លែងបានឡើយ ។

សំណើដែលស្នើឡើងដោយសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបានគាំទ្រដោយសហព្រះរាជអាជ្ញា ប៉ុន្តែត្រូវបានជំទាស់ដោយក្រុមមេធាវីការពារក្តីជនជាប់ចោទទាំងបីក្រុម ។

បន្ទាប់ពីពិភាក្សាគ្នាអស់រយៈពេលប្រមាណដប់នាទី អង្គជំនុំជម្រះបានសម្រេចថា មេធាវីនាំមុខតំណាងដើមបណ្តឹងគប្បីដាក់សំណើរបស់ខ្លួនជាលាយលក្ខណ៍អក្សរ ដើម្បីឲ្យអង្គជំនុំជម្រះងាយស្រួលក្នុងការវាយតម្លៃអំពីសំណើសុំនោះ ។ ទោះបីជាយ៉ាងណា អង្គជំនុំជម្រះបានសម្រេចអនុញ្ញាតឲ្យ ឃឹម សុវណ្ណ អាចថ្លែងអំពីទុក្ខវេទនា និងការឈឺចាប់របស់ខ្លួនលើរយៈកាលនៃសំណុំរឿង ០០២ទាំងស្រុងតែម្តង ។ អង្គជំនុំជម្រះបានសម្រេចទៀតថា ប្រសិនបើភាគីណាមួយយល់ថា ការថ្លែងរបស់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ពុំមានភាពជាប់ពាក់ព័ន្ធនឹងសំណុំរឿង០០២ នៅត្រង់ផ្នែកណាមួយ នោះភាគីអាចជំទាស់បាននៅពេលដែលដើមបណ្តឹងរដ្ឋប្បវេណីថ្លែងអំពីទុក្ខសោករបស់ខ្លួនរួចរាល់ ។

បន្ទាប់មក អង្គជំនុំជម្រះបានប្រគល់វេទិកាជូន ឃឹម សុវណ្ណ ដើម្បីឡើងថ្លែងអំពីទុក្ខសោក និងការឈឺចាប់របស់ខ្លួន ។

ខាងក្រោម គឺជាសម្រង់ទាំងស្រុងនៃពាក្យថ្លែងទុក្ខសោករបស់ដើមបណ្តឹងរដ្ឋប្បវេណី ៖

*"នៅក្នុងចន្លោះឆ្នាំ១៩៧៥ និង៧៦ នាងខ្ញុំត្រូវគេវាយធ្វើបាប គេចោទខ្ញុំថាជាប្រជាជន ១៧មេសា ទោះបីជាខ្ញុំឈឺក៏គេឲ្យខ្ញុំធ្វើការទាំងមានជំងឺ ដែលនាងខ្ញុំនៅក្មេង ។ នៅតាមសហករណ៍ដែលនាងខ្ញុំបានចេញពីឆ្នាំ១៩៧៥ ជម្លៀសនាងខ្ញុំចេញពីភ្នំពេញទៅនៅក្នុងភូមិឃុំពោធិ៍បាន ភូមិលេខ៥ ឃុំពោធិ៍បាន ស្រុកកោះធំ ។ ពេលនោះនាងខ្ញុំទៅរស់នៅ អ្នក១៧មេសា អ្នកមូល*

ដ្ឋាន១៨មេសាចោទថា នាងខ្ញុំសុទ្ធតែខ្មាំង ប្រើនាងខ្ញុំដោយអត់អាហារ ហូបតែគល់ជ្រៃស្ងោរ គ្មានកម្លាំងធ្វើការ ។ នាងខ្ញុំសុខចិត្តលះបង់សេចក្តីឈឺចាប់ និងការស្លាប់ដើរសន្សំពោត សូម្បីតែពោតក៏គេថានាងខ្ញុំជាចោរលួចពោត ។ គ្មានបាយហូប ពេលធ្វើការពេលណាហូបតែម្សៅជ្រៃ ។ ទឹកភ្នែកខ្ញុំហូរ សុខចិត្តឈឺចាប់ខ្លោចផ្សាវេទនា ។ រហូតនាំនាងខ្ញុំទៅដាក់នៅកងនារី នាងខ្ញុំឈឺគេវាល់ឲ្យខ្ញុំហូបបាយមួយវែក ។ ឪពុករបស់នាងខ្ញុំដឹងថាខ្ញុំឈឺ សុខចិត្តទៅតាមឲ្យនាងខ្ញុំមកផ្ទះ ខ្ញុំមកអត់បាន១៥នាទី ប្រធានកងនារីតាមឲ្យខ្ញុំទៅវិញ គេចោទថាខ្ញុំកងសេរី គ្មានច្បាប់គ្មានទម្លាប់ ។ សួរថាវិបត្តិផ្លូវចិត្តរបស់ខ្ញុំជិតដាមរហូតដល់សព្វថ្ងៃ ។ ខ្ញុំឈឺចាប់ ពេលណាខ្ញុំនឹកឃើញរឿងដែលខ្ញុំចេញទៅភ្នំពេញពេលណា គឺខ្ញុំរន្ធត់តក់ស្លុតអស់នូវអ្វីក្នុងខ្លួនរបស់ខ្ញុំ ។ ធ្វើការទាំងយប់ទាំងថ្ងៃ ។ នាងខ្ញុំ មនុស្សប្រជាជនដែលល្អ សុខចិត្តធ្វើឲ្យខ្លួនអាក្រក់លួចសន្សំដើម្បីក្រពះរស់នៅក្រុមគ្រួសារ ។

ទី២ ពេលមុនជម្លៀសខ្ញុំមុនឆ្នាំ១៩៧៦ គេចោទនាងខ្ញុំលួចស្រូវថានាងខ្ញុំអាក្រក់ឲ្យខ្ញុំទៅប្រូតស្រូវកន្លែងផ្សេង គេថាខ្ញុំហ្នឹងខ្ជិលប្រអូស បានតែងាប់ ។ ខ្ញុំសុខចិត្តស្រក់ទឹកភ្នែក ខំធ្វើការដើម្បីដូរនឹងបាយបបរមួយវែក ។ ហើយគេថាឲ្យនាងខ្ញុំថាមិនបាច់ជម្លៀសទៅលើកទី២ទេ នាងខ្ញុំប្តេជ្ញាចិត្តថា បើអត់ឲ្យនាងខ្ញុំទៅជួបម៉ែឪខ្ញុំ ជម្លៀសលើកទី២ ខ្ញុំសុខចិត្តរត់ សុខចិត្តស្លាប់ដើម្បីទៅតាមម៉ែឪខ្ញុំ ។

បាត់បង់ទ្រព្យសម្បត្តិ អស់គោក្របី ដីស្រែចម្ការ ។ នៅក្នុងឆ្នាំ១៩៧៨ ឪពុករបស់នាងខ្ញុំឈ្មោះ តូច ស៊ុំ ប្អូនជីដូនមួយរបស់ឪពុកខ្ញុំ និងក្មួយប្រុសរបស់ឪពុកខ្ញុំ ព្រមទាំងប្អូនស្រីរបស់នាងខ្ញុំ ខ្មែរក្រហមបានយកទៅវាយចោលនៅមន្ទីរ០៧ ទាំងយប់ដោយចោទថា សុទ្ធតែខ្មាំង ឪពុករបស់នាងខ្ញុំ និងប្អូន ។ ខ្ញុំមិនអាចយំបានដោយឃើញទិដ្ឋភាពនៅផ្ទាល់នឹងភ្នែក គេចងស្លាបសេក ហើយគេស្រែកអាក្រោសនៅតាមថ្នល់ ហើយគេបើកមីទ្ទីងថាជាខ្មាំង ។ តើខ្ញុំអ្នក១៧មេសា សុខចិត្តឱនសម្រក់ទឹកភ្នែកនឹងដី អត់ហ៊ានងើតងើបមុខនៅចំពោះអង្គមីទ្ទីងនៅក្នុងសហករណ៍ទាំងមូល ។ ភ័យរន្ធត់ ជីវិតខ្ញុំថ្ងៃរស់បានពេលយប់ឡើងជីវិតរបស់ក្រុមគ្រួសារសនាងខ្ញុំភ័យរន្ធត់ យប់ឡើងគេនឹងយកវៃចោលទៀត ។

ពាក្យស្លោករបស់អង្គការ "ដកស្មៅ ដកទាំងឫស មិនឲ្យទុក" ខ្ញុំទុក្ខវេទនារកអ្វីមកប្រៀបផ្ទឹមពុំបាន រន្ធត់ ឈឺចាប់ ដោយខ្លួននៅស្ទើរ ហើយឆ្លងកាត់នូវទុក្ខសោកគ្រប់ពេលគ្រប់វេលា ។ ភ្នែករបស់នាងខ្ញុំពេលដែលឃើញឪពុករបស់នាងខ្ញុំ កងឈ្លប ប៉ុល ពត ចងនៅនឹងមុខ ព្រោះដោយសារតែបាក់បែកព្រាត់ប្រាសគ្រួសារបងប្អូន ឪពុកម្តាយ បន្ទុកនៅលំបាកគ្មានទីពឹងរកស៊ីចិញ្ចឹមប្អូនប្រុសស្រី និងម្តាយដោយខ្លួនឯង ការលំបាកទាំងនេះធ្វើឲ្យនាងខ្ញុំចូលមន្ទីរពេទ្យរុស្ស៊ីផ្នែកវិបត្តិផ្លូវចិត្ត មានអារម្មណ៍ខ្វះយ មានវិបត្តិបញ្ហាបេះដូង និងយល់សុបិនអាក្រក់នៅនឹងភ្នែក ។ ខ្ញុំបាក់បែក បាត់បង់ទ្រព្យសម្បត្តិជាច្រើន ព្រោះតែអំឡុងពេលខ្មែរក្រហម ។ ខ្ញុំឈឺចាប់ណាស់ ព្រោះខ្ញុំកើតមកជាតិនេះ ជួបតែរឿងអភ័ព្វ ជួបតែរឿងវិនាសអន្តរាយក្នុងសង្គម គ្មានការចេះដឹងគ្មានរៀន ជួបតែរឿងវិបត្តិអសីលធម៌ រឿងអាក្រក់នៅចំពោះជីវិតរបស់នាងខ្ញុំជួបតែរឿង គ្មានធនធានមនុស្ស តើជីវិតនាងខ្ញុំចង់ចេះដឹង ចង់យល់អំពីសង្គម រៀន ខ្ញុំចង់ថា ខ្ញុំរៀនអ្វីឲ្យល្អនៅរស់នៅក្នុងសង្គមឲ្យមានជីវិតថ្លៃថ្នូរ ប៉ុន្តែនាងខ្ញុំដោយអវិជ្ជាមិនបានរៀនសូត្រ បំណងប៉ងត្រូវរលាយបាត់ដោយសារស្រមោលអន្តរកាល ទុកនូវវិបត្តិឈឺចាប់ តម្កល់មួយជីវិតរបស់នាងខ្ញុំរហូត ។

ដោយសារវិបត្តិផ្លូវចិត្តខាងលើ នាងខ្ញុំសម្រេចស្វែងទៅរកព្រះធម៌ សម្រេចចិត្តទៅបួស ដើម្បីរម្ងាប់នូវវិបត្តិផ្លូវចិត្តដល់ពេលបច្ចុប្បន្ននេះ ។ បានរម្ងាប់ផ្លូវចិត្តមួយទៀត ដោយសារតុលាការកូនកាត់ជាតិ និងអន្តរជាតិ ជំនុំជម្រះទោសនូវពួកគ្មានសីលធម៌ ។ នាងខ្ញុំមានជំនឿទុកចិត្ត ភាពកក់ក្តៅលើការកាត់ក្តីចំពោះមេដឹកនាំទាំងអស់នាពេលខាងមុខ ឲ្យស្វែងរកយុត្តិធម៌ជូនជនរួមជាតិទាំងអស់ ដែលមានគ្រោះអាក្រក់នៅក្នុងសង្គម និងខ្ញុំ តាងនាមខ្ញុំជាជនរងគ្រោះ ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ ខ្ញុំគ្មានយោបល់អ្វី និងវែងឆ្ងាយទេ ព្រោះនាងខ្ញុំបានសម្រេចចិត្តថា មានតែផ្លូវសុខហើយនិងស្ងប់ ហើយនាងខ្ញុំ មិនអាចមានសង្ឃឹមថា ពេលមុនមកនាងខ្ញុំថា មិនសង្ឃឹមថាខ្ញុំប្រឈមមុខនៅចំពោះតុលាការជាតិ និងអន្តរជាតិទេ ។ ប៉ុន្តែនាងខ្ញុំពេលនេះ បានមានមុខ មានវត្តមានប្រឈមមុខនូវចំពោះមុខតុលាការជាតិ និងអន្តរជាតិ ។ នាងខ្ញុំ

សូមថ្លែងអំណរគុណចំពោះគុណ ចំពោះតុលាការជាតិ និងអន្តរជាតិ ដែលរកយុត្តិធម៌ឲ្យនាងខ្ញុំ ។ តាងនាមឲ្យប្រជាជនទូទាំងប្រទេសជាដើមបណ្តឹងរដ្ឋប្បវេណី ព្រោះនាងខ្ញុំមានតែជំងឺផ្លូវចិត្តបៀមទុកជាយូរអង្វែងមកហើយ មិនដឹងថ្លែងវាចារប្រាប់អ្នកណាថា អ្វីល្អ អ្វីអាក្រក់ ។ ខ្ញុំដឹងថាប្រជាជនទាំងអស់ ជនរងគ្រោះប៉ុន្តែតិចនិងច្រើន តែងតែមានហើយ ។ ប៉ុន្តែទិដ្ឋភាពនៅពេល៧៥ រហូតដល់៧៩ គឺឲ្យនាងខ្ញុំយល់ច្បាស់នូវអ្វីល្អ អ្វីអាក្រក់រហូតដល់សព្វថ្ងៃនេះ ។ ហើយនាងខ្ញុំសង្ឃឹមថា តុលាការជាតិ និងអន្តរជាតិ ជួយរកយុត្តិធម៌ តើអ្វីល្អអ្វីអាក្រក់ ។ តើវិបត្តិផ្លូវចិត្តរបស់ប្រជាជន និងតំណាងនាងខ្ញុំ តំណាងដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ បាត់បង់នូវផ្លូវចិត្ត ។ នាងខ្ញុំគ្មានអ្វីថ្លែងច្រើនទេ នាងខ្ញុំថ្លែងតែប៉ុណ្ណឹង ។

នាងខ្ញុំសូមអរគុណចំពោះតុលាការជាតិ និងអន្តរជាតិ ហើយសូមអរគុណ និងលោកប្រធានជាទីគោរព ។

សូមបញ្ជាក់ថា សវនាការសួរដេញដោលដើមបណ្តឹងរដ្ឋប្បវេណី យឹម សុវណ្ណ បានបញ្ចប់នៅ វេលាម៉ោង១០ព្រឹកថ្ងៃទី២២ ខែតុលា ឆ្នាំ២០១២ ។ បន្ទាប់មក អង្គជំនុំជម្រះបានបន្តសួរដេញដោល ដើមបណ្តឹងរដ្ឋប្បវេណីមួយរូបទៀតគឺ ជុំ សុខា ។

### ៤) ប្រវត្តិសាវតាររបស់ដើមបណ្តឹងរដ្ឋប្បវេណី ជុំ សុខា

ដើមបណ្តឹងរដ្ឋប្បវេណី ជុំ សុខា កើតនៅថ្ងៃទី១ ខែមករា ឆ្នាំ១៩៥៥ និងមានទីកន្លែងកំណើត នៅភូមិត្បូងក្តី ឃុំដំរីពួន ស្រុកព្រៃវែង ខេត្តព្រៃវែង ។ បច្ចុប្បន្នកំពុងរស់នៅភូមិព្រែកដាច់ ស្រុកលើកដែក ស្រុកលើកដែក ខេត្តកណ្តាល ។ ដើមបណ្តឹងរដ្ឋប្បវេណីមានឪពុកឈ្មោះ ជុំ សារុន និងម្តាយឈ្មោះ យុគ ជន និងមានភរិយាឈ្មោះ គួច កញ្ញា មានកូនបីនាក់ ។

#### ៤.ក) ព្រឹត្តិការណ៍មុនឆ្នាំ១៩៧៥

ដើមបណ្តឹងរដ្ឋប្បវេណី ជុំ សុខា បានរៀបរាប់ថា នៅមុនឆ្នាំ១៩៧៥ លោកបានមករស់នៅម្តុំពោធិ៍ចិនតុង ហើយស្ថានការណ៍នៅពេលនោះ គឺមានការប្រយុទ្ធជារៀងរាល់ថ្ងៃរវាងទាហាន លន់ នល់ និងយោធាខ្មែរក្រហមដើម្បីដណ្តើមយកទីតាំងកាន់កាប់ ដោយមានការបាញ់ផ្លោង និងមានប្រជាជនរបួស និងស្លាប់ជារៀងរាល់ថ្ងៃ ។

#### ៤.ខ) ស្ថានភាពនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥

ឆ្លើយតបនឹងសំណួររបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ទី ស្រ៊ីណា ទាក់ទងនឹងព្រឹត្តការណ៍នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ជុំ សុខា បានរៀបរាប់ថា នៅព្រឹកថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ វេលាម៉ោង៩ព្រឹក កងទ័ពខ្មែរក្រហមបានចូលមកដល់ទីក្រុងភ្នំពេញ ដោយមានឮសម្លេងកាំភ្លើង ហើយប្រជាជននាំគ្នារស់ឈូឆរចុះឡើងតាមបណ្តោយផ្លូវ និងមានខ្លះនៅឈរអមតាមសងខាងផ្លូវ ។ អ្នកដែលឈរទាំងនោះមានទាំងទាហាន លន់ នល់ ដែលបាក់ទ័ពដោះអាវចេញនៅសល់តែខោជ៉ាវ៉ា ឬខោទាហាន និងមានកាន់កន្សែងសនៅនឹងដៃ ។ បន្ទាប់មកទើបមានរថក្រោះ និងឡានមកតាមក្រោយជាបន្តបន្ទាប់ ។ ជុំ សុខា បានរំឭកថា មានក្រុមកងទ័ពខ្មែរក្រហម កាន់មេក្រូដើរស្រែកប្រាប់ប្រជាជនថា "បងប្អូនប្រជាជនទីក្រុងភ្នំពេញទាំងអស់ គឺអត់មានទោសមានពៃរ៍អីទេ ។ បងប្អូនប្រកបការងារអ្វីតាមចិត្តទៅរកស៊ីអីក៏តាមចិត្តទៅ ។ ប៉ុន្តែអង្គការយកទោសតែបនក្បត់ប្រាំពីរក្បាលទេ មាន លន់ នល់, សិរិមតៈ, អ៊ិន តាំ, ចេង ហេង,......" ។ ប៉ុន្តែវេលាម៉ោងបីរសៀល ខ្មែរក្រហមបានដើរស្រែកប្រកាសថា "សូមអញ្ជើញបងប្អូន ពុកម៉ែទាំងអស់អញ្ជើញចេញពីទីក្រុងភ្នំពេញជាបន្ទាន់រយៈពេលបីថ្ងៃសិន ព្រោះពេលយប់នេះ ឬក៏



ដើមបណ្តឹងរដ្ឋប្បវេណី ជុំ សុខា
(ប្រភព : មជ្ឈមណ្ឌលឯកសារកម្ពុជា)

បន្តិចទៀតនេះ អាចមានកប៉ាល់ ហោះខាងកងទ័ពអាមេរិកាំងគេមកទម្លាក់គ្រាប់បែកលើទីក្រុងភ្នំពេញ» ។ ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ បានបញ្ជាក់ទៀតថា គ្រួសាររបស់លោកត្រូវបានបង្ខំឲ្យចាកចេញពីផ្ទះដោយត្រូវធ្វើដំណើរតាមផ្លូវជាតិលេខ៤ ។ នៅតាមដងផ្លូវមានសាកសពជាច្រើនដោយពុំមានគ្រួសារមកយកទៅធ្វើបុណ្យ ។ ចំណែកឯ អ្នករបួសនៅតាមមន្ទីរពេទ្យ ដែលរបួសក្បាល ធ្លាយពោះ បាក់ជើង ដោយពុំមានពេទ្យព្យាបាល ។


យុវជន និងយុវនារី ក្នុងកងចល័តខ្មែរក្រហមកំពុងប្រមូលផលដំណាំ(ប្រភព : មជ្ឈមណ្ឌលឯកសារកម្ពុជា)

## ៨.ក) ជីវិតក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ

ទាក់ទងនឹងស្ថានភាពរស់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ចន្លោះឆ្នាំ១៩៧៥ និង១៩៧៩ ជុំ សុខា បានបញ្ជាក់ថា បន្ទាប់ពីការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ គ្រួសាររបស់លោកត្រូវបានជម្លៀសទៅដល់ស្រុកកំណើត គឺនៅភូមិត្បូងក្តី ។ នៅទីនោះលោកត្រូវបានអង្គការបង្ខំឲ្យជីកទំនប់លើកភ្លឺស្រែ ដកស្ទូង ភ្ជួររាស់ ដោយពុំមានអាហារគ្រប់គ្រាន់ដើម្បីបរិភោគ ។ នៅពេលឈឺ ថ្នាំដែលខ្មែរក្រហមយកមកដើម្បីព្យាបាល គឺជាថ្នាំមួយប្រភេទដែលមានរូបរាងដូចជាអាចម៍ទន្សាយ ដោយត្រូវប្រើប្រាស់គ្រប់ជំងឺ ។ សុខា រូបនេះបានបន្តថា អង្គការបានបង្ខំឲ្យលោកធ្វើការមួយថ្ងៃរហូតទៅដល់១២ ឬ១៤ម៉ោង ។

## ៩) សេចក្តីថ្លែងអំពីទុក្ខសោក និងការទទួលរងរបស់ដើមបណ្តឹងរដ្ឋប្បវេណី ជុំ សុខា

បន្ទាប់ពីភាគីបានបញ្ចប់ការសួរដេញដោល អង្គជំនុំជម្រះបានផ្តល់ឱកាសជូនដើមបណ្តឹងរដ្ឋប្បវេណី ជុំ សុខា ឡើងថ្លែងអំពីការទទួលរងគ្រោះ និងទុក្ខសោក ដោយសាររបបកម្ពុជាប្រជាធិបតេយ្យ ។ ជុំ សុខា បានចំណាយប្រហែល២៥នាទី ដើម្បីថ្លែងអំពីសេចក្តីទុក្ខសោក និងការទទួលរងរបស់ខ្លួន ដោយរៀបរាប់យ៉ាងលម្អិតអំពីភាពឈឺចាប់ និងការបាត់បង់ នៅអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ និងបានស្នើសុំឲ្យតុលាការធ្វើការផ្តន្ទាទោសមេដឹកនាំខ្មែរក្រហមឲ្យបានធ្ងន់ធ្ងរ ។

ខាងក្រោមនេះ គឺជាសំណូមពររបស់ដើមបណ្តឹងរដ្ឋប្បវេណីជូនអង្គជំនុំជម្រះ ៖

«អ៊ីចឹងខ្ញុំសំណូមពរថា ជាចុងក្រោយ សំណូមពរជាចុងក្រោយ សូមតុលាការធ្វើការផ្តន្ទាទោសពួកមេដឹកនាំខ្មែរក្រហមដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មយង់ឃ្នងមកលើក្រុមគ្រួសារខ្ញុំ និងប្រជាជនខ្មែរស្លូតត្រង់ទូទាំងប្រទេសកម្ពុជាទៅតាមច្បាប់ឲ្យបានធ្ងន់ធ្ងរ ឲ្យសមនឹងកំហុសរបស់ពួកគេ ។ ហើយចំពោះសំណង ខ្ញុំចង់ស្នើសុំតុលាការទាមទារពីជនជាប់ចោទ និងសូមឲ្យតុលាការស្រាវជ្រាវទ្រព្យសម្បត្តិរបស់ជនជាប់ចោទយកមកសងសមូហភាព ។ ហើយរឿងទាមទារសំណងនេះ ខ្ញុំសូមទុកឲ្យមេធាវីខ្ញុំជាអ្នកចាត់ចែងជំនួស ។ ហើយសំណូមចុងក្រោយ សូមឲ្យប្រជាពលរដ្ឋកម្ពុជា ក៏ដូចជាអន្តរជាតិចូលរួមគាំទ្រទាំងស្មារតីសម្ភារៈដល់សាលាក្តីខ្មែរក្រហម ដើម្បីជួយជំរុញដំណើរការក្តីនេះឲ្យបានចប់សព្វគ្រប់ជាស្ថាពរ ។»

# សវនាការស្តីពីការស្តាប់សក្ខីកម្មសាក្សី សុខ ឈិន

## ថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១២

អង្គជំនុំជម្រះសាលាដំបូងបានប្រកាសបន្តសវនាការសាកសួរសាក្សី សុខ ឈិន នៅព្រឹកថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១២ ។ នៅមុនពេលចាប់ផ្តើម ប្រធានអង្គជំនុំជម្រះបានប្រកាសថា ជនជាប់ចោទ អៀង សារី បានស្នើសុំលះបង់សិទ្ធិក្នុងការស្តាប់សក្ខីកម្មសាក្សីចំនួន១០រូប និងដើមបណ្តឹងរដ្ឋប្បវេណីចំនួន៦រូប ដែលក្នុងនោះរួមមានសាក្សី សុខ ឈិន មួយរូបដែរ ។ សវនាការសាកសួរសាក្សី សុខ ឈិន បានផ្តោតទៅលើស្ថានភាពនៅពេលជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ទំនាក់ទំនងយោធា និងការងាររបស់ជនជាប់ចោទនៅស្ថានីយរថភ្លើង ។ ចាប់ផ្តើមសាកសួរ គឺធ្វើឡើងដោយប្រធានអង្គជំនុំជម្រះ តំណាងសហព្រះរាជអាជ្ញា មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីការពារក្តី ប៉ុន្តែសវនាការនេះមិនចំណាយពេលសាកសួរច្រើនទេ ដោយសារមេធាវីការពារក្តី នួន ជា និង ខៀវ សំផន ពុំមានសំណួរ ។

### ១) ការសាកសួរសាក្សីដោយអង្គជំនុំជម្រះ

ចៅក្រម និល ណុន បានចាប់ផ្តើមសាកសួរសាក្សីនូវសំណួរមួយចំនួនដែលទាក់ទងនឹងប្រវត្តិសាវតាររបស់សាក្សីដោយសាក្សីបានបញ្ជាក់ថា ខ្លួនមានអាយុ៦៧ឆ្នាំ រស់នៅក្រុមសាមគ្គីភូមិកំពង់ក្របី ឃុំស្វាយប៉ោ ស្រុកបាត់ដំបង ខេត្តបាត់ដំបង សព្វថ្ងៃខ្លួនគឺជានិវត្តន៍ជន ។ សាក្សីបានបន្តថា ខ្លួនមានឪពុកឈ្មោះ សុខ ស៊ុក និងម្តាយឈ្មោះ យិន នួន ប្រពន្ធឈ្មោះ គ្រួច សារើយ និងមានកូន៥នាក់ ។ បន្ទាប់មក អង្គជំនុំជម្រះបានផ្តល់វេទិកាសាកសួរជូនតំណាងសហព្រះរាជអាជ្ញាដើម្បីបន្ត ។

### ២) ការសាកសួរដោយតំណាងសហព្រះរាជអជ្ញា

#### ២.១) តំណាងសហព្រះរាជអាជ្ញាជាតិ

តំណាងសហព្រះរាជអាជ្ញាជាតិ វ៉េង ហ៊ត់ បានចាប់ផ្តើមតាំងសំណួរដំបូងដោយការដាក់ឯកសារជាក្រដាសជូនសាក្សីពិនិត្យ ហើយសំណួរដំបូងគឺទាក់ទងនឹងស្ថានភាពក្រោយថ្ងៃ ១៧ មេសា ។ សាក្សីបានរៀបរាប់ថា នៅពេលនោះខ្លួនធ្វើជាកម្មករជួសជុលផ្លូវដែកនៅរោងជាងស្វ័យយានក្រោមការគ្រប់គ្រងរបស់យោធាខ្មែរក្រហមឈ្មោះ តាម៉ុម ដែលជាអ្នកគ្រប់គ្រងនារី និងកុមារនៅក្នុងតំបន់នេះទាំងអស់ ។ ការគ្រប់គ្រងនៅក្នុងន័យនេះ គឺសំដៅដល់ការបង្ខំឲ្យធ្វើការ និងការរៀនសូត្រពីនយោបាយបក្សកុម្មុយនីសកម្ពុជា ។

ចំពោះការរស់នៅវិញ គឺមានការបែងចែកដោយកុមាររស់នៅ និងធ្វើការនៅកន្លែងផ្សេងពីឪពុកម្តាយ ។ បន្ទាប់មក តំណាងសហព្រះរាជអាជ្ញាជាតិបានលើកឡើងនៅក្នុងឯកសារដដែលដើម្បីឲ្យសាក្សីពន្យល់នូវឃ្លាមួយថា “បើរថភ្លើងក្រឡាប់ គេនឹងយកយើងទៅវាយចោល” សាក្សីបានបន្តថា ចំពោះឃ្លានេះ តាម៉ុម ធ្លាប់បង្រៀនឲ្យចេះប្រយ័ត្នប្រយែងក្នុងពេលធ្វើការងារ ហើយបើរថភ្លើងក្រឡាប់នឹងត្រូវយកទៅសម្លាប់ចោលមិនខាន ។

ទាក់ទងនឹងរបបអាហារវិញ សាក្សីបានរៀបរាប់ថា មានមនុស្សរាប់ពាន់នាក់ត្រូវបានជម្លៀសចេញពីភ្នំពេញ ហើយរបបអាហារនៅពេលនោះមិនស្មើគ្នាទេ គឺអាស្រ័យទៅលើកន្លែងធ្វើការផ្សេងៗគ្នា ។ អ្នកជំងឺនៅពេលនោះត្រូវបញ្ជូនទៅមន្ទីរពេទ្យ ប៉ុន្តែមិនអនុញ្ញាតឲ្យមានអ្នកទៅមើលថែឡើយ ។ ឆ្លើយតបនឹងសំណួរបន្ទាប់ទាក់ទងនឹងការរៀនសូត្រ សាក្សីបានបញ្ជាក់ថា ខ្លួនធ្លាប់



សាក្សី សុខ ឈិន
(ប្រភព ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)

ឃើញ តាម៉ុម ជិះរថភ្លើងមកចូលរួមប្រជុំនៅទីក្រុងភ្នំពេញដោយសារខ្លួនធ្វើការនៅតាមផ្លូវដែក ហើយពេលត្រឡប់ទៅវិញ តាម៉ុម តែងតែហៅអ្នកនៅក្រោមបង្គាប់ឲ្យមករៀនសូត្រជានិច្ច ។ ការសិក្សារៀនសូត្រនោះគឺ ពង្រឹងគោលជំហររបស់បដិវត្តន៍ និងណែនាំឲ្យប្រជាជនខំធ្វើការងារ ។

ចំណែកខាងទំនាក់ទំនងយោធាវិញ តំណាងសហព្រះរាជអាជ្ញាបានដកស្រង់ឃ្លានៅក្នុងឯកសារឆ-១៩ ដែលនិយាយអំពីការបញ្ជូនសាក្សីឲ្យទៅនៅលាច ខេត្តពោធិ៍សាត់ ។ ជាការឆ្លើយតប សាក្សីបានបញ្ជាក់ថា មួយរយៈក្រោយមក ខ្លួនត្រូវបានបញ្ជូនពីបាត់ដំបងមកខេត្តពោធិ៍សាត់ ក្រោមការគ្រប់គ្រងរបស់តាម៉ុម ។ សាក្សីបានបន្តថា មានប្រជាជនជាច្រើននាក់ត្រូវបានដឹកតាមរថភ្លើងមកដាក់ចោលនៅ ផ្លូវលាច ដោយមានប្រជាជនខ្លះឈឺ និងពុំមានអាហារបរិភោគ ។ សាក្សីបានបន្ថែមថា នៅពេលជម្លៀសនោះមានប្រជាជនច្រើនចម្រុះគ្នារួមទាំងជនជាតិចាម និងទាហានលន់នល់ ដែរ ។

## ២.២) តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ

បន្ទាប់ពីបញ្ចប់ការសាកសួរសាក្សីដោយតំណាងសហព្រះ-រាជអាជ្ញាជាតិរួចមក តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ថារីក អាប់ឌុលហាក់ បានបន្តសំណួរទាក់ទងនឹងការងាររបស់សាក្សីនៅមុនឆ្នាំ១៩៧៥ និងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ។ សាក្សីបានបញ្ជាក់ថា ខ្លួនជាអ្នកលក់សំបុត្ររថភ្លើងនៅខេត្តបាត់ដំបង ស្រុកមោងឫស្សី ក្រោយមកក៏បានផ្លាស់ទៅនៅស្រុកស្វាយស៊ីសុផុន ចាប់ពីឆ្នាំ១៩៧០រហូតដល់ឆ្នាំ១៩៧៥ទើបខ្លួនត្រូវបានបញ្ជូនឲ្យទៅនៅខេត្តពោធិ៍សាត់ នៅឃុំត្រពាំងជង ដោយទទួលខុសត្រូវខាងផ្លូវដែកប្រវែង២១គីឡូម៉ែត្រ ។ ឆ្លើយតបនឹងសំណួរបន្ទាប់ សាក្សីបានបញ្ជាក់ថា តាម៉ុម គឺជាប្រធានតំបន់ ចំណែកខ្លួនគឺជាប្រធានឃុំ ។ សាក្សីបានបន្តថា រថភ្លើងនៅកន្លែងដែលខ្លួនធ្វើការនោះមានទូរពី២០-២៥ ហើយក្នុងមួយទូរៗដឹកមនុស្សប្រហែល៤០នាក់រួមមានទាំងស្ត្រី និងកុមារត្រូវដឹកចេញពីភ្នំពេញទៅតាមខេត្តផ្សេងៗរហូតដល់ចុងឆ្នាំ១៩៧៥ ។ ឆ្លើយតបនឹងសំណួរមួយចំនួនទៀត សាក្សីបានបញ្ជាក់ថា ក្នុងពេលជម្លៀសនោះ ប្រជាជនពុំមានអាហារហូបចុកគ្រប់គ្រាន់ទេ ហើយពេលនោះខ្លួនក៏មិនហ៊ាននិយាយសួរនាំអ្វីដល់ប្រជាជនទាំងនោះឡើយ ។

បន្ទាប់មក តំណាងសហព្រះរាជអាជ្ញាបានបន្តសំណួររបស់ខ្លួនទាក់ទងនឹងចំនួនរទេះភ្លើង និងចំនួនមនុស្សដែលធ្វើដំណើរដើម្បីឲ្យសាក្សីបញ្ជាក់ ។ សាក្សីបានរៀបរាប់ថា ខ្លួនបានឃើញរទេះភ្លើង២ដងក្នុងមួយសប្តាហ៍ ប៉ុន្តែខ្លួនមិនបានដឹងពីចំនួនរទេះភ្លើងច្បាស់លាស់ទេ គ្រាន់តែដឹងថា រទេះភ្លើងទាំងនោះបានបន្សល់ទុកតាំងពីរបបសង្គមរាស្ត្រនិយម ។ អ្នកដែលគ្រប់គ្រងរថភ្លើងគឺនៅភ្នំពេញ ។ តាម៉ុម ត្រូវទទួលខុសត្រូវចំពោះរថយន្តពីរកន្លែងគឺនៅរមាស និងមានតួនាទីរាយការណ៍ទៅថ្នាក់លើនៅពេលមានប្រជុំម្តងៗ ។

សាក្សីបានបន្ថែមទៀតថា ការគ្រប់គ្រងនៅស្ថានីយរថភ្លើងគឺមានការបែងចែកតួនាទីជាប្រធានខ្សែរថភ្លើង ដែលមាននាទីធ្វើដំណើរតាមរថភ្លើងរហូត ហើយអ្នកគ្រប់គ្រងគឺជាជនស៊ីវិល ចំណែកប្រធានស្ថានីយ គឺជាអ្នកទទួលរថភ្លើង ពេលមកដល់ស្ថានីយ ។

# ៣) ការសាកសួរដោយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី

## ៣.១) មេធាវីជាតិ

បន្ទាប់ពីបញ្ចប់ការសាកសួររបស់តំណាងសហព្រះរាជអាជ្ញា ប្រធានអង្គជំនុំជម្រះបានផ្ទេរវេទិកាជូនមេធាវីជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណី វ៉ែន ពៅ ដើម្បីធ្វើការតាំងសំណួរទៅកាន់សាក្សី សុខ ឈិន ជាបន្ត ។ មេធាវីជាតិចាប់ផ្តើមសួរទាក់ទងនឹងសមាជិកក្រុមការងារដែលធ្វើការនៅកន្លែងជាមួយសាក្សី ។ សាក្សីបានបន្តថា សមាជិកនៅកន្លែងខ្លួនមានចំនួន១៨នាក់ជាបុគ្គលិកដែលធ្វើការតាំងពីជំនាន់មុន ប៉ុន្តែក្រោយមកមានយោធា៣នាក់ទៀតនៅមើលការងារពីលើ ។ ឆ្លើយតបនឹងសំណួរបន្ទាប់របស់មេធាវីទាក់ទងនឹងការជម្លៀសប្រជាជនដោយបង្ខំ នោះសាក្សីបានបញ្ជាក់ថា ការជម្លៀសមានពីរដំណាក់កាល ។ ទីមួយ នៅខែមេសា ឆ្នាំ១៩៧៥ និងទីពីរ នៅចន្លោះខែតុលា ដល់ខែធ្នូ ឆ្នាំ១៩៧៥ ហើយពេលជម្លៀសម្តងៗ ខ្លួនមិនដែលឃើញមានព្រះសង្ឃទៅជាមួយទេ ដោយសារលោកសង្ឃត្រូវបានផ្សឹកតាំងពីមុនពេលជម្លៀសមកម្ល៉េះ ។ ជាចុងក្រោយ មេធាវីបានបន្តសាកសួរអំពី

មេដឹកនាំខ្មែរក្រហម ហើយសាក្សីបានបញ្ជាក់ថា ខ្លួនធ្លាប់ឮឈ្មោះមេដឹកនាំខ្មែរក្រហមតាមរយៈការចូលរួមប្រជុំរៀនសូត្រ ប៉ុន្តែមិនដែលស្តាប់ឮតាមរយៈវិទ្យុទេ ដោយសារនៅពេលនោះខ្លួនពុំមានវិទ្យុសម្រាប់ស្តាប់ ។

### ៣.២) មេធាវីអន្តរជាតិ

មេធាវីអន្តរជាតិ ស៊ីម៉ូណូហុត បានបន្តសំណួរអំពីការរក្សាទុកបុគ្គលិកដែលនៅសល់ពីជំនាន់មុនឲ្យ នៅធ្វើការនៅស្ថានីយរថភ្លើង ។ សាក្សីបានបញ្ជាក់ថា ខ្មែរក្រហមបានចាត់តាំងឲ្យ អ៊ំព្រឿង បន្តធ្វើការងារនៅស្ថានីយដដែលដោយសារគាត់ជាប្រធានបច្ចេកទេសរថភ្លើង ។ នៅពេលរថភ្លើងដឹកមនុស្សម្តងៗ គឺមានចំនួនច្រើន ប៉ុន្តែនៅកន្លែងផ្សេងនោះខ្លួនមិនបានដឹងទេ ។ សាក្សីបានបន្តថា ស្ថានភាពប្រជាជននៅពេលនោះ គឺមានការលំបាកច្រើន ការរស់នៅគ្មានអនាម័យ គឺមានតែទឹកស្រែសម្រាប់ហូបប៉ុណ្ណោះ ។ ចំពោះខ្លួនផ្ទាល់ គឺមានសម្រាប់តែផ្គត់ផ្គង់ខ្លួនឯងប៉ុណ្ណោះ ។ សាក្សីបន្តរៀបរាប់ថា នៅពេលនោះ ខ្លួនធ្លាប់ពិភាក្សាជាមួយអ្នករួមការងារអំពីភាពលំបាក និងការអាណិតអាសូរចំពោះប្រជាជនទាំងនោះ ប៉ុន្តែខ្លួនមិនហ៊ាននិយាយពីហេតុផលអ្វីច្រើនទេដោយសារពេលនោះមានការរិតត្បិតការនិយាយស្តី ដោយប្រើពាក្យថា “ដាំដើមគរ” ។

បន្ទាប់ពីបញ្ចប់ការសាកសួររបស់ដើមបណ្តឹងរដ្ឋប្បវេណី ប្រធានអង្គជំនុំជម្រះបានប្រកាសជូនដំណឹងអំពីការកែប្រែការជំនុំជម្រះ ខណៈពេលដែលអង្គជំនុំជម្រះមានការខ្វះខាតថវិការ ដោយសារអង្គការសហប្រជាជាតិមានការកាត់បន្ថយបុគ្គលិកអន្តរជាតិ ដូច្នេះអង្គជំនុំជម្រះមិនអាចបន្តបើកសវនាការរយៈពេលបួនថ្ងៃក្នុងមួយសប្តាហ៍បាននោះទេ គឺត្រូវកាត់បន្ថយមក៣ថ្ងៃក្នុងមួយសប្តាហ៍វិញ ដោយចាប់ផ្តើមអនុវត្តចាប់ពីថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ ២០១២ ។ ភ្លាមនោះ មេធាវីអន្តរជាតិ ហ្សាស្តើប៉ៅ បានក្រោកឈរដើម្បីស្នើសុំឲ្យជនជាប់ចោទ នួន ជា ស្នើសុំទៅសម្រាកនៅខាងក្រោមដូចសព្វដង ។ ចំណែកជនជាប់ចោទ ខៀវ សំផន តាមរយៈមេធាវីជាតិ គង់ សំអុន បានស្នើសុំចូលរួមសវនាការនៅបន្ទប់ខាងក្រោមដោយសារ ខៀវ សំផន មិនអាចសម្រាកបានក្នុងរយៈពេលប៉ុន្មានយប់កន្លងមក ។ អង្គជំនុំជម្រះបានអនុញ្ញាតចំពោះ ខៀវ សំផន គឺដោយយោងតាមអនុសាសន៍របស់វេជ្ជបណ្ឌិតក្នុងការអនុញ្ញាតឲ្យ ខៀវ សំផន ទៅសម្រាកនៅបន្ទប់ខាងក្រោមដោយសារគាត់មានបញ្ហាញ័រសាច់ ។ ចំណែកសំណើរបស់ជនជាប់ចោទ នួន ជា ក៏ធ្វើឡើងដោយសមហេតុផល ដូច្នេះអង្គជំនុំ



ប្រជាជនកំពុងចោមរោមមើលរថក្រោះរបស់របប លន់ នល់ ដែលរងការខូចខាតនៅក្បែរអាគារមហោស្រពភ្នំពេញ (បច្ចុប្បន្នជាអាគារមជ្ឈមណ្ឌលភ្នំពេញ) (ប្រភព ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)

ជម្រះបានអនុញ្ញាតឲ្យជនជាប់ចោទទាំងពីរទៅសម្រាកនៅបន្ទប់ខាងក្រោមក្នុងពេលជាមួយគ្នា ។

បន្ទាប់មក ចៅក្រម ហ្សង់ម៉ាក ឡាវ៉ើញ បានបន្តការសាកសួរសាក្សីទាក់ទងនឹងគោលដៅដែលខ្មែរក្រហមដឹកប្រជាជនតាមរទេះភ្លើងទៅតំបន់ផ្សេងៗ ប៉ុន្តែសាក្សីបានបញ្ជាក់ថា ខ្លួនមិនដឹងអំពីទីតាំងទាំងនោះទេ ប៉ុន្តែជាទូទៅអ្នកទាំងនោះត្រូវបានដឹកទៅដាក់ឲ្យនៅតាមសហករណ៍ ។

## ៤) ការសាកសួរដេញដោលដោយក្រុមមេធាវីការពារក្តី

### ៤.១) មេធាវីការពារការពារក្តី នួន ជា

មេធាវីបានចាប់ផ្តើមការតាំងសំណួរទាក់ទងនឹងពេលវេលានៃការផ្តល់សម្ភាសន៍ជាមួយសហចៅក្រមស៊ើបអង្កេតដោយពេលនោះសាក្សីបានមើលឯកសារ ។ មេធាវីបានស្នើទៅអង្គជំនុំជម្រះឲ្យបញ្ឈប់ការអានឯកសាររបស់សាក្សី ។ បន្ទាប់មកសាក្សីបានបញ្ឈប់ការអានដោយបញ្ជាក់ថាខ្លួនមិនចាំថាពេលណាមួយនោះទេ ប្រហែលជាអំឡុងឆ្នាំ២០០៨ ឬ២០០៩ ។ សាក្សីបានបញ្ជាក់ទៀតថា ខ្លួនមិនចាំអំពីអ៊ីដែលខ្លួនបាននិយាយជាមួយសហចៅក្រមស៊ើបអង្កេតនោះទេ ដោយគ្រាន់តែនៅចាំថា មុនពេលសម្ភាសន៍សហចៅក្រមស៊ើបអង្កេតបានជួបសម្ភាសន៍ជាមួយអ៊ំ ព្រឿង ប៉ុន្តែខ្លួនមិនដឹងថាបទសម្ភាសន៍នោះនិយាយអំពីអ៊ីនោះទេ ។ សាក្សីបានបន្តថា ខ្លួនធ្លាប់ធ្វើការជាមួយ អ៊ំ ព្រឿង ពេញក្នុងមួយរយៈពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ដោយសារអ៊ំ ព្រឿង មាននាទីត្រួតត្រាផ្នែកបច្ចេកទេសខាងស្ពាន និងអគារ ។ មេធាវីអន្តរជាតិបានលើកឡើងម្តងហើយម្តងទៀតទាក់ទងនឹងការសម្ភាសន៍ អ៊ំ ព្រឿង និងសាក្សីដោយមិនមានការថតសម្លេងនៅពេលចៅក្រមស៊ើបអង្កេតសម្ភាសន៍ ប៉ុន្តែករណីនេះត្រូវបានចៅក្រម និល ណុន រំឭកដោយលើកឡើងនូវវិធាន៧៦(៧) ថានីតិវិធីនៃការស៊ើបអង្កេតនឹងអាចត្រូវធ្វើការកែប្រែនៅក្នុងវិធានផ្ទៃក្នុងប្រសិនបើមានបណ្តឹងឧទ្ធរណ៍ ដូច្នេះអង្គជំនុំជម្រះមិនអនុញ្ញាតឲ្យលើកឡើងពីបញ្ហានេះទេ ។ មេធាវីបានបញ្ជាក់ថា ខ្លួនគ្រាន់តែចង់ដឹងពីប្រភពពត៌មានដែលសាក្សីបានដឹងតែប៉ុណ្ណោះ ។



ប្រជាជនកំពុងធ្វើដំណើរត្រឡប់ទៅស្រុកកំណើតរបស់ខ្លួនវិញ ក្រោយការដួលរលំនៃរបបខ្មែរក្រហមនៅខែមករា ឆ្នាំ១៩៧៩ (ប្រភព ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)

បន្ទាប់មក មេធាវីបានបន្តសំណួរថា តើសាក្សីបានស្គាល់ នួន ជា តាមរបៀបណា? សាក្សីបានបញ្ជាក់ថា ខ្លួនទើបតែដឹងនៅពេលមើលទូរទស្សន៍ម្តងៗ គឺមិនមែននៅក្នុងពេលដែល នួន ជា កាន់អំណាចនោះទេ ហើយខ្លួនក៏មិនបានយកបញ្ហាតួនាទីរបស់ នួន ជា ទៅជជែកជាមួយបុគ្គលផ្សេង ឬសមាជិកគ្រួសារផ្សេងទៀតដែរ ។ សាក្សីបានបន្តថា ពេលខ្លួនធ្វើការនៅ២១គីឡូនោះ ខ្លួនបានពិនិត្យមើលការងារជួសជុលជារៀងរាល់ថ្ងៃដោយធ្វើដំណើរតាមឈូរី ។ បន្ទាប់មក មេធាវីបានបន្តសំណួរទាក់ទងនឹងសិទ្ធិអំណាចរបស់ តាម៉ូម ហើយសាក្សីបានបញ្ជាក់ថា ខ្លួនមិនបានដឹងអំពីសិទ្ធិរបស់ តាម៉ូម ដល់កំរិតណានោះទេ ប៉ុន្តែ ខ្លួនបានគោរពរាល់កិច្ចការដែល តាម៉ូម បញ្ជា ។ ឆ្លើយតបនឹងសំណួរបន្ទាប់ សាក្សីបានបញ្ជាក់ថា ទាក់ទងនឹងឯកសារដែលនិយាយអំពីការបញ្ជារថភ្លើងនោះ ខ្លួនមិនធ្លាប់ឃើញឡើយ ។ នៅពេលបញ្ចប់ សាក្សីបន្ថែមថាបញ្ជានៅក្នុងរបប ប៉ុល ពត គឺយកតាមលំនាំរបបសង្គមរាស្ត្រនិយមខ្លះ ដោយសាររាល់បញ្ជាគឺ ធ្វើតាមថ្នាក់លើនៅភ្នំពេញ ។

បន្ទាប់មក អង្គជំនុំជម្រះបានបញ្ចប់ការសាកសួរសាក្សី សុខ ឈិន ភ្លាមៗដោយសារមេធាវីការពារក្តី នួន ជា និង ខៀវ សំផន ពុំមានសំណួរដើម្បីសាកសួរសាក្សីទៀតទេ ។

# សវនាការស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណី ឡាយ បូនី

## ថ្ងៃទី២៣-២៤ ខែតុលា ឆ្នាំ២០១២

នៅរសៀលថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១២ អង្គជំនុំជម្រះសាលាដំបូងបានបន្តបើកសវនាការស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណី ឡាយ បូនី បន្ទាប់ពីការបញ្ចប់សក្ខីកម្មសាក្សី សុខ ឈិន ។ ការស្តាប់សក្ខីកម្ម ឡាយ បូនី ដែលជាជនរងគ្រោះនៃរបបកម្ពុជាប្រជាធិបតេយ្យ បានផ្តោតសំខាន់លើចំណុចមួយចំនួនដូចជា ស្ថានភាពទីក្រុងភ្នំពេញមុនការចូលមកដល់នៃកងទ័ពខ្មែរក្រហម ព្រឹត្តិការណ៍ជម្លៀសថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ ការជម្លៀស ឡាយ បូនី ទៅតាមបណ្តាខេត្តនានាដូចជាខេត្តកណ្តាល កំពង់ឆ្នាំង និងពោធិ៍សាត់ និងស្ថានភាពរស់នៅក្នុងមន្ទីរសន្តិសុខ ។ គួរបញ្ជាក់ថា ការស្តាប់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីបានចំណាយពេលជិតពីរថ្ងៃ គឺចាប់ផ្តើមនៅរសៀលថ្ងៃទី២៣ និងបញ្ចប់ទៅវិញនៅរសៀលថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១២ ។ នៅរសៀលថ្ងៃដដែល សាក្សី គង់ គីម ត្រូវបានកោះហៅមកផ្តល់សក្ខីកម្មភ្លាមៗ បន្ទាប់ពីដើមបណ្តឹងរដ្ឋប្បវេណី ឡាយ បូនី បានបញ្ចប់នូវការថ្លែងទុក្ខសោករបស់ខ្លួន ដែលទទួលរងពីព្យសនកម្មនៃរបបខ្មែរក្រហម ។

### ១) ប្រវត្តិសាវតារដើមបណ្តឹងរដ្ឋប្បវេណី ឡាយ បូនី

ឡាយ បូនី កើតនៅថ្ងៃទី២០ ខែមិនា ឆ្នាំ១៩៥០ នៅសង្កាត់លេខ៤ ក្រុងភ្នំពេញ ។ បច្ចុប្បន្ន អ្នកស្រីរស់នៅភូមិត្រពាំងឈូក ផ្លូវ៣៧១ សង្កាត់ទឹកថ្លា ក្រុងភ្នំពេញ និងជាមេផ្ទះ ។ ឪពុកឈ្មោះ ឡាយ គ្រុយ (ស្លាប់) និងម្តាយឈ្មោះ យុត ស៊ី (ស្លាប់) ។ សព្វថ្ងៃអ្នកស្រីមានស្វាមីឈ្មោះ ចាន់ សារិន និងមានកូន៣នាក់ ។

### ២) ការសួរដោលដោយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី

ក្រុមមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបានប្រគល់វេទិការសួរដេញដោលដើមបណ្តឹងរដ្ឋប្បវេណី ឡាយ បូនី មុនភាគីផ្សេងទៀតដោយអង្គជំនុំជម្រះ ។ មេធាវី ម៉ុច សុវណ្ណារី បានចាប់ផ្តើមសំណួររបស់ខ្លួន ដោយផ្តោតលើកំណត់ហេតុស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងបានប្រគល់ឯកសារមួយចំនួនជូនទៅអ្នកស្រី បូនី ដើម្បីពិនិត្យផ្ទៀងផ្ទាត់ ។ មេធាវីបានសួរផ្តោតសំខាន់ទៅលើបីចំណុច ។ ទី១ស្ថានភាពក្រុមគ្រួសារមុនការមកដល់ទីក្រុងភ្នំពេញនៃទ័ពខ្មែរក្រហម ទី២អង្គហេតុនៃការចេញពីទីក្រុង និងទីបីជីវភាពរស់នៅក្រោយពេលជម្លៀសទៅស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល រហូតដល់ស្រុកបាកាន ខេត្តពោធិ៍សាត់ ។

### ២.ក) ព្រឹត្តិការណ៍មុនពេលខ្មែរក្រហមចូលកាន់កាប់ទីក្រុងភ្នំពេញ

នៅមុនថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ទីក្រុងភ្នំពេញមានភាពច្របូកច្របល់ពីព្រោះមានគ្រាប់កាំភ្លើងផ្លោងចូលទីក្រុងភ្នំពេញ ។ ដោយសារស្ថានភាពប្រទេសជាតិមានសភាពវិកវរបែប



ដើមបណ្តឹងរដ្ឋប្បវេណី ឡាយ បូនី
(ប្រភព : មជ្ឈមណ្ឌលឯកសារកម្ពុជា)

នេះ ឡាយ បូនី មិនអាចទៅសម្រាលបុត្រនៅមន្ទីរពេទ្យបានទេ ហើយបង្ខំចិត្តសម្រាលបុត្រនៅផ្ទះ ។ ក្រោយពេលសម្រាលបុត្រហើយ ឡាយ បូនី មានជម្ងឺគ្រុនញាក់ ចំណែកកូនប្រុសទីបីបានស្លាប់ភ្លាមៗ ។ នៅពេលនោះ ឡាយ បូនី មានស្វាមីឈ្មោះ ប្រាក់ ស៊ីណាត ធ្វើជាទាហានសក្តិ៣ នៅក្នុងរបបសាធារណៈរដ្ឋ ទទួលបន្ទុកផ្នែកសន្តិសុខនៅបរិវេនផ្ទះរបស់ លន់ នល់ ។ សេនាប្រមុខ លន់ នល់ បានចាកចេញពីប្រទេសកម្ពុជាទៅហើយ ស្វាមីរបស់ បូនី

ពុំសូវរវល់នឹងការងារខ្លាំងទេ គ្រាន់តែទៅបង្ហាញខ្លួនម្តងៗ ពីព្រោះ ស្ថានភាពក្នុងប្រទេសជាតិច្របូកច្របល់ខ្លាំង ដូច្នេះស្វាមីរបស់ បូនី ក៏សម្រេចចិត្តបោះសម្លៀកបំពាក់ទាហានចោល ព្រមទាំងបានដឹក លេណ្ឌាន និងរៀបចំស្បៀង ។

## ២.១) ព្រឹត្តិការណ៍ជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ

នៅពេលដែលទ័ពខ្មែរក្រហមបានចូលមកដល់ទីក្រុងភ្នំពេញ ភ្លាម គឺមានការបញ្ជាឲ្យប្រជាជនចេញពី ផ្ទះសម្បែង ។ ឡាយ បូនី ត្រូវបានយោធាខ្មែរក្រហមដែលស្លៀកពាក់ខ្មៅ មានស្ពាយកាំភ្លើង និងប្រើសំដីម៉ាត់ៗ បានចូលមកប្រាប់ឲ្យចាកចេញពីផ្ទះ ។ នៅក្នុងព្រឹត្តិការណ៍ជម្លៀស ប្រជាជនចេញពីទីក្រុងភ្នំពេញ ឡាយ បូនី ប្រទះឃើញសាកសពស្លាប់នៅតាមផ្លូវ ដែលមានទាំងការ បញ្ជូន អ្នកជម្ងឺចេញពីមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀតទាំងសេរ៉ូម កំពុងព្យួរ និងខ្លះកំពុងសម្រាកលើគ្រែ ។ ពេលទៅដល់ឃុំស្វាយ ប្រទាល ឡាយ បូនី បានឃើញយោធាខ្មែរក្រហម ប្រកបដោយ ទឹកមុខមាំៗ និងមានក្រសែភ្នែករវាសមើលឆ្វេងស្តាំ និងមិនខ្វល់ ពីអ្នកជំងឺឡើយ ។ កងទ័ពទាំងនោះគិតតែពីជម្រុញឲ្យប្រជាជន ចេញឲ្យអស់ពីទីក្រុងប៉ុណ្ណោះ ។ អ្នកស្រីបានឃើញសាកសព ប្រជាជនជាច្រើននៅតាមផ្ទះនីមួយៗ ដែលជាសាកសពថ្មីៗមិន ទាន់មានក្លិនស្អុយនៅឡើយ ។ អ្នកស្រីមានជំងឺគ្រុនញាក់មិនអាច បន្តដំណើរទៅមុខបានទៀត ដូច្នេះបានស្នាក់នៅទីនោះមួយរយៈ ហើយកូនរបស់ខ្លួនមានជំងឺរាកមួលចេញឈាមប្រចាំកាយ ។ បូនី បានត្រឡប់ទៅរកក្រុមគ្រួសាររបស់ខ្លួននៅស្រុកខ្សាច់កណ្តាល ប៉ុន្តែយោធាគ្រប់គ្រងនៅឃុំស្វាយប្រទាលមិនអនុញ្ញាតឲ្យខ្លួនទៅ ទេ ។ ឡាយ បូនី បានលួចរត់ចាកចេញពីទីនោះចំនួន៤ដង (៤ យប់) ទើបអាចចេញទៅបាន ។ បូនី បានរៀបរាប់ បើទោះបីជាខ្លួន មិនធ្លាប់ធ្វើស្រែចម្ការកន្លងមកក៏ដោយ ប៉ុន្តែនៅក្នុងរបបខ្មែរ ក្រហម ខ្លួនបានព្យាយាមធ្វើស្រែយ៉ាងខ្លាំង ដោយសារតែខ្លាច គេនាំយកទៅសម្លាប់ចោល ។ ស្របពេលជាមួយគ្នានោះ យន ដែលជាប់សាច់ញាតិរបស់ខ្លួន តែងតែព្យាយាមលាក់អត្តសញ្ញាណ របស់ខ្លួន និងក្រុមគ្រួសារ ដោយសារតែខ្លាចអង្គការនាំខ្លួនទៅ បាត់ដូចបងប្អូនផ្សេងទៀតដែរ ។

មេធាវី ម៉ុច សុវណ្ណារី បានបន្តសំណួរដោយផ្តោតលើការ ផ្លាស់ប្តូរទីលំនៅរបស់ដើមបណ្តឹងរដ្ឋប្បវេណីទៅខេត្តបាត់ដំបង ។ មេភូមិម្នាក់មានឈ្មោះ ប៉ាត បានប្រាប់ បូនី ឲ្យរៀបចំឥវ៉ាន់ដើម្បី ចាកចេញពីខេត្តកណ្តាល ទៅខេត្តបាត់ដំបង ។ ពេលឮដូច្នេះ បូនី មានការសប្បាយរីករាយ ដោយសារគិតថា ខេត្តបាត់ដំបង ជា ខេត្តសម្បូរដោយស្រូវអង្ករ ។ ក្នុងអំឡុងពេលនៃការធ្វើដំណើរ ឡាយ បូនី បានឃើញកប៉ាល់ធំៗចំនួន៣ ដែលមានផ្ទុកមនុស្ស រាប់ពាន់នាក់ ហើយការធ្វើដំណើរនោះមានលក្ខណៈរហ័សរហួន ណាស់ ព្រោះប្រញាប់ទៅដល់កំពង់ឆ្នាំងមុនពេលយប់ ។ ឡាយ បូនី ធ្វើដំណើរទៅខេត្តពោធិ៍សាត់ មិនមែនទៅខេត្តបាត់ដំបងនោះទេ ។ បូនី និយាយថា ឲ្យតែដល់រដូវដកស្ទូងគឺជារដូវដែលពុំមានបាយ ហូបនោះទេ ។ នៅស្រុកបាកាន ខេត្តពោធិ៍សាត់ ការរស់នៅរបស់ ប្រជាជនមិនបានយកចិត្តទុកដាក់ទេ នៅជិតភូមិរបស់ខ្លួន ប្រជាជន បានកាប់ព្រៃឫស្សីធ្វើភូមិហើយប្រជាជនជាច្រើនបានស្លាប់យ៉ាង រន្ធត់ ជាពិសេសនៅពេលឈឺគឺពុំមានថ្នាំឡើយ ។

មេធាវីអន្តរជាតិ ស៊ីម៉ុណូហ្វូត បានសួរទាក់ទងនឹងការ ជម្លៀសដំបូងចេញពីភ្នំពេញ ការចូលរួមប្រជុំជីវភាព និងការណែ នាំពីការបង្កបង្កើនផល ។ ឡាយ បូនី បានរៀបរាប់ពីការបាត់បង់ ក្រុមគ្រួសារចំនួនសមាជិកដប់នាក់ ការបាត់បង់សិទ្ធ ការបែងចែក ប្រជាជនចាស់ និងប្រជាជនថ្មី ។ បូនី បានរៀបរាប់បន្តទៀត ថា រហូតមកដល់ពេលនេះសមាជិកគ្រួសារនៅសល់តែពីរនាក់ ប៉ុណ្ណោះ ។

## ២.៣) ការចាប់ខ្លួនស្វាមីរបស់ដើមបណ្តឹងរដ្ឋប្បវេណី

ដើមបណ្តឹងរដ្ឋប្បវេណី ឡាយ បូនី បានបំភ្លឺជូនអង្គជំនុំជម្រះ ទាក់ទងនឹងការចាប់ប្តីរបស់ខ្លួនទៅក្នុងមន្ទីរកែប្រែ ។ បូនី មិនដឹងពី មូលហេតុដែលនាំឲ្យខ្មែរក្រហមដឹងពីសាវតាស្វាមីរបស់ខ្លួននោះទេ នៅពេលដែលអង្គការហៅខ្លួន និងប្តីទៅដល់មន្ទីរសន្តិសុខ គឺមាន មនុស្ស៣-៤នាក់ចេញមកធ្វើទារុណកម្មស្វាមីរបស់ខ្លួន រហូត ចេញឈាមហើយសួរថា "កាំភ្លើងខ្លីលាក់ទុកនៅឯណា?" ។ ក្រោយមកប្តីរបស់ បូនី ត្រូវបានបញ្ជូនទៅក្នុងគុកងងឹត និងធ្វើ ទារុណកម្ម ចំណែក បូនី ដែលគ្រាន់តែទៅតាមស្វាមីនោះ មាន ទោសស្រាលជាង គឺអាចចេញក្រៅទៅធ្វើការ ហើយហូបបបរ បាន ។ ដើមបណ្តឹងរដ្ឋប្បវេណី បូនី បានបញ្ជាក់ទៀតថា នៅក្នុង

គុកនោះ ខ្មែរក្រហមបានចាប់ស្វាមីរបស់ខ្លួនបញ្ចូលទៅក្នុងគុកងងឹត ក្រោយមកបានសម្លាប់នៅក្នុងមន្ទីរឃុំឃាំងនោះ ។ អ្នកស្រីបានបន្តទៀតថា ខ្លួនបានឃើញផ្ទាល់ភ្នែក គឺមានយោធាម្នាក់ ដែលគេស្គាល់ថា ជាកូនរបស់ឈ្មោះ ឃិន ដែលជាប្រធានគុក ដែលនៅក្មេងស្ពាយកាំភ្លើងអូសដីបានហៅឈ្មោះ ខេង ចេញទៅហើយចោទថា ខេង បានលួចត្រីអាំង ។ ក្មេងនោះបានយកអាវុធដំពុះទង់ចាក់ចំចុងដង្ហើមធ្លាយចេញពោះវៀនមកខាងក្រៅស្លាប់ភ្លាម ។ ប៊ូនី ខំព្យាយាមខ្ទប់មាត់មិនហ៊ានស្រែកទេ ព្រោះខ្លាចគេចាប់យកទៅដែរ ។ បើយោងតាមអ្នកនៅជាប់ក្នុងមន្ទីរឃុំឃាំងជាមួយគ្នាបានប្រាប់អ្នកស្រីថា ការសម្លាប់បែបនេះគឺមានស្ទើររៀងរាល់ថ្ងៃ ចាប់ពីឆ្នាំ១៩៧៥មកម្ល៉េះ ហើយជារៀងរាល់បីថ្ងៃម្តង ខ្មែរក្រហមបាននាំយកមនុស្សទៅសម្លាប់ចោលពី១០០ ទៅ ២០០នាក់ នៅកន្លែងមួយដែលគេហៅថាភាគគឺនៅ ក្នុងមន្ទីរឃុំឃាំងនោះតែម្តង ។ ដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ជាក់បន្ថែមថា បើសរុបចំនួនប្រជាជន ដែលត្រូវបានសម្លាប់នៅក្នុងមន្ទីរឃុំឃាំងនេះរហូតដល់ចុងឆ្នាំ១៩៧៧ មានចំនួនប្រហែល១០ម៉ឺននាក់ ។

## ៣) ការសួរដេញដោលដោយសហព្រះរាជអាជ្ញា

តំណាងសហព្រះរាជអាជ្ញា វ៉ាំងសង់ ដឺវ៉ាល់ បានសួរបញ្ជាក់អំពីអត្តសញ្ញាណស្វាមីរបស់ដើមបណ្តឹងរដ្ឋប្បវេណីឡើងវិញ និងរំឭកអំពីព្រឹត្តិការណ៍ជម្លៀសនៅទីក្រុងភ្នំពេញ ។ ដើមបណ្តឹងរដ្ឋប្បវេណីបានរៀបរាប់ទាក់ទងនឹងការបោកបញ្ឆោតរបស់កម្មាភិបាលខ្មែរក្រហម ក្នុងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ។ ប៊ូនី បានបន្តថា ដំបូងខ្មែរក្រហមបានប្រាប់ឲ្យចាកចេញពីផ្ទះតែ៣ថ្ងៃទៅ៧ថ្ងៃ ប៉ុណ្ណោះ ដូច្នេះ ប្រជាជនជឿជាក់ថា ជាការពិត ព្រោះមិននឹកស្មានថា មាក៏អង្គការលោតផ្លោះដល់ថ្នាក់ហ្នឹងទេ ។ កងទ័ពខ្មែរក្រហមមិនបានណែនាំឲ្យប្រជាជននាំយកថ្នាំពេទ្យទៅជាប់នឹងខ្លួន ឬពុំមានការចាយវាយប្រាក់កាសនោះឡើយ ហើយបង្ខំប្រជាជនចាកចេញឲ្យផុតពីទីក្រុងភ្នំពេញ ។ ដើមបណ្តឹងរដ្ឋប្បវេណី ប៊ូនី បានបន្តជម្រាបជូនអង្គជំនុំជម្រះទៀតថា យោធាខ្មែរក្រហមគឺជាសត្រូវរបស់ទាហាន លន់ នល់ ព្រោះតាមការសង្កេតឃើញរបស់ខ្លួនក្នុងពេលជម្លៀសប្រជាជនចេញពីទីក្រុង ខ្មែរក្រហមសម្លាប់ទាហាន លន់ នល់ ភ្លាមៗនៅពេលដែលរកឃើញស្នាមក្រិនជើង ដោយសារតែពាក់ស្បែកជើងអាមេរិក ។ ប៊ូនី ត្រូវបានយោធាខ្មែរក្រហមបញ្ជាឲ្យបោះកាបូប ដែលមានពណ៌ដូចជាពណ៌ដែលទាហានប្រើប្រាស់ ។ យោធាខ្មែរក្រហមបានប្រើល្បិចប្រកាសឲ្យអ្នកធ្វើទាហាននៅក្នុងរបប លន់ នល់ ចូលមកភ្នំពេញវិញ ។ ដូច្នេះបងប្រុសរបស់ខ្លួនបានត្រឡប់ទៅភ្នំពេញវិញ ហើយ



កងនារីកំពុងត្បាញសូត្រក្នុងរបបកម្ពុជាប្រជាធិប

ក្រោយមកមិនដែលឃើញត្រឡប់មករកគ្រួសារវិញឡើយ ។ ដូច្នេះ ប៊ូនី គិតថាជាការចាញ់បោកខ្មែរក្រហម ។ ប៊ូនី បានឃើញយោធាខ្មែរក្រហមមិនត្រឹមតែសម្លាប់ទាហាន លន់ នល់ ប៉ុណ្ណោះទេ ថែមទាំងសម្លាប់ជនស៊ីវិលទៀតផង ដែលជាក់ស្តែងកូនក្មេងនៅក្នុងអង្រឹងក៏សម្លាប់ដែរ ។

តំណាងសហព្រះរាជអាជ្ញាជាតិ ចាន់ ដារ៉ាវស្មី បានសួរលម្អិតឡើងវិញត្រង់ចំណុចខ្លះៗទាក់ទងនឹងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ រយៈពេលរស់នៅក្នុងមន្ទីរឃុំឃាំង ជីវភាពនៅតាមសហករណ៍ដែលដើមបណ្តឹងរដ្ឋប្បវេណីត្រូវជម្លៀសទៅ

និងការប្រជុំស្វ័យទិតៀនជាដើម ។

### ៤) ការសួរដេញដោលដោយមេធាវីការពារក្តី នួន ជា

មេធាវី សុន អរុណ បានធ្វើការតាំងសំណួរដោយផ្តោតសំខាន់ លើការប្រជុំស្វ័យទិតៀននៅសហករណ៍ត្រាចក្រោល ដែលពាក់ព័ន្ធនឹងការសម្លាប់មនុស្ស ។ ឡាយ បូនី បានបញ្ជាក់ជូនថា



...បតេយ្យ (ប្រភព ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្លួនពិតជាបានឃើញការសម្លាប់អ្នកទោសម្នាក់នៅត្រាចក្រោល បន្ទាប់ពីប្រកាសឲ្យប្រជាជនដឹងថា អ្នកទោសម្នាក់នោះព្យាយាមរត់គេចខ្លួន ។ ខ្មែរក្រហមបានកាត់ក្បាលអ្នកទោសម្នាក់នោះចោល ហើយដើមបណ្តឹងរដ្ឋប្បវេណីបានឃើញក្បាលរបស់អ្នកទោសនោះធ្លាក់មកលើដីដោយផ្ទាល់ភ្នែក ។ បន្ទាប់មក មេធាវីបានសួរបញ្ជាក់ឡើងវិញទាក់ទងនឹងចំនួនអ្នកទោស ដែលត្រូវបានសម្លាប់ដែលមានចំនួនប្រហែល ១០ម៉ឺននាក់ ។ មេធាវីបានលើកយកឯកសារ ដែលជាបទសម្ភាសន៍ដែលដើមបណ្តឹងរដ្ឋប្បវេណីបានធ្វើកន្លងមកត្រង់ចំណុច ដែលបានស្នើសុំឲ្យតុលាការខ្មែរក្រហមនេះធ្វើការផ្តន្ទាទោសមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម និងជនបរទេស ។ មេធាវីបានសួរដើមបណ្តឹងរដ្ឋប្បវេណីធ្វើការបញ្ជាក់ពីជនបរទេសទាំងនោះ ។ បូនី បានជម្រាបជូនអង្គជំនុំជម្រះថាការអនុវត្តបញ្ជារបស់ខ្មែរក្រហម គឺធ្វើជាប្រព័ន្ធមិនមែនត្រឹមតែមេកង មេតំបន់ គណៈឃុំនោះទេ ។ អ្នកទទួលខុសត្រូវគឺនៅពីក្រោយខ្នង មានទាំងជនបរទេសដែរ ជាក់ស្តែងគឺបរទេសបានផ្តល់ជំនួយជាឡានដឹកប្រជាជន និងសម្លៀកបំពាក់ដែលមិនមែនជារបៀបខ្មែរ ដូច្នេះខ្លួនមានការសង្ស័យ ទើបទាមទារឲ្យតុលាការកូនកាត់នេះជួយស្វែងយល់ និងរកយុត្តិធម៌ជូនជនរងគ្រោះទាំងអស់ ។

មេធាវីអន្តរជាតិ ហ្សាស្តី ប៉ៅ ការពារក្តីជនជាប់ចោទ នួន ជា បានបន្តការតាំងសំណួរបន្តពីសហភាគីរបស់ខ្លួនឡើងវិញ ដោយសង្កត់ធ្ងន់ទៅលើព្រឹត្តិការណ៍នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ ១៩៧៥ និងស្ថានភាពច្របូកច្របល់នៅមុនថ្ងៃនោះ ដែលទាក់ទងនឹងជនភៀសខ្លួនចូលមករស់នៅក្នុងទីក្រុងភ្នំពេញ ។ បន្ទាប់មក មេធាវីបានសួរបញ្ជាក់ពីរយៈពេលក្រោយរបស់ខ្មែរក្រហមដែលដួលរលំ ដើម្បីបញ្ជាក់ថា រដ្ឋាភិបាលនៅរបបរដ្ឋកម្ពុជាបានប្រើប្រាស់ផ្ទះរបស់ម្តាយមីង ឡាយ បូនី ធ្វើជាក្រសួងការបរទេស ។ គួរបញ្ជាក់ថា បន្ទាប់ពីក្រុមមេធាវីការពារក្តី នួន ជា បានបញ្ចប់ការតាំងសំណួររបស់ខ្លួន ដោយសារក្រុមមេធាវីការពារ ក្តី អៀង សារី និង ខៀវ សំផន ពុំមានសំណួរសួរដើមបណ្តឹងរដ្ឋប្បវេណី ដូច្នេះអង្គជំនុំជម្រះបានផ្ទេរ វេទិការជូនដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីថ្លែងនូវទុក្ខសោកដែលទទួលរងពីរបបខ្មែរក្រហម ។ ខាងក្រោមនេះ គឺជាសេចក្តីចម្លងទាំងស្រុងនៃការថ្លែងនូវទុក្ខសោករបស់ ឡាយ បូនី ៖

“ចាស៎! នាងខ្ញុំសូមអរគុណ ។ ក្នុងនាមនាងខ្ញុំជាដើមបណ្តឹងរដ្ឋប្បវេណី នាងខ្ញុំមានការសប្បាយរីករាយ ហើយនេះជាឱកាសមួយដ៏ល្អបំផុត ដែលរយៈពេលជាង៣០ឆ្នាំហើយ ដែលនាងខ្ញុំបានដក់ទុកនូវការឈឺចាប់ពេញនៅក្នុងខួរក្បាល នៅក្នុងបេះដូង និងនៅក្នុងខ្លួនខ្ញុំ ។ ហើយដោយសារមានតុលាការហ្នឹង ទើបនាងខ្ញុំបានឡើងមកសម្តែងនូវការឈឺចាប់ទាំងអស់នេះចាស៎ ។ ចាប់តាំងពីថ្ងៃ១៧ មេសាឆ្នាំ៧៥ គឺថាខ្ញុំចាប់ផ្តើមមានទុក្ខរហូត គឺថាទុក្ខនោះ

ទុក្ខធំ ដែលខ្ញុំមិនដែលជួបប្រទះសោះ គឺថាត្រូវជម្លៀសចេញពីទីក្រុងភ្នំពេញ ចោលផ្ទះសម្បែង ព្រាត់ប្រាស់គ្រួសារ ម៉ែឪ បងប្អូន ទាំងកូន ទាំងសរសៃឌី ទើបតែឆ្លងទន្លេហើយ២០ថ្ងៃ ដែលនាងខ្ញុំមិនដែលជួបប្រទះ ដែលឪពុកម្តាយចិញ្ចឹមមកបានល្អ ស្រាប់តែត្រូវរបបខ្មែរក្រហមនេះមកបំផ្លាញសេចក្តីសុខនេះចាស៎ ។ វេទនាណាស់ ចេញទៅតាមផ្លូវទាំងឈឺទាំងជា ជាមួយកូន ជាមួយប្តី ទីបំផុតទៅស្លាប់កូន ស្លាប់ម្តងមួយៗរហូតពេលដែលខ្ញុំជម្លៀសចេញពីភ្នំពេញ គឺថាទុកសោកនេះ ខ្ញុំបានកប់ទុកយូរហើយ នៅពេលនេះខ្ញុំបានមកសម្តែង នាងខ្ញុំមានសេចក្តីជ្រះថ្លា និងអរព្រះគុណដល់តុលាការនេះណាស់ចាស៎ ។

ហើយជាពិសេស ពេលដែលនាងខ្ញុំជម្លៀស គឺថាជម្លៀសនោះ ជម្លៀសហួសហេតុ ចាស៎ ពីភ្នំពេញមកខ្សាច់កណ្តាល ពីខ្សាច់កណ្តាលមកកំពង់ឆ្នាំង ពីកំពង់ឆ្នាំងទៅពោធិ៍សាត់ ទីបំផុតទៅរស់នៅសហករណ៍កោះជុំ ធៀបអន់ជាងសត្វធាតុទៅទៀតណា៎ រហូតដល់ស៊ុំគេដូរបាយជ្រូកមកហូប ។ ទីបំផុតអង្គការសម្រេចចិត្តមិនដឹងជាកាត់ទោសខ្ញុំយ៉ាងម៉េច សម្រេចចិត្តយកខ្ញុំទាំងគ្រួសារយកទៅដាក់គុក ហើយគុក ហើយគុកនោះគឺមហាវិនាសកម្ម ដោយសារមិនមែនត្រឹមតែខ្ញុំទេ សូម្បីតែប្រជាពលរដ្ឋទាំងអស់ដែលពុំមានទោសពៃរ៍អ្វីសោះនេះ យកទៅសួរចម្លើយវៃដកក្រចក ជ្រមុជទឹក ចងកព្យួរ ដែលគ្នាអត់មានទោសអីសោះ ហើយថែមទាំងប្រាប់ថា ឲ្យសារភាពឲ្យត្រឹមមក អ្នកឯងធ្វើខុសអីខ្លះ? ហើយចុះបើគ្នាអត់ខុសអីផង ឲ្យសារភាពថាម៉េច បើសារភាពបន្តរបន្តួយ បើមិនសារភាពវិតតែធ្ងន់ៗ ពេលទៅសួរចម្លើយ នៅគុកថ្កោល ត្រឡប់មកវិញគឺថាវាៗ មានស្ត្រីម្នាក់នោះប្រាប់ខ្ញុំថា អូនហើយអូន បើបងស្លាប់ទៅល្អជាងនៅរស់ឲ្យគេវៃសួរចម្លើយ វៃដកក្រចកបែកឈាមហូររហាម ។ អ៊ីចឹងបានថា គឺថាមហាវិនាសកម្មនេះ ដល់តែធ្វើស្រែ ពេលទៅធ្វើការក៏វៃ ពេលហូបក៏វៃ ពេលដេកក៏វៃ ។ ហើយមូលហេតុអីបានវៃ? គេមិនឲ្យយើងហូបបន្លែ ព្រោះគេថាហូបទៅឈឺបាត់បង់ពលកម្ម ប៉ុន្តែយើងហូបអត់ឆ្អែត ព្យាយាមបេះបន្លែមកលាយ ដើម្បីសម្រន់នៅក្រពះ ។

ហើយដូចការសម្លាប់អ៊ីចឹង ទើសអីក៏សម្លាប់ដែរ ។ ផាកទៅមើលក្នុងគុកហ្នឹងពេល ដែលខ្ញុំមិនទាន់ចេញទៅសមរភូមិមុខគឺថាផាកទៅឃើញបែកក្បាល ឃើញបែកភ្នែក ឃើញរយះនេះហើយ ច្រវ៉ាក់មួយណាក៏ជាប់ច្រវ៉ាក់ដែរពេលដែលចេញមកធ្វើការលើកច្រវ៉ាក់ ចងនៅលើចង្កេះចាស៎ ហើយជាន់ដូចថា ខែ១ ច្រូតអ៊ីចឹង ប៉ែនស្រូវអ៊ីចឹងទៅ ជាន់ស្រូវបណ្តើរ ឲ្យតែហ៊ានថា ខ្វះពីបីគ្រាប់ យកមកញាត់មាត់ ភូស! បែកឈាមរហាម ។ អ៊ីចឹងបានថា ខ្ញុំនេះ គឺថាវាធ្ងន់ធ្ងរបំផុត គឺថាបើត្រឹមតែអ្នកសហករណ៍ វានៅគ្រាន់បើទេ តែជាប់គុក ក្រោយមកកសាងខ្លួនបាន ។ សម្រាប់ផ្អែតឆ្អន់ប្រហែល១០ម៉ឺននាក់ហើយ ធ្វើស្រែបានផលល្អ ដីមានជីវជាតិ ហើយប្រគល់ឲ្យអ្នកសហករណ៍ ចាស៎ ប្រគល់ដីឲ្យអ្នកសហករណ៍ ទើបបណ្តើរពួកនាងខ្ញុំនឹង រាប់រយនាក់ហ្នឹងទៅធ្វើស្រែនៅបឹងគល់ទៀត ។ បឹងគល់ស្ថិតនៅឃុំបឹងខ្នា ស្រុក២៣ ដដែលចាស៎ ។ ធ្វើស្រែស្ទូងស្រូវបាន១០០ហិចតា ។ ហើយពេលស្ទូងនោះគឺថា ដកសំណាបយប់ យប់ឡើងដកសំណាបដល់ម៉ោង១២ ។ ដល់ម៉ោង១២អីដល់ម៉ោង១១ ។ ម៉ោង១១ ឲ្យចូលកន្លែង ចូលកន្លែងទម្រាំបានសម្រាកម៉ោងដប់ដប់ពីរៗ ។ ម៉ោងបីត្រូវផ្ទុកព្រៃប្រេចឲ្យងើប គឺត្រូវតែងើបមកអង្គុយសំកុកជម្រង់ជួរឲ្យមូសខាំ ។ ចាស៎ រដូវនោះជារដូវរងា មានឯណា មានបាវទូលសំណាបហ្នឹងហើយ រុំគ្របខ្លួនចាស៎ ។ អ៊ីចឹង មូសខាំរហូតដល់ពេលឃើញអញ្ចាញដៃ មើលទៅឃើញស្រាងៗទើបបណ្តើរឲ្យចេញទៅស្ទូងៗ ។ ដល់តែពេលភ្លឺស្រាងៗ ឡើងទើបគេបណ្តើរចេញទៅធ្វើការ ចាស៎ ហើយហូបចុកខ្វះខាត មួយកំប៉ុង ហូបបួន-ប្រាំនាក់ ។ ដល់អ៊ីចឹងទៅ តើសួរថាកម្លាំងធ្វើការតើមានឯណា? អត់មានកម្លាំងធ្វើការទេ ប៉ុន្តែទៅទាំងចិត្ត ទៅទាំងខ្លាចស្លាប់ចាស៎ ។ ហើយពេលទៅធ្វើការហ្នឹង ត្រូវទូលសំណាបទៅខ្លួនឯង ហើយបើហ៊ានថា ធ្វើជ្រះធ្វើអី គឺវៃខ្សែតីវៃដូចគោអញ្ចឹង ចាស៎ នាងខ្ញុំក៏ធ្លាប់ត្រូវដែរ ចាស៎វៃខ្សែតី ព្រោះពេលគេវៃហ្នឹង គេមិនមែនគិតថាវៃអ្នកនេះមួយ អ្នកនោះមួយ គឺគេវាត់យកៗតែម្តង ប៉ះអ្នកណាត្រូវអ្នកហ្នឹងចាស៎ ។

ទៅស្ទូងអ៊ីចឹងដែរ ពេលចុះស្ទូង យើងស្ទូងទៅមានផែនការរបស់គេ ស្ទូងទៅត្រូវមួយហិចតាហ្នឹងស្ទូងប៉ុន្មាននាក់? ត្រូវប៉ុន្មានម៉ោងឲ្យហើយ? ចាស៎ គឺមានកម្រិតផែនការទាំងអស់ ធ្វើការធ្ងន់មានកម្រិត មានផែនការ តែហូបតិចៗ សួរថាយើងទាំងអស់គ្នាទទួលយកបានឬអត់? មិនមែនត្រឹមតែហូបតិចនោះទេ សម្រាប់

ស្រួលទៀតចាស់ ។ ក្រោយមកនាងខ្ញុំស្ទូង បាន១០០ហិចតា ហើយ ពួកនាងខ្ញុំប៉ុន្តែខ្ញុំសូមលើកកន្លែងនេះបន្តិចទៀតចាស់ ។ ពេលដែលបណ្តើរទៅនោះ ពីគុកថ្កោលទៅកន្លែងមន្ទីរកសាងខ្លួនបឹងគល់ហ្នឹង គឺថាបាត់មនុស្សច្រើនទៀតចាស់ ។ យើងចេះតែដើរទៅតាមថ្នល់រទេះភ្លើង ដល់ទៅដល់ណោះ អូ! បាត់អ្នកនេះបាត់អ្នកនោះ ។ ពេលនោះអាហ្នឹង ទៅដល់ហ្នឹង ពួកនិរតីម្តង អាហ្នឹងបូព៌ាចប់ទៀតហើយ ទៅខាងហ្នឹងពួកនិរតីទទួលម្តងចាស់ សម្លាប់ហ្នឹងពាយចាស់ ។ ដល់ទៅបឹងខ្នាហ្នឹង នាងខ្ញុំទៅស្ទូង បានពួកនាងខ្ញុំទៅស្ទូងបាន១០០ហិចតា ។ ១០០ហិចតាហើយ ក៏ប្រគល់ដីហ្នឹងទៅឲ្យពួកសហករណ៍ចាស់ យើងធ្វើបានផលល្អហើយ ។ អីចឹងគេឲ្យដីហ្នឹងទៅឲ្យអ្នកសហករណ៍ គេក៏បណ្តើរពួកខ្ញុំយកទៅគុកបឹងគល់ទៀត ។

ពេលនោះទៅដល់គុកបឹងគល់បានដឹងថាចំដាពិបាកហើយ ជាកន្លែងចុងក្រោយបង្អស់ ដែលពិបាកជាងគុកថ្កោល ដែលពិបាកជាបឹងខ្នាទៅទៀតចាស់ ។ អ្នកដែលខុសគឺ ដាក់ខ្នោះជើង ។ ដាក់ខ្នោះជើងហ្នឹងគឺថា អាខ្នោះជើងហ្នឹង ដេកតំរៀបគ្នាទៅរុញខ្នោះចាស់ ។ ហើយហូបចុក ឲ្យតែហូបស្រួល មិនស្រួលដូចថា មានការធ្វេសប្រហែសអីនាយអាយអីចឹង គឺវ៉ៃអីចឹងតែម្តង វ៉ៃបែកឈាមអស់ហើយ ។ ចាស់ ហើយអ្នកដែលជាប់ក្នុងបន្ទប់អ្នកជាប់គុកងងឹតគឺមិនបាច់សម្លាប់ទេ គឺស្លាប់ដោយខ្លួនឯង រដូវប្រាំងព្រោះក្តៅណាស់ ខែចែត្រចាស់ ដំបូលពីរម៉ែត្រ ហើយគ្មានកម្លាំងទប់ទល់នឹងធាតុក្តៅ ធាតុត្រជាក់អីទេចាស់ ។ គឺចាំតែដេកស្លាប់តែម្តង ។ ហើយបើយើងទៅធ្វើការ យើងមកអត់រួចទេ គឺមិនបាច់មក ដឹងតែស្លាប់ នៅហ្នឹងហើយ ។ ដឹងតែស្លាប់នៅជាដំបូង ជាគល់ឈើ គឺមិនគ្មានអ្នកណាគ្រាអ្នកណាមកបានទេចាស់ ព្រោះម្នាក់ៗយោងតែខ្លួនអត់រួចផង ។ ហើយនៅពេលនោះនៅទីនោះ នាងខ្ញុំលើកពីខ្លួននាងខ្ញុំចុះ វាឃ្លានពេក ដូចជាខ្យង នាងខ្ញុំហូបតែឆៅទេចាស់ មិនដែលស្ងោរឆ្អិននឹងគេទេ ព្រោះបើមានភ្លើងគឺគេវ៉ៃ ហើយឃ្លានណាស់! គឺថាអាការអត់ឃ្លាននេះហើយ ដែលធ្វើឲ្យមនុស្សភ្លេចអស់ហើយសីលធម៌ ភ្លេចអស់ហើយសុជីវធម៌ ចាស់ ធ្វើអីក៏ដោយឲ្យតែរស់សិន ។

នៅគុកបឹង នៅគុកគ្រោចក្រោលហ្នឹងក៏ដូចគ្នាចាស់ ។ ព្រលឹមឡើងបណ្តើរទៅធ្វើការកាំភ្លើងប្រុងប្រាង យូរគណ្តាប់ទៅធ្វើការ ថ្ងៃត្រង់មកហូបបាយនៅការដ្ឋានវិញ ។ ថ្ងៃហូបបាយហើយ ចេញទៅធ្វើការទៀត ។ ធ្វើការហើយត្រឡប់មកការដ្ឋានហូបបាយទៀត ។ យប់ទៅដកសំណាប គឺថាដឹងយ៉ាងម៉េច ខ្ញុំឆ្ងល់របបហ្នឹងក៏អាក្រក់ម្ល៉េះ! ឲ្យគ្នាធ្វើការយប់ជ្រៅហើយ មិនឲ្យគ្នាសម្រាកឲ្យបាន ថាតម្រូវបើភ្លឺបានទៅស្ទូង អាហ្នឹងឲ្យនៅដល់ភ្លឺទៅ ហេតុអីបានដោផ្ទិកញ្ចែ ឲ្យគ្នាមកអង្គុយតម្រង់ជួរ ឲ្យមូសខាំ ហាលរងារ ហាលសន្សើម ហើយសួរថាសុខភាពហ្នឹង វាទៅជាយ៉ាងណាចាស់ ។

ជាប់យូរក្រោយមកទៀត ចុងក្រោយគេក៏បានមកជម្លៀសពួកខ្ញុំ នៅក្នុងគុកដដែលហ្នឹង ប៉ុន្តែចុះទៅសហករណ៍ ព្រោះពេលនោះទឹកជំនន់ ទឹកជំនន់ហ្នឹងគេជម្លៀសខ្ញុំឲ្យទៅជួយទប់ទឹកនៅសហករណ៍ ។ គ្រាន់តែដើរទៅដល់សហករណ៍ អ្នកសហករណ៍ស្រែកថា អឺ! ទុកដាក់អីវ៉ាន់ឲ្យស្រួលបួលរើយ ពួកមន្ទីរកសាងខ្លួនមកពួកហ្នឹងសុទ្ធតែចោរ ។ ពេលនោះពួកខ្ញុំឈឺចាប់ណាស់ ការឈឺចាប់ហ្នឹង មិនដឹងជាថ្លែងប្រាប់អ្នកណាទេចាស់ ។ ពេលទៅធ្វើការគេឲ្យយើងនៅក្នុងការដ្ឋានបាយ គេឲ្យយើងសម្រាកនៅក្នុងហ្នឹងពេលយប់ តែព្រលឹមឡើងត្រូវរៀបចំឥវ៉ាន់ទើលើដំបូល ទើលើគេនែ៎ ហៅដូចពិតានការដ្ឋានបាយហ្នឹង ។ ឥវ៉ាន់ទើលើហ្នឹងដើម្បីថ្ងៃ ឡើងប្រជាពលរដ្ឋសហករណ៍ហ្នឹង គេហូបបាយក្នុងការដ្ឋានហ្នឹង ។ អីចឹងទេ យើងទើឥវ៉ាន់ ទើហើយយើងចេញទៅធ្វើការ ។ ធ្វើការនោះគឺថាទៅជីកដី ដើម្បីលើកទំនប់ទប់ទឹកទន្លេ ទឹកទន្លេសាបចាស់ ។ ហើយអ្នកសហករណ៍ធ្វើការ មានអ្នកសហករណ៍មានអ្នកមន្ទីរកសាង ។ អ្នកសហករណ៍ធ្វើការដីគោកចាស់ គេមកធ្វើថ្ងៃបន្តិចបានគេធ្វើ ធ្វើហើយគេមានពេលសម្រាកហូបបាយ ។ ដល់តែយើងធ្វើនៅក្នុងទឹក គឺចុចដីនៅក្នុងទឹក ហើយប្រមុជងើបយកដីហ្នឹង យកដាក់លើទំនប់ដើម្បីទប់ទឹក ។ ដល់តែពេលអ្នកសហករណ៍ ម៉ោងបីឡើងគេទូលដំឡូង គេចំហុយដំឡូងឈើ ដំឡូងមីហ្នឹងយកទៅឲ្យហូប ចំណែកយើងអ្នកមន្ទីរកសាងខ្លួននឹងអត់ទេ ធ្វើរហូតៗ ដល់ពេលយប់ដល់ពេលចប់ គឺត្រឡប់មកការដ្ឋានបាយគេវិញ បានគេចែកបាយនៅពេលនោះ ។ ពេលនោះហើយដែលគេវ៉ៃ មកដល់ព្រលប់ ការដ្ឋានតូច មនុស្សត្រូវស្នាក់នៅរាប់រយ

នាក់ អ្នកទោសអីចឹងទេអីវ៉ៃឥវ៉ាន់ទើនៅលើដំបូលនឹងត្រូវគេយកទៅវាបាត់ អារបស់អញៗ របស់អញនៅឯណា? ម្ល៉ោះហើយ បេចចាចគេថា យើងនឹងអត់សណ្ដាប់ធ្នាប់ គេវ៉ៃយើងនឹងខ្សែតី វ៉ាត់ខ្វៃខ្វាច់ចាស៎ ។

អ៊ីចឹង បានខ្ញុំគ្រាន់តែចង់ជម្រាបថា ពេលធ្វើការក៏វ៉ៃ ពេលហូបក៏វ៉ៃ ពេលដេកក៏វ៉ៃ គឺថាវ៉ៃទាំងអស់ វ៉ៃរហូតចាស៎ ។ រហូតដល់មានពេលមួយនោះ គេឲ្យខ្ញុំពួកខ្ញុំហ្នឹងទៅទប់ទឹកទន្លេសាប ។ ចាស៎ ជីកទប់អ៊ីចឹងទៅ ពួកខ្ញុំបន់អស់ហើយ បន់ម៉្វៃៗឲ្យធ្លាយទំនប់ហ្នឹងទៅលោកអើយ ព្រោះវេទនាម្ល៉េះ ។ ដល់តែពេលខ្យល់មកខ្លាំងគេឲ្យ គេអត់ឲ្យយើងនៅខាងក្នុងទំនប់ គេឲ្យយើងនៅខាងក្រៅទំនប់ ទៅនៅខាងក្រៅហ្នឹង ព្រោះទឹកទន្លេសាប កាលណាខ្យល់ខ្លាំង គឺរលកដល់រលកបោកមកឲ្យត្រូវខ្លួនយើង ។ យើងទៅទប់ឲ្យរលកត្រូវខ្លួនយើង វាអត់ធ្លាយទំនប់ហ្នឹងទេ បោកមកចំខ្លួនយើងរលកទៅវិញហើយ ។អ៊ីចឹងទេ ពួកខ្ញុំបន់អស់ហើយ ចុះនៅត្រាំ លោកគិតមើលត្រាំតាំងពីព្រឹកដល់ល្ងាច តើវាពិបាកប៉ុនណា វារងាដង វាអត់ឃ្លានដង វានឿយហត់ដងចាស៎ ។ ម៉្លោះហើយ បន់អស់ហើយ ជីបអូចៗ អូយ!ធ្លាយមកលោក! ធ្លាយឲ្យស្រលះទៅ! មានអី ពេលមួយនោះធ្លាយមែន ។ ដល់ធ្លាយទំនប់អ្នកដែលនៅមុខទឹកហ្នឹង ក៏ត្រូវស្លាប់ចាស៎ គឺស្លាប់តែម្ដង អត់មានសេសសល់ទេចាស៎ ។

ហើយលើករឿងមួយទៀត នៅហ្នឹងដែរចាស៎ ពេលដាំដំឡូងកាលណាទឹកចូលមក គេប្រញាប់ប្រញាល់គាស់ណាស់ ទោះដំឡូងតូចក៏ដោយ ធំក៏ដោយគេគាស់ហើយ ។ ដល់តែយើងនេះ ជាអ្នកទោសនេះ វាឃ្លាន ។ អ៊ីចឹងក៏បានទៅកាយៗរេងគេចាស់ៗហ្នឹង ខ្លះទៅម៉ោងសម្រាកហ្នឹង ទំនេទៅរើសដំឡូងហ្នឹង គេចោទយើងថា យើងលួចដំឡូងគេចាស៎ ។ នាងខ្ញុំធ្លាប់ជាប់ម្ដងដែរ គេយកមកមន្ទីរវិញ ដាក់ខ្នោះជើងទៅចាស៎ ក្រោយមកបាន នេះទៅបានមានអ្នកនេះទៅជួយទៅ បានចុះមកទន្លេដដែលហ្នឹងវិញទៀតចាស៎ ។ ហើយពេលដេកអ៊ីចឹងដែរ ពេបដេកអត់មានកន្លែងដេកស្រួលបួលទេចាស៎ នាងខ្ញុំសម្រាកអ៊ីចឹងទៅ ចេះតែសម្រាកឲ្យបានទៅ ហើយដល់ពេលទឹកវាចេះតែឡើងមក ជន្លេនពូនពំនូកប៉ុនៗនេះពូនលើជើង ។ មែនទែនទៅ លែងខ្លាចហើយជន្លេន ក៏អត់ខ្លាច ឈ្លើងក៏អត់ខ្លាច ស្អីក៏អត់ខ្លាចដែរក្រៅតែពីជីវិតរស់មួយចាស៎ ។

អ៊ីចឹងបានថា ជីវិតនេះវាអាក្រក់បំផុតមិនដឹងថាអ្នកដឹកនាំហ្នឹង គេជាមនុស្សសតិ សម្បជញ្ញៈ គេហ្នឹងជាមនុស្សដែរឬអត់? ដែលគេយកមនុស្សដូចគ្នាទៅធ្វើបាបរបៀបនេះ ចាស៎ ។ ចុងបញ្ចប់ហ្នឹងគឺថាខ្ញុំណា គេឃៀកណាមចូលខែ១ បែកគេសប្បាយរីករាយរាំវង់ ឡុកកញ្ចូង ប៉ុន្តែជីវិតនាងខ្ញុំ បែករហូតដល់ខែ៥ គឺដោយសារពួក ប៉ុល ពត ហ្នឹង ពួកអាវ ខ្មៅហ្នឹង កៀរនាងខ្ញុំចុះទៅតទៅទៀត មិនដឹងគេកៀរទៅណា ហើយពួកខ្ញុំអត់ហ៊ានរត់ទេ ចេះតែនឹកឃើញថាខំរស់មកដល់ថ្ងៃនេះ គេស្លាប់ហើយ ម៉ែញាតិមិត្តអីអ៊ីចឹង អ្នកមកមន្ទីរខ្ញុំ មានបួននាក់ ស្លាប់អស់បីនាក់ នៅសល់តែខ្ញុំម្នាក់ ។ អ៊ីចឹងអត់រត់ទេ ពិបាកស្រណុកអី ខំប្រឹងតទៅទៀតចាស៎ ។ រហូតដល់ខែ៥ ទើបខ្ញុំបានបែក ។ បែកបានស្គាល់នេះ ខ្ញុំឡើងមក ឃុំត្រពាំងជង ចាស៎ តំបន់២៣ហ្នឹង ខ្ញុំក៏ឡើងមកនៅទីនោះទៅចាស៎ ។

ហើយចុងក្រោយនេះ គឺខ្ញុំសូមជាបំណងរបស់ខ្ញុំចាស៎ ចុងក្រោយហ្នឹងគឺថា ក្រោយពី ការរៀបរាប់អំពើទារុណកម្មដ៏មហាវិនាសកម្មដ៏អាក្រក់ ដូចសត្វធាតុ លើសពីសត្វធាតុទៅទៀតនេះ ចាស៎ ខ្ញុំសូមបញ្ចប់ចុះ ហើយខ្ញុំសូមសំណូមពរចាស៎ ខ្ញុំសំណូមពរដូចរបស់ខ្ញុំអ៊ីចឹង គឺថា ខ្ញុំបានជម្រាបហើយ នៅក្នុងនេះចាស៎ ថាត្រូវធ្វើអី ត្រូវរកមុខអ្នកណាខ្លះ ព្រោះបើថា ខ្មែរដូចគ្នាហេតុអ្វីក៏ចិត្តខ្មៅម្ល៉េះ? ក្រែងលោតែមានបរទេសបន្ថែមលើហ្នឹងទៀត បានជាវាអត់ស្គាល់ខ្មែរដូចគ្នាចាស៎ ។ ចាស៎ អ៊ីចឹងបានថា ខ្ញុំចេះតែចង់ដឹង ឲ្យតុលាការរកមុខធ្វើម៉េចរកឲ្យឃើញទៅ ហើយសំណោងគឺថា ខ្ញុំសូមឲ្យសាងសង់ស្ដូបមួយព្រោះដោយសារថាមន្ទីរកសាងខ្លួននៅគុកថ្កោលហ្នឹង ថាវាអត់មានក្នុងការស៊ើបអង្កេតទេ ប៉ុន្តែនេះជាសំណូមពររបស់ខ្ញុំ ទោះបីធ្វើបានក៏ដោយ មិនបានក៏ដោយក៏ជាគំនិតរបស់ខ្ញុំផ្ទាល់ចាស៎ ខ្ញុំសូមឲ្យតុលាការជួយផ្ដល់ជួយជាគំនិតឲ្យបានសង់ស្ដូបមួយដើម្បីគោរពវិញ្ញាណក្ខន្ធ អ្នកដែលបានស្លាប់នៅគុកថ្កោលនេះ ព្រោះកន្លែងនេះថ្កោលនេះ ខ្ញុំដឹងច្បាស់ជាងគេថា ស្លាប់ច្រើនហ្នឹង ។ ចាស៎ ដើម្បីឲ្យវិញ្ញាណក្ខន្ធអ្នកដែលស្លាប់ទៅ ស្លាប់បិទភ្នែកជិត ស្លាប់ដោយអស់ចិត្ត ។ ចាស៎ សូមអស់យោបល់» ។

# សវនាការស្តាប់សក្ខីកម្មសាក្សី គង់ គីម
## ថ្ងៃទី២៤-២៥ ខែតុលា ឆ្នាំ២០១២

នៅរសៀលថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១២ បន្ទាប់ពីបញ្ចប់ការសួរដេញដោលដើមបណ្តឹងរដ្ឋប្បវេណី ឡាយ បូនី អង្គជំនុំជម្រះសាលាដំបូងបានកោះហៅសាក្សីឈ្មោះ គង់ គីម ដែលមានតួនាទីជាអតីតកងទ័ពខ្មែរក្រហមដើម្បីផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ ។ សក្ខីកម្មសាក្សីរូបនេះ បានផ្តោតជាសំខាន់លើរចនាសម្ព័ន្ធយោធា ជាពិសេសរចនាសម្ព័ន្ធយោធាថ្នាក់មូលដ្ឋានក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ដូចជាសាក្សីមុនៗដែរ ការសួរដេញដោលសាក្សីរូបនេះចាប់ផ្តើមដោយសហព្រះរាជអាជ្ញា ដើមបណ្តឹងរដ្ឋប្បវេណី និងចៅក្រម ហ្សង់ម៉ាក ឡាវ៉ែញ បន្ទាប់មកអង្គជំនុំជម្រះប្រគល់វេទិកាជូនមេធាវីការពារក្តីជនជាប់ចោទទាំងបីក្រុម ។ នៅអំឡុងពេលនៃការសាកសួរដេញដោលសាក្សី គង់ គីម ជនជាប់ចោទ អៀង សារី បានសម្រេចចិត្តបោះបង់សិទ្ធិមិនចូលរួមក្នុងសវនាការ ដោយសារបញ្ហាសុខភាពដែលត្រូវសម្រាកព្យាបាលរយៈពេលវែងនៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត ។ សវនាការស្តីពីការសួរដេញដោយ គង់ គីម បានបញ្ចប់នៅរសៀលថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១២ ។

### ១) ប្រវត្តិសាវតារសាក្សី គង់ គីម

នៅមុនពេលប្រគល់វេទិកាជូនភាគី ដើម្បីសាកសួរដេញដោល ប្រធានអង្គជំនុំជម្រះ និល ណុន បានសួរអំពីប្រវត្តិសាវតាររបស់សាក្សី គង់ គីម ។ ឆ្លើយតបនឹងសំណួររបស់ប្រធានអង្គជំនុំជម្រះសាក្សី គង់ គីម បានរៀបរាប់ថា សព្វថ្ងៃលោករស់នៅភូមិព្រៃតាំងធ្នង់ ឃុំជៀប ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង ។ មានប្រពន្ធឈ្មោះ គេង មុត និងកូនបួននាក់ ហើយមានតួនាទីជាប្រធានក្រុមប្រឹក្សា ឃុំជៀប ។ ឪពុករបស់សាក្សីឈ្មោះ ជូ ឡុង និងម្តាយឈ្មោះ ឡេង គា ។ សាក្សីបានអះអាងថា មុនពេលចូលមកផ្តល់សក្ខីកម្មនៅចំពោះអង្គជំនុំជម្រះ ខ្លួនបានស្បថនៅចំពោះមុខលោកតាដំបងដែករួចរាល់ហើយ ។ សាក្សីបានបន្តថាលោកធ្លាប់បានផ្តល់សម្ភាសន៍ចំនួនមួយដងជាមួយអ្នកស៊ើបអង្កេតរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតនៅផ្ទះរបស់លោកផ្ទាល់ ។

### ២) ការសួរដេញដោលសាក្សីដោយសហព្រះរាជអាជ្ញា

នៅអំឡុងពេលនៃការសួរដេញដោលសាក្សី គង់ គីម សហ-ព្រះរាជអាជ្ញាបានចំណាយពេលពេញមួយរសៀលថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១២ ដើម្បីសាកសួរដោយផ្តោតជាសំខាន់លើរចនាសម្ព័ន្ធយោធានៃរបបកម្ពុជាប្រជាធិបតេយ្យ និងការវាយផ្ទាច់ព្រ័ត្រចូលទីក្រុងភ្នំពេញដោយកងទ័ពខ្មែរក្រហមនៅថ្ងៃទី១៧



សាក្សី គង់ គីម
(ប្រភព ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)

ខែមេសា ឆ្នាំ១៩៧៥ ។

តំណាងសហព្រះរាជអាជ្ញាជាតិ វ៉េង ហ៊ត់ បានផ្តើមសំណួរដំបូងរបស់ខ្លួនទាក់ទងនឹងការចូលបម្រើជាកងទ័ពខ្មែរក្រហមរបស់សាក្សីនៅមុនឆ្នាំ១៩៧៥ ។ ឆ្លើយតបនឹងសំណួររបស់តំណាងសហព្រះរាជអាជ្ញា សាក្សី គង់ គីម បានបញ្ជាក់ថា ខ្លួនបានចូលបម្រើជាកងទ័ពនៅក្នុងឆ្នាំ១៩៧៤ នៅខេត្តកំពង់ធំ ដោយនៅពេលនោះទើបតែមានអាយុ២០ឆ្នាំ ។ បន្ទាប់មក ត្រូវបានផ្លាស់មកភូមិភាគឧត្តរ និងបន្តមកព្រែកក្តាមដើម្បីវាយចូលទីក្រុងភ្នំពេញ ។ សាក្សី ធ្លាប់បានចូលរួមប្រជុំកម្រិតអនុសេនាតូច អនុសេនាធំ និងវរសេនាធំ ដែលដឹកនាំប្រជុំដោយឈ្មោះ ប៉ុន

និងឈ្មោះ ឡាំ ជាមេកងអនុសេនាតូច អំពីផែនការនិងយុទ្ធសាស្រ្តវាយចូលទីក្រុងភ្នំពេញ ។ សាក្សីបានទទួលបញ្ជាឲ្យត្រៀមនៅខ្សែជួរមុខ ដែលមានទីតាំងនៅតាមបណ្តោយព្រែកភ្នៅ អន្លង់ក្ងាន និងភូមិធំ ត្រពាំងព្រាយ ដែលមានមុខព្រួញឆ្ពោះមកទីក្រុងភ្នំពេញ ។ សាក្សីបានអះអាងថា នៅពេលនោះខ្លួនបានទទួលបញ្ជាពីឈ្មោះ ស្លាប់ជាច្រើននៅតាមផ្លូវថ្នល់ ដែលនេះគឺជារឿងដែលមិនអាចជៀសរួច ទោះបីជាប្រុងប្រយ័ត្នយ៉ាងណាក៏ដោយ ។ ឆ្លើយតបនឹងសំណួរទាក់ទងនឹងការឆែកឆេរផ្ទះប្រជាជននៅក្រោយពេលខ្មែរក្រហមទទួលបានជ័យជម្នះ សាក្សីបានបញ្ជាក់ថា នៅគ្រាដែលទើបនឹងទទួលបានជ័យជម្នះភ្លាមៗ មិនទាន់មានការបែងចែកក្រុម



យោធាខ្មែរក្រហមចូលដល់អគ្គសេនាធិការយោធាខេមរជាតិនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥(ប្រភព ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)

ប៉ុន ថា ឲ្យតែមាននរណាស្លៀកពាក់ជាទាហាន ត្រូវបាញ់សម្លាប់ចោលតែម្តង ។ បញ្ជានេះត្រូវបានដាក់ចេញនៅក្នុងពេលប្រជុំ ហើយសាក្សីក៏បានទទួលបញ្ជាផ្ទាល់មាត់ដែរ ។

ឆ្លើយតបនឹងសំណួរទាក់ទងនឹងការប៉ះពាល់ដល់អាយុជីវិតរបស់ប្រជាពលរដ្ឋនៅក្នុងអំឡុងពេលនៃការវាយចូលដល់ទីក្រុងភ្នំពេញ សាក្សីបានរៀបរាប់ថា ទីក្រុងភ្នំពេញមានភាពច្របូកច្របល់ក្រៃលែង នៅពេលដែលវាយចូលទីក្រុងភ្នំពេញ ។ សាក្សីបន្តថា ការវាយលុកផ្តាច់ព្រ័ត្រនេះបានបណ្តាលឲ្យមានមនុស្ស ឲ្យឆែកឆេរផ្ទះរបស់ប្រជាជននៅឡើយទេ ព្រោះទាហានរបស់ លន់ នល់ នៅពាសពេញទីក្រុងនៅឡើយ ។ ប៉ុន្តែក្រោយពេលជម្លៀសដោយសារនៅមានប្រជាជនដែលមិនទាន់ចាកចេញ ទើបមានបញ្ជាឲ្យធ្វើការឆែកឆេរនៅតាមផ្ទះទាំងអស់នៅទីក្រុងភ្នំពេញ ។ សាក្សីបន្តថា កងពលរបស់ខ្លួនពុំមានតួនាទីទាក់ទងនឹងការជម្លៀសប្រជាជនទេ ប៉ុន្តែមានតួនាទីចាំបោសសម្អាតបន្ទាប់ពីមានការជម្លៀស ។ បន្ទាប់មក តំណាងសហព្រះរាជអាជ្ញាជាតិ វើង ហ៊ត់ បានប្រគល់វេទិកាជូនតំណាងសហព្រះរាជអាជ្ញាអន្តរជាតិដើម្បី

សួរដេញដោលបន្ត ។

តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ថារីក អាប់ឌុលហាក់ បានបន្តសួរ ទាក់ទងនឹងអ្នកដែលចេញបញ្ជាឲ្យមានការបោសសម្អាតប្រជាជនឲ្យអស់ចេញពីទីក្រុង ។ សាក្សី គង់ គីម បានអះអាងថា អ្នកដែលបានចេញបញ្ជានេះ ឈ្មោះ អឿន ។ សាក្សីបន្តថា ក្នុងអំឡុងពេលនៃការបោសសម្អាតនោះ ខ្លួនពុំដែលបាញ់សម្លាប់ប្រជាជននោះទេ គឺមានតែការបាញ់ជាមួយទាហានហើយប៉ះដល់ប្រជាជន ។ សាក្សីបានបន្ថែមទៀតថា នៅអំឡុងពេលនៃការជម្លៀសនៅភ្នំពេញខ្លួនពុំទាន់ទទួលបញ្ជាឲ្យបាញ់នៅឡើយទេ ប៉ុន្តែ ក្រោយពេលជម្លៀស គឺក្នុងអំឡុងពេលនៃការបោសសម្អាតទីក្រុង ដោយសារតែមានការបាញ់កងទ័ពស្លាប់ ពីសំណាក់ទាហានលន់ នល់ ដែលនៅលាក់ខ្លួនខាងក្នុងផ្ទះដែលពុំទាន់ចាកចេញពីភ្នំពេញ ទើបមានការបញ្ជាឲ្យបាញ់ ។ តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ថារីក បានសួរទៀតថា តើយោធាខ្មែរក្រហមអាចបាញ់ប្រជាជនបានដោយមិនចាំបាច់ទទួលទោសមែនដែរឬទេ? សាក្សីបានឆ្លើយតបនឹងសំណួរនេះថា ចំពោះការបាញ់នោះ គឺសម្តៅលើការបាញ់នៅលើសមរភូមិ ព្រោះនៅលើសមរភូមិចាំបាច់ គឺត្រូវតែបាញ់ ។ ទាក់ទងនឹងការចាប់ខ្លួនកម្មាភិបាលយោធា សាក្សីបានបញ្ជាក់ថា ឈ្មោះ អឿន ដែលជាមេបញ្ជាការរបស់ខ្លួនត្រូវបានចាប់ខ្លួន ហើយកម្មាភិបាលយោធាផ្សេងៗទៀតក៏ត្រូវបានចាប់ខ្លួនដែរ ។ មូលហេតុដែលដឹងអំពីរឿងនេះ គឺដោយសារតែនៅពេលនោះសាក្សីគឺជាអ្នកយាមនៅមន្ទីរឃុំឃាំងដែលដាក់អតីតថ្នាក់លើរបស់ខ្លួន ប៉ុន្តែក្រោយមកសាក្សីត្រូវបានផ្លាស់ប្តូរចេញពីកន្លែងនោះ ឲ្យទៅធ្វើព្រលានយន្តហោះកំពង់ឆ្នាំងវិញម្តង ដោយមានកងទ័ពមកពីភូមិភាគនិរតីមកគ្រប់គ្រងក្រុមយុវជននៅទីនោះ ។

## ៣) ការសួរដេញដោលសាក្សីដោយមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី

មេធាវីជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណី មេធាវី ចេត វ៉ាន់លី បានចាប់ផ្តើមសំណួរទាក់ទងនឹងតួនាទីជានីរសាររបស់សាក្សីចាប់ពីពេលចូលធ្វើបដិវត្តនៅឆ្នាំ១៩៧៤ រហូតដល់ពេលវាយចូលទីក្រុងភ្នំពេញ ។ សាក្សី គង់ គីម បានឆ្លើយតបនឹងសំណួរនេះថា ក្នុងអំឡុងពេលជានីរសារខ្លួនបានពាក់ឯកសណ្ឋានពណ៌ខ្មៅ និងស្បែកជើងកង់ឡាន ហើយមានភារកិច្ចជាអ្នកនាំយកបាយទៅសរមភូមិមុខ និងនាំសារពីសមរភូមិមុខមកសមរភូមិក្រោយ ។ សាក្សីបានបន្តថា នៅពេលនោះខ្លួនទើបតែមានអាយុ១៥ឆ្នាំ តែប៉ុណ្ណោះ ពុំទាន់កាន់កាំភ្លើងទេ ។ ក្រៅពីមុខងារជានិរសារ សាក្សីក៏ជាអ្នកប្រយុទ្ធនៅលើសមរភូមិដែរ ។ ទាក់ទងនឹងការចូលបម្រើការជាកងទ័ព សាក្សី គង់ គីម បានអះអាងថា ខ្លួនចូលធ្វើជាកងទ័ពនៅពេលនោះ គឺដោយសារការចាប់បង្ខំទេ ។ បន្ទាប់ពីរំដោះទីក្រុងភ្នំពេញបានហើយ សាក្សីត្រូវបានផ្តល់តំណែងជាប្រធានកង ។ ចំពោះសំណួរទាក់ទងនឹងសមាសភាពរបស់ថ្នាក់ដឹកនាំផ្នែកយោធា សាក្សីបានបញ្ជាក់ថា ខ្លួនពុំស្គាល់ថ្នាក់ដឹកនាំជាន់ខ្ពស់ទេ គឺស្គាល់តែប្រធានវរៈសេនាធំរបស់ខ្លួនតែប៉ុណ្ណោះ ដោយសារតែថ្នាក់ដឹកនាំអនុសេនាតូច និងអនុសេនាធំទៅចូលរួមប្រជុំជាមួយថ្នាក់ដឹកនាំយោធា ហើយទើបមកប្រជុំប្រាប់កងទ័ព នៅក្នុងកងពលរបស់ខ្លួនដែលកំពុងត្រៀមប្រយុទ្ធនៅភ្នំពេញ ។ ក្រោយពេលវាយយកបានទីក្រុងភ្នំពេញ ហើយសាក្សី គង់ គីម បានទទួលភារកិច្ចឲ្យមើលខុសត្រូវពីវត្តភ្នំទៅដល់ស្ពានជ្រោយចង្វាទាំងយប់ទាំងថ្ងៃ ។ ពេលនោះមានការប្រឫកប្រប្រល់ ដោយមានប្រជាជនខ្លះនៅក្រាញនៅលើផ្ទះថ្ម ហើយបានគប់គ្រាប់បែក និងបាញ់មកលើយោធាខ្មែរក្រហម ដោយសារតែហេតុផលនេះហើយ ទើបមានការបោសសម្អាតអ្នកដែលមិនព្រមចាកចេញនៅពេលបន្ទាប់ ។ នៅក្នុងការបោសសម្អាតផ្លូវ គ្មាននរណាម្នាក់មានសិទ្ធិចូលផ្ទះទេបើមិនមានការអនុញ្ញាត ។ ទាក់ទងនឹងការជម្លៀសប្រជាជន សាក្សីបានពន្យល់ថា ក្នុងអំឡុងពេលនៃការជម្លៀសនោះខ្លួនមានភារកិច្ចត្រឹមតែបណ្តេញប្រជាជនប៉ុណ្ណោះ ហើយមិនដឹងថាប្រជាជនត្រូវបានបញ្ជូនទៅទីណានោះទេ ។

## ៤) ការសួរដេញដោលសាក្សីដោយចៅក្រម ហ្សង់ម៉ាក ឡាវែរីញ

បន្ទាប់ពីមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ចប់ការចោទសួររបស់ខ្លួន អង្គជំនុំជម្រះបានប្រគល់វេទិកាជូនចៅក្រមអន្តរជាតិ ហ្សង់ម៉ាក ឡាវែរីញ ដើម្បីសួរដេញដោលសាក្សី ។ ចៅក្រម ឡាវែរីញ បានចោទសួរសំណួរមួយចំនួនទាក់ទងនឹងសកម្មភាពមុនពេលវាយយកភ្នំពេញ និងផែនការក្នុងការជម្លៀស

ប្រជាជនចេញពីទីក្រុងភ្នំពេញ រួមជាមួយនឹងការបោសសម្អាតប្រជាជនទាំងអស់ក្រោយជម្លៀស ។ ចម្លើយដែលសាក្សី គង់ គីម ឆ្លើយតបនឹងសំណួររបស់លោកចៅក្រម ភាគច្រើនប្រហាក់ប្រហែលនឹងចម្លើយដែលសាក្សីបានឆ្លើយតបសំណួររបស់សហព្រះរាជអាជ្ញា និងមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ។ ប៉ុន្តែសាក្សីបានបន្ថែមថា ចំពោះផែនការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ សាក្សីមិនបានដឹងទាល់តែសោះ និងមិនដឹងពីគោលបំណងជម្លៀសនេះឡើយ ។ ការបញ្ជាឲ្យជម្លៀស គឺធ្វើឡើងភ្លាមៗនៅពេលដែលកងទ័ពវាយចូលមកដល់ទីក្រុងភ្នំពេញ ។

## ៥) ការសួរដេញដោលសាក្សីដោយក្រុមមេធាវីការពារក្តីជនជាប់ចោទ

អង្គជំនុំជម្រះបានប្រគល់វេទិកាបន្តជូនក្រុមមេធាវីការពារក្តីទាំងបីក្រុមដើម្បីសាកសួរលើសាក្សី គង់ គីម ដោយចាប់ផ្តើមពីក្រុមមេធាវីការពារក្តី នួន ជា និងបន្តទៅក្រុមមេធាវី អៀង សារី និង ខៀវ សំផន ។ ប៉ុន្តែក្នុងអំឡុងពេលនៃការផ្តល់សក្ខីកម្មរបស់សាក្សីរូបនេះ ក្រុមមេធាវីការពារក្តី អៀង សារី និង ខៀវ សំផន មិនបានចោទសួរសំណួរឡើយ ។

មេធាវីអន្តរជាតិការពារក្តីជនជាប់ចោទ នួន ជា គឺមេធាវី ហ្សាស្តេ ប៉ោ បានសួរដេញដោលសាក្សី គង់ គីម ដោយផ្តោតជាសំខាន់លើការផ្តល់សក្ខីកម្មរបស់សាក្សីជាមួយការិយាល័យសហចៅក្រមស៊ើបអង្កេត និងការផ្តល់បទសម្ភាសន៍ជាមួយនឹងមជ្ឈមណ្ឌលឯកសារកម្ពុជា ។ បន្ទាប់ពីបានសួរសំណួរទាក់ទងនឹងការប្រយុទ្ធនៅមុនថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ មេធាវី ហ្សាស្តេ ប៉ោ បានលើកយកឯកសារបទសម្ភាសន៍រវាងប្រវត្តិវិទូ បេិន ឃៀរនិន ជាមួយនឹងសម្តេច ហេង សំរិន ដែលធ្វើឡើងនៅខែធ្នូ ឆ្នាំ១៩៩១ ស្តីពីការប្រយុទ្ធនៅមុនការដួលរលំទីក្រុងភ្នំពេញ ។ មេធាវី ហ្សាស្តេ ប៉ោ បានយកស្រង់សម្តីរបស់សម្តេច ហេង សំរិន ដែលជាអតីតមេបញ្ជាការកងពលនៅភូមិភាគបូព៌ា ដែលបាននិយាយនៅក្នុងបទសម្ភាសន៍នោះដើម្បីស្នើឲ្យសាក្សីធ្វើការបញ្ជាក់ ។ ការលើកយកបទសម្ភាសន៍នេះ មកសាកសួរសាក្សីត្រូវបានតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ថារីក អាប់ឌុលហាក់ជំទាស់ ដោយអះអាងថា មេធាវីការពារក្តី នួន ជា បានប្រើប្រាស់សក្ខីកម្មរបស់អ្នកដទៃដើម្បីស្នើឲ្យសាក្សីធ្វើការបញ្ជាក់ និងថាមេធាវីអាចសួរត្រឹមតែអ្វីដែលជាបទពិសោធន៍ផ្ទាល់ដែលសាក្សីធ្លាប់បានឆ្លងកាត់តែប៉ុណ្ណោះ ។ អង្គជំនុំជម្រះបានយល់ស្របចំពោះការជំទាស់របស់តំណាងសហព្រះរាជអាជ្ញា ដោយផ្តល់ហេតុផលថា មេធាវីការពារក្តី នួន ជា មិនអាចលើកយកចម្លើយរបស់អ្នកដទៃមកធ្វើជាមូលដ្ឋានក្នុងការចោទសួរចំពោះសាក្សីបានទេ ។ ភ្លាមៗបន្ទាប់ពីអង្គជំនុំជម្រះបានសម្រេចដូច្នេះ មេធាវីអន្តរជាតិការពារក្តីជនជាប់ចោទ អៀង សារី គឺមេធាវី ម៉ៃឃើល ការណាវ៉ាស បានធ្វើការកត់សម្គាល់ថា នៅពេលក្រុមរបស់ខ្លួនប្រើប្រាស់វិធីសាស្ត្រក្នុងការសួរសំណួរដូចអ្វីដែលមេធាវីការពារក្តី នួន ជា កំពុងតែធ្វើ គឺពុំមានជំទាស់ពីសំណាក់តំណាងសហព្រះរាជអាជ្ញា ឬរារាំងដោយអង្គជំនុំជម្រះឡើយ ប៉ុន្តែនៅពេលក្រុមមេធាវីការពារក្តី នួន ជា ប្រើប្រាស់វិធីសាស្ត្រដូចគ្នានេះ បែរជាមានការជំទាស់ និងមិនត្រូវបានអនុញ្ញាតឲ្យសួរទៅវិញ ។ ដើម្បីដោះស្រាយបញ្ហានេះ ចៅក្រម ឡាវើញ បានបកស្រាយចំពោះសេចក្តី សម្រេចរបស់អង្គជំនុំជម្រះថា អង្គជំនុំជម្រះមិនបានហាមឃាត់អំពីវិធីសាស្ត្រក្នុងការសាកសួរសាក្សីរបស់ក្រុមមេធាវីការពារក្តី នួន ជា ទេ ប៉ុន្តែអ្វីដែលសំខាន់អង្គជំនុំជម្រះមិនអនុញ្ញាតឲ្យមានការលើកយកសក្ខីកម្មរបស់អ្នកដទៃមកសួរដេញដោលចំពោះសាក្សី ។

បន្ទាប់មក មេធាវី ហ្សាស្តេ បានបន្តសំណួររបស់ខ្លួនជាច្រើនដោយលើកយកបទសម្ភាសន៍ ដែលសាក្សី គង់ គីម ធ្លាប់បានធ្វើជាមួយនឹងមជ្ឈមណ្ឌលឯកសារកម្ពុជា និងចម្លើយដែលបានឆ្លើយនូវក្នុងអំឡុងពេលសវនាការដើម្បីឲ្យសាក្សីធ្វើការបញ្ជាក់ ។ ពេលវេលាសួរដេញដោលរបស់ក្រុមមេធាវី នួន ជា បានចំណាយភាគច្រើនលើការពិភាក្សាទាក់ទងនឹងការជំទាស់របស់តំណាងសហព្រះរាជអាជ្ញា ដោយសារតែមេធាវី ហ្សាស្តេ ប៉ោ បានលើកយកឯកសារមួយទៀត ដែលនិពន្ធដោយ ហ្វីលីព ស្ហុត ដើម្បីឲ្យសាក្សីបញ្ជាក់ ។

ការសួរដេញដោលសាក្សី គង់ គីម ដោយក្រុមមេធាវីការពារក្តី នួន ជា បានបញ្ចប់ទាំងស្រុង នៅរសៀលថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១២ ។

# សវនាការស្តាប់សក្ខីកម្មសាក្សី ស៊ុំ ជា
## ថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ២០១២

នៅថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ២០១២ អង្គជំនុំជម្រះសាលាដំបូង នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការ កម្ពុជាបានប្រកាសបន្ត សវនាការសួរដេញដោលសាក្សី ស៊ុំ ជា ដែលជាអតីតទាហានខ្មែរ ក្រហម ។ គួររំឭកថា នៅក្នុងឯកសារប្រវត្តិរូបដែលសម្ភាសន៍ ដោយបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជានៅឆ្នាំ២០០៣សាក្សី មានឈ្មោះ វ៉ៃ ជា ហៅ សែន ។ សវនាការសាកសួរសាក្សី ស៊ុំ ជា បានប្រព្រឹត្តទៅរយៈពេលមួយថ្ងៃពេញ ដោយមានការចូលរួមពី ប្រជាពលរដ្ឋចំនួន៣០០នាក់មកពីខេត្តព្រៃវែង និងតាកែវនៅ


សាក្សី ស៊ុំ ជា
(ប្រភព ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)

ក្នុងបន្ទប់សវនាការ ។ ផ្ទុយទៅវិញ ក្នុងពេលដំណើរការសវនាការ នេះដែរពុំមានវត្តមានរបស់ជនជាប់ចោទ អៀង សារី ទេដោយ សារជនជាប់ចោទមានបញ្ហាសុខភាព ។ កិច្ចដំណើរការសាកសួរ នេះ ផ្តើមឡើងដោយប្រធានអង្គជំនុំជម្រះ គឺចៅក្រម និល ណុន បន្ទាប់តំណាងសហព្រះរាជអាជ្ញា និងក្រុមមេធាវីនាំមុខតំណាង ដើមបណ្តឹងរដ្ឋប្បវេណី និងក្រុមមេធាវីការពារក្តីដោយផ្តោត សំខាន់ទៅលើរចនាសម្ព័ន្ធយោធា, ការចាប់ខ្លួនទាហាននៅជំនាន់ លន់ នល់ និងស្ថានភាពជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ។ ដោយឡែកក្រុមមេធាវីការពារក្តី ខៀវ សំផន បានបញ្ជាក់ថា ខ្លួន ពុំមានសំណួរដើម្បីចោទសួរសាក្សីទេ ។

### ១) ប្រវត្តិសាវតាររបស់សាក្សី ស៊ុំ ជា

ចៅក្រម និល ណុន បានចាប់ផ្តើមដោយសាកសួរអំពីប្រវត្តិ សវតាររបស់សាក្សីមុនពេលប្រគល់វេទិកាជូនភាគីផ្សេងទៀត ។ ឆ្លើយតបនឹងសំណួរនេះ សាក្សីបានបញ្ជាក់ថា ខ្លួនមានឈ្មោះ ស៊ុំ ជា អាយុ ៥៩ឆ្នាំ កើតនៅភូមិបឹងណាយ ខេត្តកំពង់ចាម ។ បច្ចុប្បន្ន រស់នៅស្រុកព្រៃឈរ ខេត្តកំពង់ចាម មានមុខរបរធ្វើស្រែចំការ និងជាជាងកាត់សក់ ។ សាក្សីបានបន្តថា ខ្លួនមានឪពុកឈ្មោះ វ ស៊ុំ ម្តាយឈ្មោះ ជុំ ស៊ី និងប្រពន្ធឈ្មោះ ប្រាក់ សំអាត ។ បន្ទាប់មក លោកប្រធានបានណែនាំអំពីសិទ្ធិ និងកាតព្វកិច្ចរបស់សាក្សីក្នុង ពេលកិច្ចដំណើរការនីតិវិធី ។

### ២) ការសាកសួរដោយតំណាងសហព្រះរាជអាជ្ញា

បន្ទាប់ពីបញ្ចប់ការសាកសួរ ចៅក្រម និល ណុន បានផ្ទេរ វេទិកាជូនតំណាងសហព្រះរាជអាជ្ញា ដើម្បីសាកសួរបន្តដែលមាន តំណាងសហព្រះរាជអាជ្ញាជាតិ សុង ឆវ៉ន និងតំណាងសហព្រះរាជ អាជ្ញាអន្តរជាតិ ឌេ លីសាក់ ។

#### ២.១) តំណាងសហព្រះរាជអាជ្ញាជាតិ

តំណាងសហព្រះរាជអាជ្ញាជាតិ សុង ឆវ៉ន បានចាប់ផ្តើម សាកសួរសាក្សីដោយផ្តោតទៅលើមូលហេតុដែលនាំសាក្សីចូល ធ្វើយោធាខ្មែរក្រហម ។ ឆ្លើយតបនឹងសំណួរនេះ សាក្សីបញ្ជាក់ថា ខ្លួនចូលធ្វើយោធានៅឆ្នាំ១៩៧២ នៅកងពលទី១ស្ថិតនៅភូមិ បឹងណាយដែលមាន វឿន ជាប្រធាន ។ សាក្សីបានបន្ថែមថា ខ្លួនចូលធ្វើយោធានៅពេលនោះដោយសារមានការអំពាវនាវពី សម្តេច សីហនុ ។ ឆ្លើយតបនឹងសំណួរបន្ទាប់ទាក់ទងនឹងព្រឹត្តិការណ៍ មុនចូលមកដល់ទីក្រុងភ្នំពេញ សាក្សីបានបញ្ជាក់ថា នៅពេលនោះ កងទ័ពបានមកឈរជើងនៅបាសិតប្រហែលពីរខែទើបវាយចូល មកភ្នំពេញ ដោយវាយពីខាងត្បូងប្រសិតទៅខ្ទួញ និងត្រឡោក បែកទើបចូលមកដល់ទីក្រុង ។ ពេលមកដល់ខ្លួនបានឃើញមនុស្ស

ម្នាជាច្រើននាក់រួមមាន ប្រជាជនស៊ីវិល និងទាហាន លន់ នល់ ដែលលើកទង់សរ ដើម្បីទទួលកងទ័ពខ្មែរក្រហម គឺនៅក្នុងឆ្នាំ ១៩៧៥ ។ ក្រោយពេលចូលមកដល់ យោធាខ្មែរក្រហមបាន ប្រាប់ឲ្យប្រជាជនចេញពីទីក្រុងឲ្យអស់ក្នុងរយៈពេលបីថ្ងៃដោយ អះអាងថា អ្នកដែលបញ្ជាឲ្យប្រជាជនចាកចេញនោះឈ្មោះ ហាក់ ។ តំណាងសហព្រះរាជអាជ្ញាបានបន្តថា នៅពេលនោះ ហាក់ បានប្រាប់យោធាទាំងអស់ថា «ធ្វើម៉េចធ្វើទៅឲ្យតែប្រជាជនចេញ ពីទីក្រុង» ហើយភាពពិតមានយោធាខ្លះបានវាយដំ និងបាញ់ កាំភ្លើងទៅលើប្រជាជនណាដែលក្រាញនននាលមិនព្រមចាក ចេញ ។ សាក្សីបានបន្តថា មុខសញ្ញាដែល ហាក់ បានបញ្ជានោះ គឺនៅម្តុំផ្សារថ្មី ស្ពានជ្រោយចង្វារ និងគីឡូម៉ែតលេខ៩ ។ តំណាង សហព្រះរាជអាជ្ញាបានបន្តសួរថា តើមានការវាយដំទៅលើទាហាន លន់ នល់ ដែរឬទេ? ឆ្លើយតបនឹងសំណួរនេះ សាក្សីបានបញ្ជាក់ថា នៅពេលនោះមិនថាទាហាន ឬប្រជាជនធម្មតាទេ គឺសុទ្ធតែត្រូវ បានយោធាខ្មែរក្រហមវាយប្រសិនបើមានការរឹងទទឹង ។ សាក្សី បានបន្តថា នៅក្នុងស្ថានភាពជម្លៀសនោះ គឺអ្នកជំងឺត្រូវបាន បណ្តេញចេញពីមន្ទីរពេទ្យ ហើយអ្នកខ្លះស្លាប់នៅតាមផ្លូវទៀត ផង ។ សាក្សីបានបន្ថែមថា ខ្លួនមិនដឹងថាប្រជាជនដែលត្រូវបាន ជម្លៀសនោះនឹងត្រូវចេញទៅទីណាទៀតទេ ហើយការជម្លៀស នោះត្រូវចំណាយពេលប្រាំថ្ងៃទើបប្រជាជនចេញអស់ពីទីក្រុង ។

បន្ទាប់មក តំណាងសហព្រះរាជអាជ្ញាបានបន្តសួរអំពីការ អំពាវនាវរបស់ខ្មែរក្រហមឲ្យចាប់ខ្លួនទាហាន លន់ នល់ យកទៅ សម្លាប់ ។ ជាការឆ្លើយតប សាក្សីបានបញ្ជាក់ថា ក្រោយពេល យោធាចូលមកដល់បានប្រាំពីរថ្ងៃ ខ្មែរក្រហមបានជិះរថយន្ត ដោយមានចង្កាប់មេក្រូដើម្បីប្រកាសហៅអ្នកណាដែលធ្លាប់ធ្វើ ការរាជការនៅជំនាន់ចាស់ឲ្យត្រលប់ទៅធ្វើការវិញ ។ សាក្សីបាន បន្តថា នៅពេលនោះមានប្រជាជនខ្លះបានឆ្លើយកុហកថា ខ្លួន ធ្លាប់ធ្វើការនៅតាមផ្នែកផ្សេងៗ ប៉ុន្តែជាលទ្ធផលអ្នកទាំងនោះ ត្រូវបានបញ្ជូនយកទៅសម្លាប់នៅព្រៃកញ្ចៅទាំងអស់ ។

## ២.២) តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ

តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ឌេ លីសាក់ បានបន្ត សំណួរបន្ទាប់ពីតំណាងសហព្រះរាជអាជ្ញា ជាតិទាក់ទងនឹងការបោះ ទីតាំងរបស់យោធាខ្មែរក្រហម ។ ឆ្លើយតបនឹងសំណួរនេះ សាក្សី បានបញ្ជាក់ថា ពេលដែលខ្លួនចូលធ្វើយោធាដំបូងគឺមានទីតាំង នៅភូមិបឹងណាយ និងឈរជើងនៅទីនោះរហូតដល់ពេលវាយចូល មកដល់ភ្នំបាសិត និងចូលមកភ្នំពេញដោយឆ្លងកាត់តាមព្រៃក ក្តាម ។ ក្រោយមក ខ្លួនចូលមកធ្វើកងទ័ពនៅក្នុងកងពលលេខ១ ប៉ុន្តែនៅទីនោះខ្លួនគ្មានតួនាទីអ្វីឡើយ ។ បន្ទាប់មក តំណាងសហ ព្រះរាជអាជ្ញាអន្តរជាតិបានបន្តសួរទាក់ទងនឹងស្ថានភាពទាហាន លន់ នល់ ដែលខ្មែរក្រហមចាប់បាន ។ សាក្សីបានរៀបរាប់ថា ពេលចូលមកដល់ភ្នំពេញខ្មែរក្រហមបានប្រកាសតាមមេក្រូថា អ្នកណាជាតែទាហាននៅជំនាន់ចាស់នឹងត្រូវធ្វើការដដែល ប៉ុន្តែ ពេលនោះមិនឃើញមានទាហាន លន់ នល់ ទេដោយសារទាហាន ទាំងនោះបានដោះឯកសណ្ឋានចេញ ។ តំណាងសហព្រះរាជអាជ្ញា អន្តរជាតិបានបន្តដោយលើកយកឯកសារសម្ភាសន៍របស់សាក្សី ជាមួយសហចៅក្រមស៊ើបអង្កេត ដែលនិយាយអំពីការបាញ់ សម្លាប់ប្រជាជននៅពេលជម្លៀសដើម្បីឲ្យសាក្សីបញ្ជាក់ ។ ឆ្លើយ តបនឹងសំណួរនេះ សាក្សីបានរៀបរាប់ថា នៅពេលចូលមកដល់ នោះខ្លួនបានឈរជើងនៅស្ថានទូតបារាំង ហើយពេលនោះពុំមាន ការបាញ់ទៅលើប្រជាជនទេ ប៉ុន្តែ នៅពេលដែលយោធាមកពី ភូមិភាគបូព៌ាចូលមក ទើបមានការបាញ់ទៅលើប្រជាជនដែលរឹង ទទឹងមិនព្រមចាកចេញតាមការបញ្ជា ។ សាក្សីបានបន្ថែមថា នៅពេលនោះ ហាក់ គឺជាអ្នកបញ្ជាឲ្យប្រជាជនចេញពីទីក្រុង ។ តំណាងសហព្រះរាជអាជ្ញាអន្តរជាតិបានបន្តសួរថា តើការជម្លៀស ប្រជាជននៅពេលនោះគឺ ដើម្បីបោសសំអាត លន់ នល់ ឬយ៉ាង ណា? ឆ្លើយតបនឹងសំណួរនេះ សាក្សីបានទទួលស្គាល់ការលើក ឡើងរបស់តំណាងសហព្រះរាជអជ្ញា និងបញ្ជាក់បន្ថែមថាមូល ហេតុមួយទៀតគឺការទម្លាក់គ្រាប់បែករបស់ អាមេរិក ។ បន្ទាប់មក តំណាងសហព្រះរាជអាជ្ញាលើកយកឯកសារសម្ភាសន៍របស់ សាក្សី ដែលបានមាននិយាយអំពីស្ថានភាពរបស់ប្រជាជនក្នុង ពេលជម្លៀសដោយមានអ្នកយំ អ្នកជំងឺដែលត្រូវបានរុញតាម រទេះ និងអ្នកស្លាប់នៅតាមមន្ទីរពេទ្យ ។ ជាការឆ្លើយតប សាក្សី បានបញ្ជាក់ថា ខ្លួនពិតជាបានឃើញស្ថានភាពទាំងនោះនៅពេទ្យ កាល់ម៉ែតដែលនៅជិតស្ថានទូតបារាំង ខណៈពេលដែលខ្លួននៅ

ឈរជើងនៅទីនោះ ។ សាក្សីបានបញ្ជាក់ថា ទ័ពរបស់ខ្លួនក៏បានទៅដល់ពេទ្យកាល់ម៉ែតប្រហែលបួនប្រាំនាក់ដើម្បីឈរយាមតាមផ្លូវឲ្យប្រជាជនចេញឲ្យអស់ពីទីក្រុងក្នុងរយៈពេលប្រាំថ្ងៃ ។ សាក្សីបានបន្ថែមថា នៅពេលជម្លៀសនោះប្រជាជនមិនត្រូវបានផ្តល់បាយទឹកអ្វីឡើយ ។

ឆ្លើយតបនឹងសំណួរបន្ទាប់ទាក់ទងនឹងការចាប់ខ្លួនទាហាន លន់ នល់ វិញ សាក្សីបានបញ្ជាក់ថា ឲ្យតែទាហានគឺគេមិនគិតពីឋានៈបុណ្យសក្តិនោះឡើយ ហើយដើម្បីចាប់ទាហានបាន គឺគេប្រកាសតាមមេក្រូឲ្យមកធ្វើប្រវត្តិរូប ប៉ុន្តែខ្លួនមិនបានដឹងអំពីស្ថានភាពចាប់ខ្លួនចំពោះប្រជាជនធម្មតាទេ ។ សាក្សីបានបន្តរៀបរាប់ថា ចំពោះទាហានដែលគេចាប់បាននោះ ត្រូវបានយកទៅសម្លាប់នៅព្រៃកញ្ជោ ហើយខ្លួនបានដឹងរឿងនេះតាមរយៈ គឿន ។

បន្ទាប់មក តំណាងសហព្រះរាជអន្តរជាតិ ខេ លីសាក់ បានស្នើសុំ អង្គជំនុំជម្រះដើម្បីប្រើប្រាស់ឯកសារចម្លើយរបស់សាក្សីផ្សេងទៀត ដែលនឹងមិនចូលមកផ្តល់សក្ខីកម្មនោះទេដើម្បីឲ្យសាក្សីបញ្ជាក់ ។ ប៉ុន្តែការស្នើសុំនេះត្រូវបានមេធាវីការពារក្តី កាណាវ៉ាស ធ្វើការកត់សម្គាល់ ដោយលើកឡើងថាការប្រើប្រាស់វិធីសាស្ត្រសាកសួរបែបនេះមេធាវីការពារក្តី នួន ជា ធ្លាប់បានស្នើសុំរួចហើយទាក់ទងនឹងសៀវភៅរបស់ ហ្វីលីព ស្សុត ប៉ុន្តែតំណាងសហព្រះរាជអាជ្ញាបានជំទាស់ ។ ឆ្លើយតបនឹងការលើកឡើងនេះ តំណាងសហព្រះរាជអាជ្ញាបានបញ្ជាក់ថា ឯកសារដែលខ្លួនលើកឡើងនេះ គឺជាចម្លើយរបស់សាក្សី ដែលខុសគ្នានឹងករណីលើកឡើងពីសៀវភៅរបស់ ហ្វីលីប ស្សុត ដោយសារ ហ្វីលីប ស្សុត នឹងមកផ្តល់សក្ខីកម្មនៅក្នុងតុលាការនេះ ។ បន្ទាប់មក ចៅក្រម និល ណុន បានបង្គាប់មិនឲ្យសាក្សីឆ្លើយសំណួររបស់សហព្រះរាជអាជ្ញា និងរំឭកដល់តំណាងសហព្រះរាជអាជ្ញាមិនឲ្យយកសក្ខីកម្មរបស់សាក្សីផ្សេង មកសួរសាក្សីដែលកំពុងធ្វើសក្ខីកម្ម ។ ចៅក្រម ឡាវើញ បានយល់ស្របចំពោះការយោងរបស់តំណាងសហព្រះរាជអាជ្ញា ដោយបញ្ជាក់បន្ថែមថា ការលើកឡើងរបស់តំណាងសហព្រះរាជអាជ្ញា គឺយោងទៅលើហេតុការណ៍មួយដែលលើកឡើងដោយសាក្សីហើយករណីនេះមិនមែនជាការវិភាគទេ ។ ជាចុងក្រោយ ចៅក្រម ឡាវើញ បានរំឭកដល់តំណាងសហព្រះរាជអាជ្ញាឲ្យរៀបចំសំណួរឲ្យបានល្អដើម្បីឲ្យសាក្សីងាយស្រួលយល់ ។

មុនពេលបញ្ចប់ តំណាងសហព្រះជាអាជ្ញាអន្តរជាតិ ខេល លីសាក់ បានបន្តសួរទាក់ទងនឹងការសម្លាប់ទាហាន លន់ នល់ នៅទួលគោក ។ ឆ្លើយតបនឹងសំណួរនេះដែរ សាក្សីបានបញ្ជាក់ថា មានតែទាហាន លន់ នល់ ទេដែលរងការសម្លាប់ពីព្រោះករណីនេះពុំមានកើតឡើងចំពោះប្រជាជនធម្មតាឡើយ ។

### ៣) ការសាកសួរដោយមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី

បន្ទាប់ពីបញ្ចប់ការសាកសួររបស់តំណាងសហព្រះរាជអាជ្ញា ចៅក្រម និល ណុន បានផ្ទេរវេទិកាជូនមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ។ មេធាវីជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណី ពេជ្រ អង្គ បានក្រោកឈរបញ្ជាក់ជូនអង្គជំនុំជម្រះក្នុងការផ្ទេរសិទ្ធិជូនមេធាវីជាតិ ទី ស្រីនណា និងមេធាវីអន្តរជាតិ នូស៊ីន សាកាវ៉ាទី ក្នុងការសាកសួរសាក្សី ។

### ៣.១) ការសាកសួរដោយមេធាវីជាតិ

មេធាវីជាតិ ទី ស្រីនណា បានចាប់ផ្តើមសួរដោយផ្តោតទៅលើចំនួនកងពល ប៉ុន្តែសាក្សីបានបញ្ជាក់ថា ខ្លួនមិនបានដឹងពីចំនួនជាក់លាក់នោះទេ ពីព្រោះយោធាតូចៗមិនអាចដឹងការងារអ្វីច្រើនទេ ។ សាក្សីបានបន្តថា យោធានៅក្នុងកងពលខ្លួន គឺសុទ្ធតែមានការបណ្តុះបណ្តាលក្នុងការវាយយកទីក្រុង និងបង្រៀនឲ្យយោធាមានការឈឺចាប់ដោយសារអាមេរិកទម្លាក់គ្រាប់បែកដែលបណ្តាលឲ្យឆេះផ្ទះប្រជាជន ។ ទាក់ទងនឹងសត្រូវរបស់អង្គការវិញ សាក្សីបានបញ្ជាក់ថា ក្រៅពីអាមេរិកខ្មាំងរបស់អង្គការគឺសំដៅទៅលើទាហានក្នុងរបប លន់ នល់ ។ សាក្សីនិយាយថា មានមេដឹកនាំខ្មែរក្រហមមួយចំនួនបានទៅដល់កន្លែងបណ្តុះបណ្តាល ប៉ុន្តែនៅពេលនោះ ខ្លួនមិនស្គាល់ មិនដែលឮឈ្មោះមេដឹកនាំខ្មែរក្រហមទាំងនោះទេ ។ មេធាវីបានបន្តសួរទាក់ទងនឹងការរៀបចំផែនការវាយយកទីក្រុងភ្នំពេញ ។ ទាក់ទងនឹងបញ្ហានេះ សាក្សីបានបញ្ជាក់ថា នៅពេលនោះមានការបញ្ជាពីថ្នាក់លើមកឲ្យ ហាក់ ដែលជាប្រធានកងពល ហើយ ហាក់ ជាអ្នកផ្សព្វផ្សាយបន្តនៅថ្នាក់ក្រោម ។ សាក្សីបានបញ្ជាក់ថា នៅពេលកងទ័ពខ្មែរក្រហម

បានចូលមកដល់ទីក្រុងភ្នំពេញមិនឃើញមានទាហាន លន់ នល់ ទេដោយសារតែទាហាននៅលាយឡំគ្នាជាមួយប្រជាជន ។ មេធាវីបានបន្តសួរទាក់ទងនឹងមធ្យោបាយនៃការជម្លៀសប្រជាជនចេញពីទីក្រុង ហើយសាក្សីបានបញ្ជាក់ថា នៅពេលនោះមានការប្រកាសថា អាមេរិកនឹងទម្លាក់គ្រាប់បែក ដូច្នេះប្រជាជនត្រូវតែចាកចេញមួយរយៈ ប៉ុន្តែនឹងត្រូវត្រលប់មកវិញក្នុងរយៈពេលបីបួនថ្ងៃក្រោយមក ។ នៅពេលនោះមានការដាក់កុងត្រូល ដើម្បីឆែកឆេររកមើលខ្មាំងទៀតផង ។ បន្ទាប់មក មេធាវីបានលើកឡើងអំពីស្ថានភាពនៅក្នុងស្ថានទូតបារាំងក្នុងពេលជម្លៀសដើម្បីឲ្យសាក្សីបញ្ជាក់ ។ ជាការឆ្លើយតប សាក្សីបានបញ្ជាក់ថា ក្នុងពេលជម្លៀសនោះពុំមានប្រជាជនណាម្នាក់រត់ចូលទៅក្នុងស្ថានទូតឡើយ ហើយពេលនោះសូម្បីតែព្រះសង្ឃក៏ពុំមានដែរ ។ មេធាវីជាតិបានបន្តសួរថា តើនៅពេលនោះមានការប្រកាសអំពីផែនការរៀបចំទីក្រុងដែរឬទេ? ឆ្លើយតបនឹងសំណួរនេះសាក្សីបានបញ្ជាក់ថា បន្ទាប់ពីប្រជាជនចេញពីទីក្រុងអស់ទៅ គឺពុំមានការកសាងអ្វីទេគ្រាន់តែមានការគាស់ការ៉ូដើម្បីដាំដើមដូងនៅតាមដងផ្លូវតែប៉ុណ្ណោះ ។ សាក្សីបានបន្ថែមថា បន្ទាប់ពីទទួលបានជ័យជម្នះ ខ្លួនធ្លាប់បានទៅចូលរួមប្រជុំនៅស្តាតអូឡាំពិកដើម្បីស្តាប់សុន្ទរកថា របស់លេខាបក្សគឺ ប៉ុល ពត ប៉ុន្តែដោយសារពេលនោះមានកងទ័ពមកចូលរួមច្រើន ខ្លួនមិនបានឃើញមុខលេខាបក្សនៅពេលនោះទេ ។ មេធាវីជាតិបានបន្តសំណួរទាក់ទងនឹងការប្រកាសមិនឲ្យចាយលុយ បន្ទាប់ពីទទួលបានជ័យជម្នះ ។ សាក្សីបានរៀបរាប់ថា ខ្លួនបានឮតៗគ្នាដែរអំពីការហាមឃាត់មិនឲ្យចាយលុយ ។ ឆ្លើយតបនឹងសំណួរបន្ទាប់ សាក្សីបានបន្តថា ក្រោយពេលទទួលបានជ័យជម្នះកងទ័ពក៏ត្រូវបានបញ្ជូនឲ្យទៅធ្វើការជីកប្រឡាយដូចប្រជាជនធម្មតាដែរ ហើយស្ថានភាពរស់នៅរបស់ប្រជាជននៅពេលនោះពិតជាមានការការលំបាកណាស់ ។

### ៣.២) ការសាកសួរដោយមេធាវីអន្តរជាតិ

បន្ទាប់ពីបញ្ចប់ការសាកសួរសាក្សីដោយមេធាវីជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណី មេធាវីអន្តរជាតិបានបន្តការសាកសួរទាក់ទងនឹងស្ថានភាពជម្លៀសអ្នកជំងឺចេញពីមន្ទីរពេទ្យកាល់ម៉ែត និងការផ្តល់សេវាកម្ម និងផ្តល់ថ្នាំដល់អ្នកជំងឺ ។ ទាក់ទងនឹងបញ្ហានេះ សាក្សីបានរៀបរាប់ថា នៅពេលនោះអ្នកជំងឺត្រូវបានបណ្តេញចេញពីមន្ទីរពេទ្យ ហើយពុំមានផ្តល់សេវាកម្មអ្វីឡើយសម្រាប់អ្នកជំងឺទេ ។ សាក្សីបានបន្ថែមថា ចំពោះយោធាខ្មែរក្រហមវិញ គឺគេរៀបចំឲ្យមានពេទ្យមួយសម្រាប់ព្យាបាល គឺនៅពេទ្យធំ ប៉ុន្តែនៅទីនោះពុំមានថ្នាំដែលនាំចូលពីក្រៅប្រទេសនោះទេ ។ មេធាវីបានបន្តសួរថា តើមានការបណ្តេញប្រជាជននៅតាមផ្ទះដែរឬទេ? ឆ្លើយតបនឹងសំណួរនេះសាក្សីបានរៀបរាប់ថា នៅពេលជម្លៀសនោះពុំមានការបណ្តេញប្រជាជនតាមផ្ទះទេ ហើយខ្លួនក៏មិនដែលឃើញយោធាធ្វើបាបនារីនៅពេលនោះដែរ ។ មុនពេលបញ្ចប់មេធាវីបានបន្តសំណួរទាក់ទងនឹងការប្រយុទ្ធគ្នាដោយអាវុធរបស់ទាហាន លន់ នល់ នៅពេលកងទ័ពខ្មែរក្រហមចូលមកទីក្រុងភ្នំពេញ ។ សាក្សីបានបញ្ជាក់ថា នៅពេលនោះពុំមានការប្រយុទ្ធគ្នាទៀតទេ គឺមានតែប្រជាជនលើកទង់ជ័យសដើម្បីអបអរ ហើយក្រោយមកទើបមានការចាប់ខ្លួនទាហាន លន់ នល់ យកទៅសម្លាប់នៅព្រែកព្នៅ ។

### ៤) ការសាកសួរដោយចៅក្រម ហ្សង់ម៉ាក ឡាវីញ

ចៅក្រម ហ្សង់ម៉ាក ឡាវីញ បានចាប់ផ្តើមសួរសាក្សីដោយលើកឡើងពីការបាញ់កាំភ្លើងនៅភ្នំបាសិត ទៅលើភ្នំពេញ ប៉ុន្តែសាក្សីបានបញ្ជាក់ថា ការបាញ់នោះមិនចូលភ្នំពេញទេ គឺចូលទៅខ្ញញដែលនាំឲ្យឆេះផ្ទះ ប្រជាជនអស់ជាច្រើនខ្នង ។ លោកចៅក្រមបានបន្តសួរទាក់ទងនឹងការប្រកាសចាប់ខ្លួនទាហាន លន់ នល់ ។ សាក្សីបានបញ្ជាក់ថា ខ្លួនបានដឹងអំពីការប្រកាសតាមមេក្រូនៅពេលនោះ ប៉ុន្តែខ្លួនមិនដឹងថាមេក្រូនោះយកមកពីណាទេ ហើយខ្លួនក៏មិនបានឃើញដែរ ។ ចំពោះទាហាន លន់ នល់ វិញ គឺមានការប្រមូល និងដឹកតាមឡានយកទៅសម្លាប់ ។ សាក្សីបានបន្ថែមថា ពេលចូលដល់ទីក្រុងភ្នំពេញដំបូងមានការប្រកាសព័ត៌មានតាមគេអូ ។ ខ្លួនពុំមានវិទ្យុស្តាប់ទេ ។ ខណៈនោះ ខ្លួនត្រូវបានចាត់តាំងឲ្យទៅយាមនៅមុខពេទ្យកាល់ម៉ែត ប៉ុន្តែពុំមានអ្នកជំងឺនៅក្នុងពេទ្យទៀតទេដោយសារអ្នកជំងឺទាំងនោះត្រូវបានបញ្ជូនចេញក្នុងរយៈពេលពីរថ្ងៃអស់ទៅហើយ ។ សាក្សីបានបន្តថា ពេលខ្លួនកំពុងយាមនៅទីនោះ ខ្លួនបានឃើញជនជាតិហ្វីលីពីនខ្លះដែរ ប៉ុន្តែពីរបីថ្ងៃក្រោយមកអ្នកទាំងនោះក៏បាត់ខ្លួនមិនដឹងទៅទីណាទេ ។

## ៥) ការសួរដេញដោលដោយក្រុមមេធាវីការពារក្តី

### ៥.១) ក្រុមមេធាវីការពារក្តី នួន ជា

មេធាវីជាតិ សុន អរុណ បានចាប់ផ្តើមសួរដោយឲ្យសាក្សីបញ្ជាក់អំពីមូលហេតុដែលនាំឲ្យសាក្សីចូលធ្វើកងទ័ពខ្មែរក្រហម ។



យោធាខ្មែរក្រហមនៅក្បែរយន្តហោះបែកបាក់នៅព្រលានយន្តហោះពោធិចិនតុង (សព្វថ្ងៃព្រលានយន្តហោះអន្តរជាតិភ្នំពេញ)
(ប្រភព : មជ្ឈមណ្ឌលឯកសារកម្ពុជា)

សាក្សីបានបញ្ជាក់ថា ខ្លួនបានចូលធ្វើទ័ពតាំងពីអាយុ១៨ឆ្នាំដោយស្ម័គ្រចិត្ត ដោយសារមានការអំពាវនាវរបស់សម្តេចសីហនុ ហើយពេលនោះខ្លួនគ្រាន់តែជាទ័ពធម្មតាពុំមានឋានៈតួនាទីអ្វីឡើយ ។ មេធាវី បានបន្តសួរឲ្យសាក្សីបញ្ជាក់ ទាក់ទងនឹងការបាញ់ប្រជាជនដោយយោធាមកពីភូមិភាគបូព៌ា ក្នុងករណីដែលប្រជាជនមិនព្រមចេញតាមការបញ្ជា ។ ឆ្លើយតបនឹងសំណួរនេះ សាក្សីបានបញ្ជាក់ថា ខ្លួនបានដឹងអំពីបញ្ហានេះតាមរយៈយោធានៅក្នុងកងជាមួយគ្នាតែប៉ុណ្ណោះ ។ លោកមេធាវី បានបន្តសួរទាក់ទងតួនាទីរបស់ គឿន ហើយសាក្សីបានបញ្ជាក់ថា ពីមុន គឿន មានតួនាទីជាប្រធានកងវីរៈសេនាតូច ហើយក្រោយមកត្រូវបានដកចេញពី

តំណែងដោយសារខុសសីលធម៌ ។ ចំពោះស្ថានភាពនៃការចូលមកដល់ទីក្រុងភ្នំពេញ សាក្សីបានបញ្ជាក់ថា បន្ទាប់ពីវាយចូលទីក្រុងហើយ ទើបខ្មែរក្រហមដាក់ផែនការឲ្យជម្លៀសប្រជាជនចេញដោយខ្លួនពុំបានដឹងជាមុនពីគម្រោងនោះឡើយ ។

បន្ទាប់មកមេធាវីអន្តរជាតិ ហ្សាស្តើ ប៉ៅ បានបន្តសំណួរពីមេធាវីជាតិ សុន អរុណ ដោយផ្តោតទៅលើការទម្លាប់គ្រាប់បែករបស់សហរដ្ឋអាមេរិក ។ សាក្សីបានបញ្ជាក់ថា ខ្លួនបានដឹងពីការទម្លាក់គ្រាប់ បែករបស់សហរដ្ឋអាមេរិក ដែលបណ្តាលឲ្យមានការខូចខាតផ្ទះប្រជាជនជាច្រើនខ្នង ព្រមទាំងមានឆេះវត្តអារាមទៀតផង ។ សាក្សីបានបន្តថា ដោយសារការទម្លាក់គ្រាប់បែកនេះ ខ្លួនបានបាត់បង់បងប្រុស និងបងជីដូនមួយនៅពេលនោះ ។ បន្ទាប់មកមេធាវីបានស្នើសុំបង្ហាញឯកសារទាក់ទងនឹងទីតាំងឈរជើងរបស់សាក្សីដែលនៅម្តុំផ្សារថ្មី ទួលគោក គីឡូម៉ែតលេខ៩ និងស្ពានជ្រោយចង្វារ ។ សាក្សីបានយល់ស្របចំពោះការលើកឡើងនោះ ។ សាក្សីបានបន្តថា នៅពេលនោះទ័ពត្រូវបានបែងចែកទៅតាមតំបន់ផ្សេងៗគ្នា ហើយមិនអាចជ្រៀតជ្រែកទៅតំបន់ផ្សេងទៀតបានទេ ។ ដោយផ្នែកក្រុមរបស់ខ្លួនអាចទៅការពារនៅម្តុំវត្តភ្នំបានទេ ។ បន្ទាប់មក មេធាវីបានបន្តសួរទាក់ទងនឹងស្ថានភាពនៅមន្ទីរពេទ្យកាល់ម៉ែត ។ សាក្សីបានរៀបរាប់ថា ថ្ងៃដែលខ្មែរក្រហមចូលមកដល់ភ្នំពេញនោះ នៅមន្ទីរពេទ្យកាល់ម៉ែតមានតែអ្នកជំងឺ ដោយគ្មានគ្រូពេទ្យនៅមើលការខុសត្រូវអ្វីឡើយ ។

មេធាវីអន្តរជាតិ បានបន្តដោយអានសម្រង់ឃ្លាចេញពីសៀវភៅកម្ពុជា១៩៧៥-១៩៨២ របស់ ម៉ៃឃើល វីកឃើរី ដែលពាក់ព័ន្ធនឹងចម្លើយរបស់សាក្សី ។ ភ្លាមនោះ តំណាងសហព្រះរាជអាជ្ញាបានជំទាស់នឹងការសារសួររបស់មេធាវីដោយអះអាងថា ករណីនេះមេធាវីការពារក្តីធ្លាប់បានជំទាស់ចំពោះការសួររបស់ខ្លួនរួចហើយ ដោយស្នើសុំឲ្យខ្លួនសួរតែអ្វីដែលសាក្សីបានដឹងតែប៉ុណ្ណោះ ដោយមិនចាំបាច់ដកស្រង់ចេញពីឯកសារនោះទេ ។ ដើម្បីដោះស្រាយបញ្ហាទាំងនេះ ចៅក្រម ហ្សង់ម៉ាក ឡាវែញ បានបញ្ជាក់ថា ដោយយោងទៅលើសេចក្តីសម្រេចពីមុននោះសាក្សីមិនចាំបាច់ប្រើវិធីសាស្ត្រសាកសួរដោយ យោងទៅលើសៀវភៅនោះទេ ដោយផ្តល់ហេតុផលថា អ្នកនិពន្ធមិនមែនជាសាក្សី ឬពុំមានវត្តមាននៅក្នុងប្រទេសកម្ពុជានៅក្នុងអំឡុងពេលនោះទេ ។ មេធាវី ហ្សាស្តើ ប៉ៅ បានបញ្ជាក់ថា ខ្លួនមិនយល់ច្បាស់ អំពីសេចក្តីសម្រេចរបស់អង្គជំនុំជម្រះទេដោយហេតុថា តំណាងសហព្រះរាជបានយោងទៅលើសៀវភៅរបស់អ្នកនិពន្ធ ដេវីដ ឆែនដល័រ និង ហ្វីលីព ស្សូត ខណៈពេលដែលអ្នកទាំងពីរនេះពុំមានវត្តមាននៅក្នុងប្រទេសកម្ពុជានៅក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ ដូច្នេះខ្លួនមិនដឹងថា តើសៀវភៅរបស់អ្នកនិពន្ធណាខ្លះដែលខ្លួនអាចយោងបាននោះទេ ។ ជាការឆ្លើយតបនឹងការលើកឡើងនេះ តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ឌេ លីសាក់ បានអះអាងជំទាស់នឹងការលើកឡើងរបស់មេធាវីដោយបញ្ជាក់ថា ភាគីសហព្រះរាជអាជ្ញាបានយោងទៅលើសៀវភៅរបស់ ហ្វីលីព ស្សូត ដោយសារសាក្សីដែលខ្លួនសួរនោះបានផ្តល់បទសម្ភាសន៍ជាមួយ ហ្វីលីព ស្សូត ដែលចម្លើយទាំងនោះគឺយោងទៅលើចម្លើយរបស់សាក្សីតែប៉ុណ្ណោះ ។

បន្ទាប់ពីបញ្ចប់ការទាញហេតុផលនេះមក មេធាវីអន្តរជាតិ ហ្សាស្តើ ប៉ៅ បានបន្តសួរថា តើទ័ពដែលមកពីភូមិភាគបូព៌ានោះជាទ័ពខ្លាំងលើផ្នែកអ្វី? ជាការឆ្លើយតប សាក្សីបានបញ្ជាក់ថា ទ័ពទាំងនោះជាទ័ពខ្លាំង ដោយសារពេលជម្លៀសប្រជាជន ទ័ពទាំងនោះហ៊ានធ្វើគ្រប់បែបយ៉ាងដើម្បីដេញប្រជាជនចេញពីទីក្រុង ។ សាក្សីបានបន្តថា ទ័ពដែលមកពីភូមិភាគបូព៌ា គឺយាមចាប់តាំងពីផ្សារថ្មីទៅខាងកើតតាមមាត់ទន្លេ ។ ឆ្លើយតបនឹងសំណួរបន្ទាប់របស់មេធាវី សាក្សីបានបញ្ជាក់ថា ទ័ពដែលមកពីភូមិភាគបូព៌ាស្លៀកឯកសណ្ឋានខ្មៅដូចទ័ពខ្មែរក្រហមឯទៀតដែរ ។ ម្យ៉ាងទៀតទ័ពទាំងអស់ត្រូវបានបែងចែកទៅតាមភូមិភាគ ហើយមិនអាចឆ្លងពីកងពលមួយទៅកងពលមួយទៀតបានទេ ។ បន្ទាប់មក មេធាវីអន្តរជាតិ ហ្សាស្តើ ប៉ៅ បានលើកឡើងទាក់ទងនឹងបទសម្ភាសន៍របស់សម្តេច ហេង សំរិន ជាមួយ ប៉ែន យៀនិន ប៉ុន្តែករណីនេះមិនត្រូវបានចៅក្រម និល ណុន អនុញ្ញាតឲ្យសាកសួរទេ ដោយសារតែបញ្ហានេះ ត្រូវបានអង្គជំនុំជម្រះបានសម្រេចពីមុនរួចហើយក្នុងការយោងទៅលើការដកស្រង់នៅក្នុងឯកសារផ្សេងទៀត ។ ចំពោះករណីនេះ តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ឌេល លីសាក់ បានលើកឡើងដូចការជំទាស់នៅផ្នែកខាងលើដែរ ហើយ

ចៅក្រម និល ណុន បានបញ្ជាក់ជូនភាគីឲ្យយោងទៅលើសេចក្តីសម្រេចរបស់ខ្លួនកាលពីមុន ។ មេធាវីអន្តរជាតិ ហ្សារ៉ស្តើ ប៉ៅ បានបន្តសួរសាក្សីថា តើទ័ពមកពីភូមិភាគបូព៌ាទាំងអស់សុទ្ធតែជាទ័ពខ្លាំងពិតដែរឬទេ? ទាក់ទងនឹងបញ្ហានេះ សាក្សីបានបញ្ជាក់ថា ទាំងទ័ពដែលមកពីភូមិភាគបូព៌ា និងទ័ពដែលមកពីនិរតីសុទ្ធតែខ្លាំងដូចគ្នា ដោយសំដៅលើភាពម៉ឺងម៉ាត់ក្នុងការជម្លៀសប្រជាជន ។ ចំណែកទ័ពនៅភូមិភាគខុត្តរវិញ មានចរិតទន់ភ្លន់ និងម៉ឺងម៉ាត់ ។ លោកមេធាវីអន្តរជាតិបានបន្តទាក់ទងនឹងការរៀបចំមេក្រូមុនពេលជម្លៀសប្រជាជន ។ សាក្សីបានបញ្ជាក់ថា ខ្លួនមិនដឹងពីការរៀបចំនោះទេ ហើយខ្លួនក៏មិនបានឮពីការប្រកាសនោះដែរ ។ សាក្សីបានឮ គឿន និយាយប្រាប់ខ្លួនថា ក្រោយការចូលទីក្រុងភ្នំពេញបានប្រហែល៧ថ្ងៃ គឺមានការប្រកាសតាមចាប់ខ្លួនទាហាន លន់ នល់ ។

មេធាវីបានបន្តសួរថា តើមុនពេលចូលមកដល់ទីក្រុងនោះមានការផ្សាយតាមមេក្រូដែរឬទេ? សាក្សីបានបញ្ជាក់ថា នៅពេលនោះមានតែការចាក់ចម្រៀងតាមមេក្រូតែប៉ុណ្ណោះ ។ បន្ទាប់មក មេធាវីបានបន្តសួរអំពីការប្រើប្រាស់ឯកសណ្ឋានរបស់ទ័ព ។ សាក្សីបានបញ្ជាក់ថា ជាធម្មតាសម្លៀកបំពាក់ខ្មែរក្រហម គឺពណ៌ខ្មៅ ប៉ុន្តែក្រោយមកនៅពេលដែលខ្មែរក្រហមវាយបានបន្ទាយណាមួយនោះគឺត្រូវយកទាំងខោអាវរបស់ទាហាននោះទៀត ម៉្លោះហើយទ័ពនៅពេលនោះស្លៀកពាក់ឯកសណ្ឋានចំរុះ ។

## ៥.២) ក្រុមមេធាវីការពារក្តី អៀង សារី

បន្ទាប់ពីបញ្ចប់ការសួរដេញដោលរបស់មេធាវីការពារក្តី នួន ជា មេធាវី ម៉ៃឃើល ការណាវ៉ាស បានចាប់ផ្តើមសួរសាក្សីទាក់ទងនឹងសហចៅក្រមស៊ើបអង្កេតដែលសាក្សីបានផ្តល់បទសម្ភាសន៍ខ្លួន ។ សាក្សីបានបញ្ជាក់ថា សហចៅក្រមដែលមកសម្ភាសន៍ខ្លួនទាំងពីរលើក គឺសុទ្ធតែជាមនុស្សផ្សេងគ្នាទាំងអស់ ។ មេធាវីបានបន្តសួរទាក់ទងនឹងនីតិវិធីក្នុងការសម្ភាសន៍ ។ សាក្សីបានបញ្ជាក់ថា ការសម្ភាសន៍លើកទី១ គឺមានការផ្តល់ឯកសារជូនមកខ្លួន និងមានថតសម្លេងក្នុងរយៈពេលកន្លះម៉ោង ។ ចំណែកការសម្ភាសន៍លើកទី២ ធ្វើឡើងរយៈពេលប្រហែល១០នាទីប៉ុណ្ណោះ ។ មុនពេលបញ្ចប់ មេធាវីអន្តរជាតិ ម៉ៃឃើល ការណាវ៉ាស បានសួរទាក់ទងនឹងការឃារយាមនៅស្ថានទូតបារាំង ។ សាក្សីបានបញ្ជាក់ថា ខ្លួនទៅប្រចាំការនៅស្ថានទូតបារាំង ហើយនៅថ្ងៃបន្ទាប់ខ្លួនបានដឹងថា មានការចាប់មនុស្ស និងចាប់ទាហាន លន់ នល់ យកទៅសម្លាប់តាមរយៈ គឿន ដែលជាអ្នកនិយាយប្រាប់ ។


ទិដ្ឋភាពទីក្រុងភ្នំពេញឆ្នាំ១៩៧៩ ក្រោយការចូលមកដល់នៃកងទ័ពវៀតណាម (ប្រភព : មជ្ឈមណ្ឌលឯកសារកម្ពុជា)

# សវនាការស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណី មុំ សំអឿន ថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១២

បន្ទាប់ពីបញ្ចប់ការស្តាប់សក្ខីកម្មរបស់សាក្សី ស៊ុំ ជា នៅថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១២ អង្គជំនុំជម្រះសាលាដំបូង បានបន្តបើកសវនាការស្តាប់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីមួយរូបទៀត គឺ មុំ សំអឿន ។ អង្គជំនុំជម្រះគ្រោងនឹងធ្វើសវនការមួយថ្ងៃពេញ ដោយផ្តល់ពេលវេលាជូនសហព្រះរាជអាជ្ញា និងមេធាវីដើមបណ្តឹងរដ្ឋប្បវេណីរយៈពេលកន្លះថ្ងៃ ដើម្បីសួរដេញដោល និងកន្លះថ្ងៃទៀតគឺសម្រាប់មេធាវីការពារក្តីជនជាប់ចោទទាំងបីក្រុម ។ មេធាវីការពារក្តី ជនជាប់ចោទ អៀង សារី និង ខៀវ សំផន បានបញ្ជាក់ថា ខ្លួនគ្មានសំណួរនឹងចោទសួរទេ ដូច្នេះ សវនាការនេះបានចប់មុនពេលកំណត់ពោលគឺប្រើពេលជាងកន្លះថ្ងៃតែប៉ុណ្ណោះ ។

សវនាការស្តាប់សក្ខីកម្ម លោកស្រី មុំ សំអឿន បានប្រព្រឹត្តទៅដោយរលូន ដោយមានអ្នកចូលរួមតាមដានដោយផ្ទាល់ក្នុងបន្ទប់សវនាការប្រមាណ៤០០ នាក់មកពីខេត្តកំពត និងកណ្តាល ។



ទីក្រុងភ្នំពេញក្រោយពីគ្រាប់ផ្លោងខ្មែរក្រហមបាញ់ផ្តក់ត្រូវ ។ ផ្ទះសម្បែងប្រជាជនច្រើនខ្នងត្រូវបានបំផ្លាញនៅដើមឆ្នាំ១៩៧២ (ប្រភព : មជ្ឈមណ្ឌលឯកសារកម្ពុជា)

មុននឹងអនុញ្ញាតឲ្យភាគីទាំងអស់សួរដេញដោល ប្រធានអង្គជំនុំជម្រះ និល ណុន បានប្រាប់អំពីសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការថ្លែងទុក្ខសោកទាំងឡាយ ដែលទទួលរងផលប៉ះពាល់ពីរបបកម្ពុជាប្រជាធិបតេយ្យ ។ ក្នុងអំឡុងពេលនោះដែរ មេធាវីដើមបណ្តឹងរដ្ឋប្បវេណីមួយរូបគឺ មេធាវី ហុង គឹមសួន បានស្នើសុំអង្គជំនុំជម្រះអនុញ្ញាតឲ្យសួរលើអង្គហេតុទាំងមូល ដែលកូនក្តីរបស់ខ្លួនបានដឹងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដោយផ្តល់ហេតុផលថា កូនក្តីរបស់ខ្លួនមានវ័យចាស់ជរាដែលប្រហែលជាមិនអាចមកផ្តល់សក្ខីកម្មជាលើកទី២បាន ។ ប៉ុន្តែសំណើនេះត្រូវបានប្រធានអង្គជំនុំជម្រះបដិសេធគឺ អនុញ្ញាតឲ្យភាគីទាំងអស់សួរត្រឹមអង្គហេតុដែលត្រូវជំនុំជម្រះក្នុងសំណុំរឿង០០២/១តែប៉ុណ្ណោះ ។ អង្គជំនុំជម្រះផ្តល់សំអាងហេតុថា ដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានអនុញ្ញាតឲ្យថ្លែងទុក្ខសោកទាំងអស់ដែលខ្លួនបានទទួលរង ដូច្នេះដើមបណ្តឹងរដ្ឋប្បវេណីអាចថ្លែងគ្របដណ្តប់លើអង្គហេតុទាំងមូលបាន ។

ដូចធ្លាប់បានអនុវត្តរួចមកហើយ ក្នុងការសួរដេញដោលដើមបណ្តឹងរដ្ឋប្បវេណី ប្រធានអង្គជំនុំជម្រះផ្តល់ឱកាសឲ្យមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីចោទសំណួរទៅកាន់កូនក្តីរបស់ខ្លួនមុនគេ បន្ទាប់មកទើបតំណាងសហព្រះរាជអាជ្ញា និងមេធាវីការពារក្តីជនជាប់ចោទ ។ សវនាការនេះប្រព្រឹត្តទៅដោយអវត្តមានជនជាប់ចោទ អៀង សារី និង នួន ជា នៅពេលព្រឹក ។ នៅពេលរសៀល ជនជាប់ចោទទាំងពីររូបនេះបានលះបង់សិទ្ធិចូលរួមសវនាការទេ ដោយសារបញ្ហាសុខភាព ។

អ៊ំស្រី មុំ សំអឿន កើតថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ១៩២៧ នៅទីក្រុងភ្នំពេញ បច្ចុប្បន្នរស់នៅជាមួយកូននៅទីក្រុងភ្នំពេញ ។ ឪពុកឈ្មោះ សួស មុំ ធ្លាប់ធ្វើជាគ្រូពេទ្យនៅក្នុងព្រះបរមរាជវាំង ម្តាយឈ្មោះ គឹម ពុន ។ អ៊ំស្រីមានកូនចំនួន១១នាក់ ប៉ុន្តែត្រូវបានសម្លាប់នៅក្នុងរបបខ្មែរក្រហមចំនួន៦នាក់ ។ មុនរបបខ្មែរក្រហម អ៊ំស្រី ធ្លាប់ធ្វើជាគ្រូបង្រៀន ។ អ៊ំស្រីបានស្គាល់ អៀង សារី និង

ប៉ុល ពត យ៉ាងច្បាស់ ព្រោះធ្លាប់រៀននៅសាលាព្រះស៊ីសុវត្ថិជាមួយគ្នា ។ ជាងនេះទៅទៀត អ៊ំស្រីធ្លាប់រៀនថ្នាក់ជាមួយ ខៀវ ធីរ៉ាត់ ដែលត្រូវជាបងស្រីបង្កើតរបស់ ខៀវ ធីរិទ្ធ (អៀង ធីរិទ្ធ) ។ ទោះបីជាយ៉ាងណាក៏ដោយ ស្ទើរពេញមួយរបបខ្មែរក្រហម អ៊ំស្រីមិនដឹងថា អ្នកទាំងនេះ មានមុខនាទីជាអ្វីឡើយ គឺទើបតែដឹងថាអ្នកទាំងនេះគឺជាមេដឹកនាំខ្មែរក្រហមនៅពេលដែលរបបនេះជិតដួលរលំទៅហើយ ។

## ១) ការសួរដេញដោលដោយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី

ក្នុងការសួរដេញដោលអ៊ំស្រី មុំ សំអឿន មេធាវី ហុង គឹមសួន បានសួរផ្តោតសំខាន់ លើព្រឹត្តិការណ៍ជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ និងផលប៉ះពាល់ផ្សេងៗ ដែលអ្នកស្រីបានទទួលរងបន្ទាប់ពីខ្មែរក្រហមបានឡើងកាន់អំណាច ។ ឆ្លើយតបនឹងសំណួរទាំងនោះ អ៊ំស្រី មុំ សំអឿន បញ្ជាក់ថា បន្ទាប់ពីខ្មែរក្រហម



ដើមបណ្តឹងរដ្ឋប្បវេណី មុំ សំអឿន
(ប្រភព ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)

ឡើងកាន់អំណាចនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ប្រជាជនទាំងអស់ត្រូវបានជម្លៀសចេញពីទីក្រុងភ្នំពេញដោយបង្ខំ ។ ឳពុកក្មេករបស់អ៊ំស្រីត្រូវបានយោធាខ្មែរក្រហមចាប់ខ្លួនភ្លាមៗ ហើយនាំយកទៅបាត់រហូត ។ ដោយមើលឃើញសភាពការណ៍បែបនេះ អ៊ំស្រីមានអារម្មណ៍តក់ស្លុតយ៉ាងខ្លាំង ។ អ៊ំស្រីហៀបនឹងប្រមូលទ្រព្យសម្បត្តិមួយចំនួនទុកជាប់នឹងខ្លួន ប៉ុន្តែត្រូវទាហានខ្មែរក្រហមមកទាន់ ហើយយកកាំភ្លើងភ្ជង់ និងបង្គាប់ឲ្យចេញពីផ្ទះទាំងគ្រួសារ ។ យោធាខ្មែរក្រហមបានប្រាប់ អ៊ំស្រីថា មិនចាំបាច់យកទ្រព្យសម្បត្តិអ្វីទៅទាំងអស់ ព្រោះអង្គការឲ្យចេញតែបីថ្ងៃប៉ុណ្ណោះ ។

អ៊ំស្រី មុំ សំអឿន បានបញ្ជាក់បន្ថែមថា យោធាខ្មែរក្រហមប្រដាប់ដោយអាវុធ បានដើរយ៉ាងប្រកៀកនឹងប្រជាជន និងបង្ខំឲ្យដើរទៅមុខដោយគ្មាននរណាម្នាក់ហានជំទាស់ឡើយ ។ អ្នកដែលហ៊ានជំទាស់ តវ៉ា គឺត្រូវបានបាញ់សម្លាប់ចោល ។ ក្នុងពេលកំពុងធ្វើដំណើរ អ៊ំស្រីបានឃើញសាកសពជាច្រើននៅតាមផ្លូវ ដែលមានទាំងប្រជាជនស៊ីវិល និងទាហានលន់នល់ ។ សាកសពទាំងនោះភាគច្រើន ត្រូវបានបាញ់សម្លាប់ចំក្បាលពីក្រោយ ។ ក្នុងអំឡុងពេលនោះដែរ មានស្ត្រីម្នាក់កំពុងរលូតកូន ហើយស្រែកហៅរកជំនួយ ប៉ុន្តែគ្មាននរណាម្នាក់ហ៊ានឈប់មើលឡើយ ពោលគឺម្នាក់ៗមានការភ័យខ្លាចគ្រប់ៗគ្នា ។

អ៊ំស្រី មុំ សំអឿន បានរៀបរាប់ថា អ៊ំស្រី និងប្រជាជនផ្សេងៗទៀត ត្រូវបានយោធាខ្មែរក្រហមជម្លៀសទៅដល់ខឿនព្រះវិហារ ។ នៅពេលដែលមេធាវី ហុង គឹមសួង សួរថា តើក្នុងពេលជម្លៀស បក្សបានចាត់វិធានការអ្វីខ្លះ ដើម្បីសម្រួលដល់ប្រជាជន? អ៊ំស្រីបញ្ជាក់ថា បក្សមិនបានចាត់វិធានការអ្វីទាំងអស់ ។ ប្រជាជនត្រូវធ្វើដំណើរដោយថ្មើរជើងនៅក្រោមកំដៅថ្ងៃ ដេកផ្ទាល់នឹងដី ខ្វះទឹក និងអាហារបរិភោគ គ្មានមន្ទីរពេទ្យ ។ល ។ ផ្ទុយមកវិញ យោធាខ្មែរក្រហមបានប្រើពាក្យប្រមាថ មើលងាយ និងជារឿយៗតែងតែហៅប្រជាជនទាំងនោះថា "ពួកអាសក្តិភូមិ" ។ ពេលឈប់សម្រាកនៅតាមផ្លូវ យោធាខ្មែរក្រហមបានតាមដានប្រជាជន និងសួរនាំអំពីការងារដែលធ្លាប់ធ្វើពីមុន ហើយខ្មែរក្រហមបានប្រើពាក្យ "ចាំមើល! តែបដិវត្តរកឃើញមិនរួចខ្លួនទេ" ។ អ៊ំស្រី មុំ សំអឿន បានបញ្ជាក់បន្ថែមថា ពេលធ្វើដំណើរនៅតាមដងទន្លេ អ៊ំស្រីបានឃើញកប៉ាល់ជាច្រើនគ្រឿងដឹកប្រជាជនចេញពីទីក្រុង ហើយពេលកប៉ាល់ត្រឡប់មកវិញ គឺដឹកតែសម្លៀកបំពាក់ និងសំភារៈផ្សេងៗតែប៉ុណ្ណោះ ។ អ៊ំស្រីមិនដឹងថាប្រជាជនទាំងនោះត្រូវបានសម្លាប់ឬយ៉ាងណានោះទេ ។

នៅពេលមេធាវី ហុង គឹមសួន សួរនាំពាក់ព័ន្ធនឹងការបាត់បង់សមាជិកគ្រួសារ អ៊ំស្រី មុំ សំអឿន បានឆ្លើយទាំងទឹកភ្នែកជូនអង្គ

ជំនុំជម្រះថា កូនប្រុសតូចរបស់អ៊ំស្រីត្រូវបានខ្មែរក្រហមបញ្ជូនឲ្យទៅឃ្វាលគោ ។ កូនប្រុសតូចនោះត្រូវបានគោជាន់ចំមុខ បណ្តាលឲ្យបែកថ្គាម ហើយនៅពេលដែលអ៊ំស្រីយំ ខ្មែរក្រហមបានស្តីបន្ទោសថា “យាយឯងសក្តិភូមិ មិនចេះប្រើកូន ថ្នមកូន កូនមិនចេះធ្វើអី ឥឡូវគោជាន់បែកមុខ សមមុខហើយយាយឯង” ។ កូនប្រុសម្នាក់ទៀតត្រូវបានខ្មែរក្រហម ចាប់ឃុំខ្លួននៅក្នុងចេតិយ ។ នៅពេលដែលអ៊ំស្រីសួរនាំអំពីមូលហេតុនៃការចាប់ខ្លួននោះ ខ្មែរក្រហមគំហកដាក់ថា “យាយឯងអីក៏សេរីម្ល៉េះ បានជាហានមកតវ៉ា” ។ បន្ទាប់ពីបានឮដូច្នេះ អ៊ំស្រីត្រឡប់មកវិញ ដោយមិនហ៊ានតវ៉ាអ្វីឡើយ ព្រោះខ្លាចមានគ្រោះថ្នាក់ទាំងខ្លួនឯងទៀត ។ ចំណែកកូនផ្សេងៗទៀត គឺត្រូវបានខ្មែរក្រហមបំបែកឲ្យទៅរស់នៅតាមសហករណ៍ផ្សេងៗគ្នា លើកលែងតែកូនម្នាក់ដែលកំពុងមានជំងឺ ។ ចំពោះប្តីរបស់អ៊ំស្រីវិញ គឺត្រូវបានខ្មែរក្រហមចាប់ ហើយបានបាត់ខ្លួនរហូត ។ អ៊ំស្រីបញ្ជាក់បន្ថែមថា មុនរបបខ្មែរក្រហម ប្តីរបស់អ៊ំស្រីគឺជាអគ្គនាយកក្រុមហ៊ុនលក់គ្រឿងខ្មៅ និងជាម្ចាស់ក្រុមហ៊ុនប្រមូលទិញស្រូវ ពោត ដោយមានការសហការជាមួយប្រទេសជប៉ុន ។ ក្រៅពីនេះ ប្តីអ៊ំស្រី គឺធ្លាប់ធ្វើជាសាស្ត្រាចារ្យបង្រៀននៅសាលាចំការដូង និងសាលាកសិកម្មព្រែកលៀប ។ ក្នុងពេលចាកចេញពីទីក្រុងភ្នំពេញ ក្រុមគ្រួសាររបស់អ៊ំស្រីមិនត្រូវបានអនុញ្ញាតឲ្យយកទ្រព្យសម្បត្តិអ្វីទាំងអស់ គឺឲ្យយកតែអង្ករនិងត្រីងៀតបន្តិចបន្តួចសម្រាប់បរិភោគតែប៉ុណ្ណោះ ដោយខ្មែរក្រហមប្រកាសថា បីថ្ងៃក្រោយនឹងអាចវិលត្រឡប់មកផ្ទះវិញ ។ ចុងក្រោយអ៊ំស្រី មុំ សំអឿន បញ្ជាក់ថា បន្ទាប់ពីរបបខ្មែរក្រហមត្រូវបានផ្តួលរំលំ អ៊ំស្រីធ្វើដំណើរជាមួយកូនដែលនៅសល់ពីការស្លាប់ចំនួន៥នាក់វិលមកទីក្រុងភ្នំពេញវិញ ហើយពេលនោះ ទ្រព្យសម្បត្តិដែលអ៊ំស្រីមានពីពេលមុនចាកចេញពីទីក្រុង គឺបានបាត់បង់ទាំងអស់ ។

## ២) ការសួរដេញដោលដោយតំណាងសហព្រះរាជអាជ្ញា

ក្រៅពីការសួរបញ្ជាក់បន្ថែមអំពីស្ថានភាពនៃការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ វីនសិន ដឺវ៉ាល់ បានសួរសំណួរមួយចំនួនបន្ថែមពាក់ព័ន្ធនឹងការចាប់ខ្លួនប្រពន្ធរបស់អតីតទាហាននៃរបប លន់ នល់ បញ្ជូនទៅកោះខ្សាច់ជន្លៀ ។ ឆ្លើយតបនឹងសំណួរទាំងនេះ អ៊ំស្រី មុំ សំអឿន បានរៀបរាប់ថា កោះខ្សាច់ជន្លៀ គឺជាគុកឥតជញ្ជាំងមួយ ដែលប្រជាជនថ្មី រួមមាន ប្រពន្ធរបស់អតីតទាហាន និងមន្ត្រីរាជការក្នុងរបប លន់ នល់ ត្រូវបានបញ្ជូនឲ្យទៅធ្វើការជាទម្ងន់នៅទីនោះ ។ អ្នកដែលបានប្រព្រឹត្តខុសបន្តិចបន្តួច នឹងត្រូវបានយកទៅសម្លាប់ចោល ។ ស្ត្រីម្នាក់ ត្រូវបានបង្គាប់ឲ្យជីករណ្តៅសម្រាប់កប់ខ្លួនឯង ហើយក្រោយមកត្រូវបានវាយនឹងត្បូងចបសម្លាប់ ដោយសារការលួចល្ហុតហូប ។

បន្ទាប់មក តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ វីនសិន បានព្យាយាមសួរសំណួរពាក់ព័ន្ធនឹងការចាប់ខ្លួនអតីតទាហាន និងមន្ត្រីរាជការរបស់របប លន់ នល់ ប៉ុន្តែអ៊ំស្រី មុំ សំអឿន មិនបានដឹងច្រើនអំពីបញ្ហាទាំងនេះឡើយ ។

## ៣) ការធ្វើសេចក្តីថ្លែងទុក្ខសោករបស់ដើមបណ្តឹងរដ្ឋប្បវេណី

បន្ទាប់ពីតំណាងសហព្រះរាជអាជ្ញាបញ្ចប់សំណួររបស់ខ្លួន ហើយក្រុមមេធាវីការពារក្តីបញ្ជាក់ថា ខ្លួនពុំមានសំណួរប្រធានអង្គជំនុំជម្រះបានប្រគល់វេទិកាជូនអ៊ំស្រី មុំ សំអឿន ដើម្បីធ្វើសេចក្តី ថ្លែងទុកសោកទាំងឡាយ ដែលអ៊ំស្រីបានទទួលរងផលប៉ះពាល់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ បន្ទាប់ពីទទួលបានការអនុញ្ញាតនេះ អ៊ំស្រី មុំ សំអឿន បានលើកឡើងថា បន្ទាប់ពីបានឆ្លងកាត់របបខ្មែរក្រហម អ៊ំស្រីទទួលរងទុកវេទនាយ៉ាងខ្លាំង ព្រោះបាត់បង់ទាំងប្តី កូន និងទ្រព្យសម្បត្តិ ។ សុខភាពមានការធ្លាក់ចុះទ្រុឌទ្រោមយ៉ាងខ្លាំង ហើយត្រូវខំប្រឹងប្រែងរកស៊ីចិញ្ចឹមកូនទាំង៥នាក់ ។ នៅពេលនឹកដល់ការព្រាត់ប្រាស់ ការសម្លាប់នៅក្នុងសម័យ ប៉ុល ពត គឺនៅតែធ្វើឲ្យអារម្មណ៍របស់អ៊ំស្រីមានការភ័យតក់ស្លុតជាខ្លាំង ។ ទោះបីជាយ៉ាងណាក៏ដោយ អ៊ំស្រី មុំ សំអឿន មិនបានទាមទារសំណងជំងឺចិត្ត ចំពោះការបាត់បង់នេះឡើយ គឺបន់ស្រន់សូមកុំឲ្យជួបរបបខ្មែរក្រហមម្តងទៀត ។

បន្ទាប់ពីដើមបណ្តឹងរដ្ឋប្បវេណីធ្វើសេចក្តីថ្លែងទុក្ខសោកចប់សព្វគ្រប់ ប្រធានអង្គជំនុំជម្រះបានអនុញ្ញាតឲ្យភាគីការពារក្តីមានឱកាសធ្វើការកត់សម្គាល់ចំពោះការធ្វើសេចក្តីថ្លែងទុក្ខសោកទាំងនោះ ប៉ុន្តែគ្មានក្រុមមេធាវីការពារក្តីជនជាប់ចោទណាម្នាក់ ធ្វើការកត់សម្គាល់លើសេចក្តីថ្លែងនេះឡើយ ។

# សវនាការស្តាប់សក្ខីកម្មសាក្សី ប៉ែជុយ ជីពសែ
## ថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១២

នៅថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១២ អង្គជំនុំជម្រះសាលាដំបូងបានបើកសវនាការស្តាប់សក្ខីកម្មរបស់សាក្សី ប៉ែជុយ ជីពសែ អតីតអ្នកកាន់បញ្ជីឈ្មោះអ្នកទោសនៅមន្ទីរសន្តិសុខពង្រ ដែលមានទីតាំងនៅក្នុងស្រុកជីក្រែង ។ សវនាការបានប្រព្រឹត្តទៅដោយរលូន ដោយមានសាធារណៈជនចូលរួមតាមដាន ដោយផ្ទាល់ប្រមាណជាង ៣៦០នាក់ ប៉ុន្តែអវត្តមានជនជាប់ចោទ អៀង សារី នៅក្នុងបន្ទប់សវនាការ ដោយជនជាប់ចោទស្នើសុំចូលរួមសវនាការពីចម្ងាយ តាមរយៈប្រព័ន្ធសោតទស្សន៍នៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ ។

ដូចបានអនុវត្តកន្លងមកដែរ មុននឹងអនុញ្ញាតឲ្យភាគីទាំងអស់ចោទសំណួរទៅសាក្សី អង្គជំនុំជម្រះបានចោទសំណួរមួយចំនួនដើម្បីកំណត់អំពីអត្តសញ្ញាណរបស់សាក្សី និងភាពត្រឹមត្រូវនៃសក្ខីកម្មដែល សាក្សីបានផ្តល់ជូនអ្នកស៊ើបអង្កេត ។ បន្ទាប់មកអង្គជំនុំជម្រះប្រាប់អំពីសិទ្ធិរបស់សាក្សីក្នុងការមិនផ្តល់ សក្ខីកម្មប្រឆាំងនឹងខ្លួនឯង ដែលអាចនាំឲ្យមានពិរុទ្ធភាព និងករណីកិច្ចរបស់សាក្សីក្នុងការឆ្លើយតបសំណួររបស់ភាគី លើកលែងតែសំណួរដែលឆ្លើយទៅអាចដាក់បន្ទុកលើខ្លួនឯង ។ បន្ថែមលើនេះ អង្គជំនុំជម្រះ អនុញ្ញាតឲ្យសាក្សីឆ្លើយតែហេតុការណ៍ណាដែលខ្លួនបានដឹង បានឮ បានឃើញ បានចងចាំ ឬបានធ្វើការ សង្កេតដោយផ្ទាល់នូវព្រឹត្តិការណ៍នោះតែប៉ុណ្ណោះ ។ ពោលគឺមិនអាចឆ្លើយដោយស្មានឬព្រាវៗឡើយ ព្រោះចម្លើយទាំងនេះគឺពុំមានតម្លៃសម្រាប់ឲ្យអង្គជំនុំជម្រះយកធ្វើជាមូលដ្ឋានក្នុងការសម្រេចសេចក្តីឡើយ ។ ទន្ទឹមគ្នានេះដែរ អង្គជំនុំជម្រះបានផ្តល់មេធាវីជូនសាក្សីមួយរូប គឺមេធាវី មឿន សុវណ្ណ ដើម្បីប្រឹក្សាយោបល់មុននឹងផ្តល់សក្ខីកម្មលើអង្គហេតុទាំងឡាយណាដែលអាចដាក់បន្ទុកលើខ្លួនឯង ។ គួរបញ្ជាក់បន្ថែមថា មុននឹងផ្តល់វេទិកាជូនភាគី ប្រធានអង្គជំនុំជម្រះបានកំណត់ថា ក្នុងការសួរដេញដោល សាក្សី ភាគីទាំងអស់ត្រូវផ្តោតសំខាន់លើអង្គហេតុស្តីពីរចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់មូលដ្ឋាន និងគោលនយោបាយទូទៅនៃការជម្លៀសប្រជាជន ។

### ១) ប្រវត្តិសាវតាររបស់សាក្សី ប៉ែជុយ ជីពសែ

ប៉ែជុយ ជីពសែ មានអាយុ៥៨ឆ្នាំ បច្ចុប្បន្នរស់នៅក្នុងភូមិថ្មី ឃុំគោកធ្លកក្រោម ស្រុក ជីក្រែង ខេត្តសៀមរាប ។ មុខរបរធ្វើជាគ្រូបង្រៀននៅសាលាបឋមសិក្សាគីឡូគាឈឹម ។ ឪពុកឈ្មោះ ឆេង ជុយ ម្តាយឈ្មោះ តែ អៀក ប្រពន្ធឈ្មោះ កៅ ម៉េងអ៊ី និងមានកូនចំនួន៣នាក់ ។ នៅក្នុងអំឡុង ឆ្នាំ១៩៧១ ជីពសែ បានចូលរួមចលនាបដិវត្តន៍របស់ខ្មែរក្រហមនៅក្នុងព្រៃ ។ ឆ្នាំ១៩៧២ ជីពសែ បានរត់ចេញពីខ្មែរក្រហមវិញ ដោយសារពេលនោះ



សាក្សី ប៉ែជុយ ជីពសែ
(ប្រភព ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្មែរក្រហមមានការប្រទាញប្រទង់គ្នា រហូតដល់មានការបង្កើតយុទ្ធនាការមួយហៅថា"យុទ្ធនាការចេនឡាទី២" ។ ជីពសែ បានបញ្ជាក់បន្ថែមថា ក្នុងអំឡុងឆ្នាំ១៩៧៤ ប្រជាជនជាច្រើនត្រូវបានខ្មែរក្រហមសម្លាប់ចោល ដោយខ្មែរក្រហមចោទប្រកាន់ថាប្រជាជន ទាំងនោះបានរត់ចេញពីខ្លួន ហើយទៅទាក់ទងជាមួយ លន់ នល់ ។ ចាប់ពីឆ្នាំ១៩៧៣ រហូតដល់ឆ្នាំ១៩៧៧ ជីពសែ ត្រូវបានចាត់តាំងឲ្យបម្រើការងារនៅមន្ទីរសន្តិសុខ គឺមានតួនាទីជាអ្នកកាន់កាប់បញ្ជីឈ្មោះអ្នកទោសនៅមន្ទីរសន្តិសុខពង្រ ក្នុងស្រុកជីក្រែង ខេត្តសៀមរាប និងទទួលបន្ទុកកត់ត្រាឈ្មោះ អ្នក

ទោសដែលត្រូវបាននាំចេញ និងនាំចូលមន្ទីរសន្តិសុខនេះ ។ គួរបញ្ជាក់ថា សក្ខីកម្មរបស់ ដីពសែ នៅចំពោះមុខអង្គជំនុំជម្រះភាគច្រើនគឺពាក់ព័ន្ធនឹងរចនាសម្ព័ន្ធគ្រប់គ្រងនៅមន្ទីរសន្តិសុខពព្រ រចនាសម្ព័ន្ធ រដ្ឋបាលនៅស្រុកជីក្រែង និងការសម្លាប់អតីតទាហាន និងមន្ត្រីរដ្ឋការរបស់របប លន់ នល់ ដែលត្រូវបានជម្លៀសមកពីខេត្តសៀមរាប ។

## ២) សក្ខីកម្មរបស់សាក្សីពាក់ព័ន្ធនឹងមន្ទីរសន្តិសុខពព្រ



ទិដ្ឋភាពប្រជាជនកំពុងធ្វើការ នៅក្នុងការដ្ឋានក្នុងអំឡុងពេលនៃរបបខ្មែរក្រហម (ប្រភព ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា)

ដីពសែ បញ្ជាក់ថា មន្ទីរសន្តិសុខពព្រ មានទីតាំងនៅក្នុងស្រុកជីក្រែង ខេត្តសៀមរាប ។ មន្ទីរនេះ ត្រូវបានរៀបចំជាអង្គការសម្ងាត់ ហើយត្រូវបានបង្កើតឡើងដើម្បីដាក់អ្នកទោសនៅស្រុកជីក្រែង ។ អ្នកទោសដែលត្រូវបានបញ្ជូនមកមន្ទីរសន្តិសុខនេះគឺភាគច្រើនត្រូវបានសម្លាប់ចោល ដោយទទួលការ ចោទប្រកាន់ថាជាពួកចក្រពត្តិ ។ មន្ទីរសន្តិសុខនេះស្ថិតនៅក្រោមការគ្រប់គ្រងរបស់ស្រុកជីក្រែង ដែលមាន តាស៊ុន និងក្រោយមក តាសុខ គឺជាលេខាស្រុក ។ ប្រធានមន្ទីរសន្តិសុខពព្រដំបូងគឺ តាវ័ន្ត ក្រោយមក តាគន់ (បន្ទាប់ពី តាវ័ន្ត ត្រូវបាន តាសុខ ចោទថាក្បត់) ។ ក្នុងអំឡុងពេលបំពេញតួនាទី តាវ័ន្ត និង តាគន់ បានរាយការណ៍ជាប្រចាំទៅគណៈស្រុកអំពីស្ថានភាពអ្នកទោសនៅមន្ទីរសន្តិសុខនេះ ។ ដីពសែ បញ្ជាក់បន្ថែមថា ក្នុងការចាប់ខ្លួនអ្នកទោសនៅតាមមូលដ្ឋានណាមួយ គឺត្រូវបានធ្វើបន្ទាប់ពីមានការរាយការណ៍ពីមេឃុំនៅតាមមូលដ្ឋានទាំងនោះ ។ ក្នុងនាមជាអ្នកកាន់កាប់បញ្ជីឈ្មោះអ្នកទោស លោក(ដីពសែ) ត្រូវធ្វើការកត់ត្រានូវឈ្មោះកាលបរិច្ឆេទ ប្រភេទនៃអ្នកទោស ដែលត្រូវបានចាប់ខ្លួនបញ្ជូនមកមន្ទីរសន្តិសុខពព្រ ។ បញ្ជីឈ្មោះ និងចម្លើយសារភាពរបស់អ្នកទោស ត្រូវបានប្រធានមន្ទីរសន្តិសុខបញ្ជូនទៅគណៈស្រុក ។ បន្ទាប់មកបញ្ជីឈ្មោះនេះត្រូវបានបញ្ជូនត្រឡប់មកវិញ ហើយឈ្មោះអ្នកដែលត្រូវសម្លាប់ គឺគូសញ្ញាខ្វែងព័ណក្រហម ។ ចំពោះអ្នកទោសដែលមិនត្រូវបានសម្លាប់ គឺត្រូវទទួលការអប់រំកែប្រែ

តាមរយៈការដាក់ឲ្យធ្វើការជាទម្ងន់ ។ ជីពសែ បានបញ្ជាក់ទៀតថា ថ្នាក់លើបានបង្គាប់ឲ្យធ្វើការបែងចែកឲ្យបានច្បាស់រវាងអ្នកទោស ដែលជាប្រជាជនថ្មី និងប្រជាជនមកពីមូលដ្ឋាន ។ អ្នកទោស ដែលជាប្រជាជនថ្មីគឺត្រូវបានដាក់ឲ្យធ្វើការធ្ងន់ជាងអ្នកទោសមកពី មូលដ្ឋាន ។ បន្ថែមលើនេះ អ្នកទោសត្រូវបានសួរយកចម្លើយ ដោយប្រើទារុណកម្ម និងត្រូវបានបង្គាប់ឲ្យឆ្លើយតាមអ្វីដែល អ្នកសួរចម្លើយ ប្រាប់ឲ្យឆ្លើយ បើមិនឆ្លើយនោះនឹងត្រូវបានវាយ រហូតដល់ស្លាប់ ។ មានអ្នកទោសផ្សេងទៀតបានស្លាប់ទាំងជាប់ ខ្នោះ ដោយសារពុំមានអាហារហូបគ្រប់គ្រាន់ និងមិនអាចទ្រាំ បាននឹងអាកាសធាតុនៅទីនោះ ។

ទាក់ទងនឹងការធ្វើទារុណកម្ម និងសម្លាប់អ្នកទោសនៅមន្ទីរ សន្តិសុខពង្រ ជីពសែ ធ្លាប់បានបញ្ជាក់ ជូនសហចៅក្រមស៊ើប អង្កេតថា *"អ្នកទោសត្រូវបានសម្លាប់ដោយយកដំបងវាយចំ ក្បាល ។ ពេលអ្នកទោសដួលគេយកកាំបិតអារ-កថែមទៀត រួចហើយរុញសាកសពទម្លាក់ចូលក្នុងរណ្តៅ ។ សម្លាប់រួច ហើយគេ កប់រណ្តៅវិញ"* ។ ទោះបីជាយ៉ាងណា ជីពសែ មិនបានឃើញព្រឹត្ត ការណ៍នេះដោយផ្ទាល់នោះទេ ដោយលោកបញ្ជាក់ថា លោកបាន ដឹងតាមរយៈអ្នកដែលយកអ្នកទោសនោះទៅសម្លាប់តែប៉ុណ្ណោះ ។

ចុងក្រោយ ជីពសែ បញ្ជាក់ថា មន្ទីរសន្តិសុខពង្រត្រូវបាន រំលាយចោល (បិទទ្វារ) ក្នុងឆ្នាំ១៩៧៧ ដោយមានការចោទ ប្រកាន់ថា កម្មាភិបាលដែលធ្វើការនៅក្នុងមន្ទីរសន្តិសុខនេះ គឺ សុទ្ធសឹងជាអ្នកក្បត់ ហើយឈ្មោះរបស់កម្មាភិបាលទាំងនោះ គឺត្រូវបានបញ្ជូនទៅថ្នាក់លើទាំងអស់ ។

គួរបញ្ជាក់ថា នៅពេលតំណាងសហព្រះរាជអាជ្ញា សេង ប៊ុនឃាង ចោទសំណួរទៅសាក្សីពាក់ព័ន្ធនឹងមន្ទីរសន្តិសុខពង្រ ក្រុមមេធាវីការពារក្តីជនជាប់ចោទ នួន ជា គឺមេធាវី ហ្សាស៊្តើប៉ោ បានជំទាស់ ដោយផ្តល់ហេតុផលថា អង្គហេតុទាក់ទងនឹងមន្ទីរ សន្តិសុខ គឺមិនស្ថិតនៅក្នុងវិសាលភាពនៃអង្គហេតុដែលត្រូវជំនុំ ជម្រះក្នុងដំណាក់កាលទី១ឡើយ ។ ប៉ុន្តែសេចក្តីជំទាស់នេះត្រូវ បានអង្គជំនុំជម្រះបដិសេធចោល ដោយអង្គជំនុំជម្រះផ្តល់សំអាង ហេតុថា សំណួររបស់តំណាងសហព្រះរាជអាជ្ញាគឺពាក់ព័ន្ធនឹង រចនាសម្ព័ន្ធ គ្រប់គ្រងរដ្ឋបាលនៅមន្ទីរសន្តិសុខពង្រ ពោលគឺមិន ចូលដល់អង្គហេតុជាក់លាក់ ឬស៊ីជម្រៅដល់អង្គហេតុ ដែលជា អំពើឧក្រិដ្ឋកម្មនៅក្នុងមន្ទីរសន្តិសុខនេះឡើយ ។

### ៣) រចនាសម្ព័ន្ធគ្រប់គ្រងនៅស្រុកជីក្រែង

ទាក់ទងនឹងរចនាសម្ព័ន្ធរដ្ឋបាល និងប្រព័ន្ធទំនាក់ទំនងការងារ នៅស្រុកជីក្រែង ជីពសែ បញ្ជាក់ថា ដំបូងឡើយលេខាស្រុកគឺ គាស៊ុន បន្ទាប់មកត្រូវបានចោទប្រកាន់ថាក្បត់ ហើយត្រូវបាន ជំនួសដោយ គាសុខ (មកពីនិរតី) ។ ស្រុកនេះត្រូវបានគ្រប់គ្រង ដោយតំបន់ ដែលមានឈ្មោះ សុទ្ធ ជាលេខាតំបន់ ។ បន្ទាប់ពី គាសុខ ឡើងធ្វើជាលេខាស្រុក តាវ៉ិត្ត ដែលជាប្រធានមន្ទីរសន្តិសុខ ពង្រ ត្រូវបានចាប់ខ្លួន ដោយចោទប្រកាន់ថាបានក្បត់ដែរ ហើយ ត្រូវបានជំនួសដោយ តាគន់ ។ សម្រាប់ទំនាក់ទំនងការងារ ប្រធាន មន្ទីរសន្តិសុខពង្រ គឺត្រូវរាយការណ៍ទៅគណៈស្រុក ហើយទទួល បញ្ជាត្រឡប់មកវិញ ចំណែកលេខាស្រុក គឺរាយការណ៍បន្តទៅ តំបន់ ។

### ៤) អំពីការជម្លៀសប្រជាជន

ឆ្លើយតបសំណួររបស់ក្រុមមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ពាក់ព័ន្ធនឹងការជម្លៀសប្រជាជន ជីពសែ បានបញ្ជាក់ថា ប្រជាជនមកពីខេត្តសៀមរាប និងទីក្រុងភ្នំពេញជាច្រើន មានទាំង មនុស្ស ចាស់ ក្មេង អ្នកជំងឺ អ្នកពិការ ពោលគឺមានគ្រប់រូបភាព ត្រូវបានជម្លៀសមកស្រុកជីក្រែង ។ ប្រជាជនទាំងនោះគឺត្រូវធ្វើ ដំណើរដោយថ្មើរជើង និងទទួលរងទុក្ខវេទនាយ៉ាងខ្លាំង ហើយនៅ តាមផ្លូវ ខ្មែរក្រហមពុំបានផ្តល់ជម្រក ឬផ្គត់ផ្គង់បាយទឹកឡើយ ។ ប្រជាជននៅខេត្តសៀមរាបត្រូវបានបង្ខំឲ្យចាកចេញពីផ្ទះ ដោយ យោធាខ្មែរក្រហមបានប្រើកាំភ្លើងបាញ់រះឡើងលើ ពោលគឺគ្មាន ប្រជាជនណាម្នាក់ហ៊ានប្រឆាំងឡើយ ។ ពេលទៅដល់មូលដ្ឋាន ប្រជាជនទាំងនោះត្រូវបានបំបែកឲ្យទៅរស់នៅតាមសហករណ៍ ផ្សេងៗគ្នា ។ ចំណែកអតីតទាហាន និងមន្ត្រីរដ្ឋការ (រួមទាំងក្រុម គ្រួសារ) របស់របប លន់ នល់ គឺត្រូវបានខ្មែរក្រហមជម្លៀសទៅ កំពុងក្តី ដើម្បីសួរយកចម្លើយ បន្ទាប់មកត្រូវបានសម្លាប់ចោល ទាំងអស់ ក្រោមបញ្ជារបស់គណៈតំបន់ ។ ជីពសែ បានបញ្ជាក់ បន្ថែមថា តាមការសង្កេតរបស់លោកផ្ទាល់ គឺឃើញថាគោល នយោបាយរបស់ខ្មែរក្រហម គឺពុំមានការពេញចិត្តចំពោះប្រជា

ជនថ្មីឡើយ ។ ប្រជាជនថ្មីបានទទួលរងនូវការមើលងាយ និង ត្រូវបានផ្តល់របបអាហារទាំងទើសទាល់ ព្រោះខ្មែរក្រហមតែងតែ គិតថាប្រជាជនទាំងនោះគឺសុទ្ធតែជាអ្នកដែលធ្លាប់រស់នៅជាមួយ លន់ នល់ ។

ជីពសែ បានបញ្ជាក់បន្ថែមថា បន្ទាប់ពីកម្មាភិបាលខ្មែរ ក្រហមមកនិរតីចូលគ្រប់គ្រងស្រុកជីក្រែង កម្មាភិបាលខ្មែរក្រហម បម្រើការមុនៗគឺត្រូវបានចាប់ខ្លួន ។ ក្រោយមកទៀតចាប់ខ្លួន ប្រជាជន១៧ មេសា យកទៅសម្លាប់ចោលនៅវត្តកំពង់ក្តី ដោយ



យោធាខ្មែរក្រហមកំពុងជិះនៅលើរថពាសដែក (ប្រភព : មជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្មែរក្រហមចោទថា ប្រជាជនទាំងនោះបានធ្វើការបោះបោរ សម្លាប់កម្មាភិបាលខ្មែរក្រហម ។

គួរបញ្ជាក់ថា នៅពេលតំណាងសហព្រះរាជអាជ្ញា សេង ប៊ុនយាង ចោទសំណួរទៅសាក្សីពាក់ព័ន្ធនឹងការជម្លៀសប្រជាជន ចេញពីខេត្តសៀមរាប ក្រុមមេធាវីការពារក្តីជនជាប់ចោទ នួន ជា គឺមេធាវី ហ្សាស្តើប៉ៅ បានជំទាស់យ៉ាងខ្លាំង ដោយផ្តល់ហេតុផល ថា អង្គហេតុស្តីពីការជម្លៀសប្រជាជនចេញពីខេត្តសៀមរាម គឺមិនស្ថិតនៅក្នុងវិសាលភាពនៃអង្គហេតុដែលត្រូវជំនុំជម្រះក្នុង ដំណាក់កាលទី១ឡើយ ។ ប៉ុន្តែសេចក្តីជំទាស់នេះត្រូវបានអង្គ ជំនុំជម្រះបដិសេធចោល ដោយអង្គជំនុំជម្រះផ្តល់សំអាងហេតុថា សំណួររបស់តំណាងសហព្រះរាជអាជ្ញា គឺពាក់ព័ន្ធទៅនឹងគោល នយោបាយទូទៅរបស់ខ្មែរក្រហមក្នុងការជម្លៀសប្រជាជន ។

**កំណត់សម្គាល់ :**

ក្នុងការសួរសាក្សី ក្រុមមេធាវីការពារក្តីជនជាប់ចោទ នួន ជា បានព្យាយាមសួរទាក់ទងនឹងវិធីសាស្រ្តដែលអ្នកស៊ើបអង្កេតសួរ យកចម្លើយរបស់សក្សី ពោលគឺអ្នកស៊ើបអង្កេតបានបង្ហាញ ឯកសារណាមួយជូនសាក្សីពិនិត្យ ដើម្បីផ្តល់សក្ខីកម្មដែរឬទេ? ជាងនេះទៅទៀត ក្នុងការផ្តល់សក្ខីកម្ម តើសាក្សីបានឆ្លើយតាម ការចងចាំរបស់ខ្លួនផ្ទាល់ ឬប្រើប្រាស់ឯកសារជំនួយក្នុងការផ្តល់ បទសម្ភាសន៍? ក្នុងការសួរសំណួរទាំងនេះ គឺមានបញ្ហាចម្រូង ចម្រាសមួយចំនួនរវាងក្រុម មេធាវីការពារក្តីជនជាប់ចោទ នួន ជា និងតំណាងសហព្រះរាជ អាជ្ញា នៅពេលស្តាប់សម្លេងខ្សែ អាត់ដែលសាក្សីបានផ្តល់ជូន អ្នកស៊ើបអង្កេតដោយក្រុម មេធាវីស្តាប់ឮថា«សូមទៅមើល ណូតបន្តិច» ចំណែកតំណាងសហ ព្រះរាជអាជ្ញាថា ស្តាប់មិនច្បាស់ តែឮថា«សូមទៅនោមបន្តិច» ហើយពេលសួរទៅសាក្សី សាក្សីបញ្ជាក់ថា ខ្លួនមិនច្បាស់ថា សម្លេងនោះជាសម្លេងរបស់ខ្លួនឬយ៉ាងណាដែរ ។ ប៉ុន្តែអង្គជំនុំ ជម្រះបញ្ជាក់ថា ពាក្យខ្មែរពុំមានពាក្យ«ណូត»ទេ ព្រោះពាក្យនេះ ជាភាសាបរទេស គឺមានតែពាក្យ«កំណត់ត្រា» ។

ចំពោះក្រុមមេធាវីការពារក្តីជនជាប់ចោទ ខៀវ សំផន ពុំមានសំណួរចោទសួរសាក្សីឡើយ ប៉ុន្តែ បានលើកឡើងអំពី ការបែងចែកពេលវេលាសម្រាប់ភាគីទាំងអស់ ។ មេធាវី អង់តា ហ្គីសសេ បានបញ្ជាក់ ថាតំណាងសហព្រះរាជអាជ្ញា និងក្រុម មេធាវីដើមបណ្តឹងរដ្ឋប្បវេណី បានប្រើពេលវេលាច្រើនជាងក្រុម មេធាវីការពារក្តីជនជាប់ចោទទាំងបីរូប ។ ចុងក្រោយលោកស្រី មេធាវី ស្នើឲ្យអង្គជំនុំជម្រះធ្វើការបែងចែកពេលវេលាឲ្យមាន សមភាពរវាងគូរភាគី ។

**ពិនិត្យ និងផ្ទៀងផ្ទាត់ដោយ វ៉ាន់ថាន់ ពោដារ៉ា**

## ពន្យល់ពាក្យសំខាន់ៗ

*អគ្គសេនាធិការ* ៖ ទីបញ្ជាការជាន់ខ្ពស់នៃកងទ័ពបដិវត្តន៍កម្ពុជា ដែលដឹកនាំដោយ សុន សេន មានទីតាំងស្ថិតនៅក្នុងទីក្រុងភ្នំពេញ ។

*សហករណ៍* ៖ អង្គភាពរដ្ឋបាលសង្គមមួយដែលត្រូវបានបង្កើតឡើងដោយខ្មែរក្រហម ដោយមានសមាសភាព១០០០គ្រួសារ បន្ទាប់ពីការរំលាយចោលរចនាសម្ព័ន្ធរដ្ឋបាលភូមិ-ឃុំ ។

*កងឈ្លប (សេនាជន)* ៖ កងកម្លាំងក្រៅពីកងទ័ពអាជីពរបស់ជាតិ ដែលត្រួតត្រានៅថ្នាក់ឃុំ តំបន់ ឬថ្នាក់ស្រុក ។

*កងចល័ត* ៖ ជាក្រុមពលករ ឬក្រុមមនុស្សដែលនៅលីវ មានអាយុចាប់ពីក្រោយវ័យជំទង់ទៅដល់ម្ភៃឆ្នាំប្លាយ ដែលមានភារកិច្ចត្រូវធ្វើដំណើរចល័តទៅបំពេញការងារពីកន្លែងមួយទៅកន្លែងមួយទៀតក្នុងកំពេងការណ៍នានា ។


## មជ្ឈមណ្ឌលឯកសារកម្ពុជា

ប្រអប់សំបុត្រលេខ១១១០, ភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ ៖ (៨៥៥) ២៣ ២១១ ៨៧៥
ទូរសារ ៖ (៨៥៥) ២៣ ២១០ ៣៥៨
អ៊ីម៉ែល ៖ *dccam@online.com.kh*
គេហទំព័រ ៖ *www.dccam.org*
ឬ *www.cambodiatribunal.org*



គម្រោងនេះទទួលជំនួយហិរញ្ញវត្ថុពីមូលនិធិ *John D. and Catherine T. MacArthur Foundation and British Embassy-Cambodia* ។


| ល.រ | ឈ្មោះដើម | ឈ្មោះបដិវត្ត | លេខសម្ងាត់ | ប្រភពឯកសារ |
|---|---|---|---|---|
| ១ | សាឡុត ស | ប៉ុល ពត, បងប៉ុល, បងទី១, | ៨៧០, ៨៧ | D427, E1/56.1 |
| ២ | នួន ជា | នួន ជា, បងនួន, បងទី២ | (អត់ដឹង) | D427 |
| ៣ | គីម ត្រាង | អៀង សារី, វ៉ាន់ | (អត់ដឹង) | D427, E1/21.1 |
| ៤ | ខៀវ សំផន | ហែម, ខាង, ណន | (អត់ដឹង) | D427 |
| ៥ | សុន សេន | ខៀវ, ឃឹម | ៨៩, ៦២ | E1/54.1 |



**ឆាយ ឈុនលី**

បរិញ្ញាបត្រច្បាប់ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។



**លឹម ជ័យឧត្តម**

បរិញ្ញាបត្រច្បាប់ និងបរិញ្ញាបត្រសេដ្ឋកិច្ច ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងជាជ័យលាភីថ្នាក់ជាតិក្នុងការប្រកួតសរនាការប្រឌិតឆ្នាំ ២០១០ ។



**ឌី សុជាតា**

បរិញ្ញាបត្រច្បាប់ សិក្សាជាភាសាអង់គ្លេស ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។



**ចាន់ ប្រាថ្នា**

បរិញ្ញាបត្រច្បាប់ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។



មជ្ឈមណ្ឌលឯកសារកម្ពុជា រក្សាសិទ្ធិខែត្ត ឆ្នាំ២០១២